ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Oct-2012, 13:27
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១២៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក សេង ប៊ុនឃាង

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី បេនី យេ *(Ms. Beini YE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្ង សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក គង់ គីម ហៅ កើ (TCW-362) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក គង់ គីម ហៅ កើ** (TCW-362)


សួរដោយលោកស្រី ជេត វណ្ណលី ផ្ដើមពី៖ ........................................ទំព័រ ១

សួរដោយលោកស្រី បេនី យេ ផ្ដើមពី៖........................................ទំព័រ ១៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖........................................ទំព័រ ១៨

សួរដោយលោក ហ្សាស្តេី ប៉ៅ ផ្ដើមពី៖ ........................................ទំព័រ ៣០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃគឺយើងនឹងបន្តស្តាប់សក្ខីកម្ម គង់ គីម ជាបន្ត ដែលអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរយៈពេល១ម៉ោង។ សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពដល់អង្គសវនាការទាំងមូល។

សួស្តីលោកសាក្សី គង់ គីម! ខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ពីម្សិលមិញលោកបំភ្លឺនូវចំណុចមួយចំនួនចំពោះអង្គជំនុំជម្រះ ហើយនិងនៅថ្ងៃនេះខ្ញុំសូមឱ្យលោកបំភ្លឺនូវចំណុចមួយចំនួនបន្ថែមទៀត ដើម្បីជាពន្លឺដល់អង្គជំនុំជម្រះ។ សូមអរគុណលោកទុកជាមុន។ ចំណុចដំបូងគឺយើងខ្ញុំនៅតែរក្សាការសួរនៅលើឯកសារ D166/74 ហើយនិងឯកសារ IS19.96 របស់មជ្ឈមណ្ឌលឯកសារ។ ជាដំបូងនេះខ្ញុំសូមសួរលោក គង់ គីម ប៉ុន្តែខ្ញុំសូមបកទៅក្រោមបន្តិច។ ខ្ញុំចង់សួរលោកថា តើនៅឆ្នាំណាដែលលោកធ្វើនីរសារ?

**លោក គង់ គីម៖**

**ឆ៖** បាទ ខ្ញុំបាទសូមឆ្លើយពីធ្វើនីរសារ ពេលដែលខ្ញុំចូលតាំងពីឆ្នាំ១៩៧៤ មកដល់សមរភូមិគេចាត់តាំងឱ្យធ្វើនីរសារ។ នីរសារអនុសេនាធំ។

**ស៖** នៅកន្លែងណាដែរលោក?

**ឆ៖** បាទ ពេលដែលខ្ញុំបំពេញភារកិច្ចជានីរសារនៅចំណុចព្រែកក្តាមហ្នឹង បាទ ជាមុខព្រួញបុកចូលភ្នំពេញ។

**សៈ** តើការធ្វើនីរសារនេះ គេចាត់ទុក -- គេចាត់តាំងលោក ឬក៏លោកស្ម័គ្រចិត្ត?

**ផៈ** បាទ ពេលនុ៎ងគឺការចាត់តាំងរបស់ប្រធានក្រុមដែលខ្ញុំនៅជាមួយ។

[០៩:០៥:០៦]

**សៈ** ក្នុងការងារនីរសារ តើលោកបានធ្វើអីខ្លះ? លោកនាំសំបុត្រពីកន្លែងណាទៅកន្លែងណាខ្លះ? ហើយលោកមានឯកសណ្ឋានយ៉ាងម៉េចដែរក្នុងនាមលោកជានីរសារ?

**ផៈ** បាទ ខ្ញុំបាទគឺឯកសណ្ឋានខ្មៅ ស្បែកជើងកង់ឡាន ហើយការនាំនូវសារគឺទី១ គឺនាំអ្នកដែលដឹកជញ្ជូនបាយពីសមរភូមិខាងក្រោយ យកទៅឲ្យសមរភូមិមុខ។ ទី២ គឺនាំអ្នកដែលប្រយុទ្ធហើយរបួស នាំពីសមរមុខបញ្ជូនទៅតាមស្នាក់ការៗ បញ្ជូនទៅក្រោយ។

**សៈ** ក្នុងនាមលោកជានីរសារ លោកមានកាន់កាំភ្លើងទេ?

**ផៈ** បាទ នៅពេលដែលខ្ញុំធ្វើនីរសារនេះគឺថា ចំនួននីរសារមិនមែនម្នាក់ឯងទេ ពេលដែលដឹកជញ្ជូនគឺខ្ញុំបាទកាលណោះនៅតូច បាទមិនបានកាន់កាំភ្លើងដោយអ្នកដទៃគេកាន់កាំភ្លើង គ្រាន់តែនាំដំណើរជាមួយគ្នា។

[០៩:០៦:៣១]

**សៈ** ពេលនោះលោកអាយុប៉ុន្មានលោក?

**ផៈ** បាទ ដោយខ្ញុំមិនបានចាំច្បាស់ បើស្មានប្រហែលជា១៥ឆ្នាំ។

**សៈ** អ៊ីចឹងការងារនីរសារដែលលោកធ្វើហ្នឹង លោកធ្វើជាក្រុម? ហើយមានគ្នាប៉ុន្មាននាក់?

**ផៈ** បាទ ព្រោះនីរសារវាមាននីរសារអនុសេនាតូច នីរសារអនុសេនាធំ បាទនីរសារវរៈ អ៊ីចឹងដែលពេលធ្វើដំណើរនាំសារម្តងៗ គេបូកនីរសារឲ្យទៅជាពួកបាទ មានគ្នាចាប់ពីបីនាក់ទៅប្រាំនាក់។

**សៈ** តើភាគច្រើនសំបុត្រដែលលោកនាំយកទៅ គឺលោកនាំពីកន្លែងណាទៅកន្លែងណា? ហើយមានអ្នកទទួលនៅកន្លែងណាខ្លះ? ហើយលោកត្រូវការនាំសំបុត្រហ្នឹងមកវិញទេ?

**ផៈ** បាទ នៅពេលជំនាន់នោះ គឺពុំមានលិខិតស្នាមកាន់នៅដៃទេ គឺរត់ទៅតាមបទបញ្ជាពីក្រោយទៅមុខ ហើយនិងពីមុខមកក្រោយ។

**សៈ** ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ព្រោះលោកបាននិយាយហើយថា លោកធ្វើនីរសារនៅក្នុងកងពលហ្នឹង។ អ៊ីចឹងបានចង់ដឹងថា តើលោកសំបុត្រហ្នឹង នាំទៅកន្លែងណាខ្លះ ដែលលោកធ្លាប់ធ្វើកន្លែងមក? លោកនៅចាំទេចាស?

**ឆ៖** បាទ នីរសារនេះជានីរសារសមរភូមិមុខ។ ដូច្នេះមានសមរភូមិក្រោយជាទីតាំងនៅប្រចាំការខាងក្រោយ ហើយសមរភូមិមុខ ដែលមាននៅឃ្នូញ អន្លង់ក្ងាន ភូមិធំ ត្រពាំងព្រាយនេះ ជាសមរភូមិជួរមុខ ដែលជាបន្ទាយខាងទាហាន ហើយខាងទ័ពយើងខ្ញុំគឺនៅទល់មុខនឹងបន្ទាយទាំងអស់នេះ។

[០៩:០៩:០៦]

**ស៖** ពេលដែលលោកយកសំបុត្រទៅដល់ តើនៅខាងអ្នកទទួលនោះ គេមានចុះហត្ថលេខាទទួលទេ? ហើយគេមានផ្ញើសំបុត្រអីមកលោកវិញទេ?

**ឆ៖** បាទនៅក្នុងសម័យនោះគឺពុំមានស៊ីញេទទួលលិខិតស្នាមទេ គ្រាន់តែយើងយកបទបញ្ជាពីក្រោយជូនទៅមុខ មុខនឹងដាក់បទបញ្ជា នាំពីមុខទៅខាងក្រោយវិញ។

**ស៖** ខ្ញុំចង់បញ្ជាក់លោកដែរថា តើបញ្ជាហ្នឹងយ៉ាងម៉េច ជាសំបុត្រ ឬក៏ជាស្អីលោក ឬក៏ជាមាត់ទទេ ឬក៏ជាអី ដែលលោកនិយាយថាបទបញ្ជាហ្នឹង?

**ឆ៖** បាទ បទបញ្ជា គឺជាបទបញ្ជាមាត់ទទេ អត់មានសារ ជាលិខិតអីទេ គឺថាបញ្ជាប៉ះមាត់និងមាត់ហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី អង្គហេតុដែលចោទប្រកាន់ គឺយុត្តាធិការ ១៧ មេសា ៧៥ ទៅមុខ ហើយអង្គហេតុដែលយើងធ្វើសវនាការនេះ គឺជម្លៀសទី១ ដែលសំខាន់ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលចោទប្រកាន់ ហើយសាក្សីទំនងជាបានដឹងគោលបំណងនៃការស្តាប់សក្ខីកម្មរូបនេះ ពាក់ព័ន្ធជាមួយនឹងជម្លៀសលើកទី១។ ហើយទី២ អង្គជំនុំជម្រះសូមរំឭកថា ពេលវេលាឥឡូវនេះអស់១០មីនុតហើយនៅសល់តែ៥០មីនុតទៀតទេ។ ដើម្បីឲ្យពេលវេលាដ៏មានតម្លៃប្រព្រឹត្តិទៅមានប្រយោជន៍ ដែលអាចផ្តុះបញ្ចាំងនៅក្នុងអង្គហេតុដែលចោទប្រកាន់ ដែលអង្គជំនុំជម្រះកំណត់មកធ្វើសវនាការ។ នេះជាការសមរម្យដើម្បីឲ្យមានប្រសិទ្ធភាពនៅក្នុងការសួរដេញដោលបាទ។

[០៩:១១:០៤]

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន ដែលបានជួយរំឭក។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោកសាក្សី តើក្រៅពីមធ្យោបាយទំនាក់ទំនងធ្វើជានីរសារ តើលោកបានធ្វើអីទៀតទេនៅ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក គង់ គីម៖**

**ឆ៖** បាទ ពីមុនដំបូងដែលខ្ញុំចូលថ្មី គេឲ្យធ្វើនីរសារដើម្បីធាតុផ្សំនៅសមរភូមិ។ ក្រោយមក គឺចូលរួមប្រយុទ្ធនៅតាមសមរភូមិជួរមុខ។

**ស៖** អរគុណលោកសាក្សី។ ម្សិលមិញលោកបានបញ្ជាក់យ៉ាងច្រើននៅចំពោះមុខព្រះរាជអាជ្ញាក៏ដូចជាអង្គជំនុំជម្រះ អំពីរចនាសម្ព័ន្ធយោធា និងការជម្លៀសប្រជាជន។ ឥឡូវខ្ញុំចង់សួរលោកថា តើអ្នកណាជាអ្នកនាំលោកចូលទ័ពហ្នឹង?

[០៩:១២:០៩]

**ឆ៖** បាទ នៅក្នុងសម័យនុំងគឺថានៅមូលដ្ឋានខាងក្រោយគឺកំណែន គឺចាប់បញ្ចូលតែម្តង។ បាទអត់មានការស្ម័គ្រចិត្តទេ គឺថាជាកំណែនទូទៅត្រូវតែចាប់បញ្ចូល ទាំងកុមារ ទាំងពេញវ័យ។

**ស៖** តើលោកមានបានហ្វឹកហ្វឺនក្បួនទ័ពទេលោក?

**ឆ៖** បាទ ពេលដែលខ្ញុំចេញមកដល់តំបន់ គេហៅថាទ័ពតំបន់ គេយកមកឈរជើងនៅកន្លែងនុំង គឺថាកន្លែងជើងព្រៃ បាននៅស្រុកជើងព្រៃនេះរយៈពេល១ខែ ការហ្វឹកហ្វឺនកងព័ទ។

**ស៖** អរគុណ។ តើនៅឆ្នាំណាដែលលោកបានទទួលតួនាទីជាប្រធានកង?

**ឆ៖** បាទ ទទួលនៅប្រធានកងក្រោយដែលបានបែក បាទបែកទីក្រុងភ្នំពេញហើយ ហើយចូលដល់ទីក្រុងភ្នំពេញ ខ្ញុំបាទនឹងទទួលឋានៈជាប្រធានកង។

[០៩:១៣:៣០]

**ស៖** អរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោករៀបរាប់បន្តិចពីរចនាសម្ព័ន្ធយោធា កាលនៅក្នុងសម័យនោះយ៉ាងម៉េចដែរលោក ចាប់ពីប្រធានក្រុមឡើងទៅ? ព្រោះលោកជាប្រធានក្រុម។ ដូច្នេះចាប់ពីប្រធានក្រុមទៅ មានអ្នកណាទៀត? អ្នកណា ឈ្មោះអី? អ្នកណាជាអ្នកដឹកនាំ? ព្រោះនេះជារចនាសម្ព័ន្ធរបស់ខាងយោធា ហើយលោកនៅយោធាស្រាប់ ដូច្នេះលោកអាចដឹងឮពីបញ្ហាហ្នឹងយ៉ាងច្បាស់។ សូមលោករៀបរាប់បន្តិចទៅចាស។

**ឆ៖** បាទ ខ្ញុំបាទ ជាប្រធានក្រុម ហើយរស់ក្រោមអនុសេនាតូចមានបីក្រុម ដែលមានដឹកនាំដោយឈ្មោះ ប៉ុន។ បីអនុសេនាតូចក្រោមការគ្រប់គ្រងរបស់អនុសេនាធំ ដែលមានឈ្មោះ រ៉េន ជាប្រធានអនុសេនាធំ។ ហើយនៅក្នុងនោះក៏រស់ក្រោមវរសេនាតូចដែរ អនុសេនាតូចគឺឈ្មោះ យឹម បាទ។

អ៊ីចឹងការរួមរស់មានប៉ុណ្ណឹង ហើយចំពោះវរសេនាធំកងពលនេះ គ្រាន់តែឮឈ្មោះ ហើយនិងដឹងលេខ តែយើងមិនបានជិតស្និទ្ធ។

[០៩:១៥:៤១]

**ស៖** តើលោកស្គាល់ឈ្មោះទេ កងវរសេនាធំ កងវរសេនាតូច កងវរសេនាតូចពិសេស លោកដឹងឈ្មោះ តើអ្នកណាជាអ្នកគ្រប់គ្រង? អ្នកណាជាអ្នកដឹកនាំក្រុមហ្នឹងចាស?

**ឆ៖** បាទ នៅក្នុងកងពលដែលចេញមកពីភូមិភាគឧត្តរដែលមានបីខេត្ត ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប។ កងពលខ្ញុំគឺមានឈ្មោះ អឿន ជាប្រធានកងពល។ ឈ្មោះ សុង ជាប្រធានវរសេនាធំ ៥៣។ ឈ្មោះ យឹម គឺវរសេនាតូច៣២។

**ស៖** ចុះអ្នកណាជាប្រធានកងវរតូចពិសេសលោក?

**ឆ៖** ប្រធានកងវរសេនាតូចពិសេស គឺខ្ញុំពុំបានដឹងទេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! ក្បាលមីក្រូហ្វូនមិនទាន់ធ្វើប្រតិបត្តិការទេ។ រង់ចាំក្បាលមីក្រូហ្វូនធ្វើប្រតិបត្តិការ សឹមលោកឆ្លើយណ៎ះ។

**លោក គង់ គីម៖**

**ឆ៖** អ៊ីចឹងគឺមួយក្នុងវរសេនាធំនេះ វាមានកងពិសេសមួយវរសេនាតូចដែលអមនៅវរសេនាធំ។ ដូច្នេះខ្ញុំមិនបានដឹងច្បាស់ថា ឈ្មោះអីជាអ្នកដឹកនាំទេ ប៉ុន្តែវរសេនាធំហ្នឹងមានថ្នាក់ដឹកនាំមួយទៀត ឈ្មោះ ចិត្ត ដែរ។ បាទ ឈ្មោះ ចិត្ត, ឈ្មោះសុង។

[០៩:១៦:២០]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើកងពលមជ្ឈិមហ្នឹង មានកងពលលេខប៉ុន្មានខ្លះចាស?

**ឆ៖** បាទ នៅកងពលមជ្ឈិមនេះ ខ្ញុំមិនបានដឹងគ្រប់កងពលទេ។ ខ្ញុំបាទដឹងតែកងពលខ្លួនដែលមានលេខ ៣១០។

**ស៖** អរគុណលោក។ ប៉ុន្តែខ្ញុំចង់សួរលោកថា តើកងពល ៣១០ហ្នឹង ស្ថិតនៅក្រោមកងពលណាលោក?

**ឆ៖** បាទ ខ្ញុំពុំអាចដឹងទេ កងពលខ្ញុំហ្នឹងមិនដឹងរស់នៅក្នុងកង -- ក្រោមកងពលណាទេ។ ព្រោះដូចខ្ញុំបានជម្រាបហើយថា ខ្ញុំស្ថិតនៅតែក្នុងក្រុមអនុសេនាតូច អនុសេនាធំនេះ បានអាចថាដឹង តែចំពោះថ្នាក់ធំៗទៅទៀត គឺពុំដឹង។

[០៩:១៧:៣២]

**ស៖** នៅមុនពេលចូលវ៉ៃភ្នំពេញ តើនៅក្នុងអង្គភាពកងទ័ពមានការបែងចែកជាបញ្ជាការដ្ឋានសមរភូមិទី១ ឬក៏បញ្ជាការដ្ឋានសមរភូមិទី២ ទេចាស?

**ឆ៖** បាទ ពេលដែលប្រយុទ្ធដែលក្ដៅដើម្បីវ៉ៃបំបែកទីក្រុងភ្នំពេញនេះ ខ្ញុំបាទពុំបានដឹងការបែងចែកអ្វីៗទាំងអស់។ ប៉ុន្តែដឹងតែការប្រជុំអប់រំគឺដើម្បីប្រមូលកម្លាំងគឺថា សម្រុកដើម្បីយកជ័យជម្នះទីចុងក្រោយនេះ។

**ស៖** ខ្ញុំចង់បញ្ជាក់សួរលោកមួយទៀតដែរ ពីវិន័យ តើវិន័យនៅក្នុងកងទ័ពយ៉ាងម៉េចដែរលោក?

**ឆ៖** បាទ នៅក្នុងសម័យកងទ័ពដែលខ្ញុំបានធ្វើនោះ វិន័យគឺគ្មានដើរទៅណាទេ គឺថាការងារគ្រប់គ្រងទ័ពគឺពេលចេញមកសមរភូមិមុខដឹងតែប្រយុទ្ធ។ ពេលដែលចេញទៅសមរភូមិក្រោយសម្រាកគឺដឹងប្រមូលផ្ដុំកម្លាំង គឺនៅនឹងកន្លែង។ អ៊ីចឹងរឿងកិច្ចការឲ្យមានថា ដឹងព័ត៌មាន ឬក៏ដើរចេញ ដើរចូលទៅណាគឺគ្មានទេសម័យហ្នឹង។

[០៩:១៩:១២]

**ស៖** ចុះចំពោះអ្នកដែលល្មើសនឹងវិន័យ តើមានវិធានការម៉េចដែរលោក?

**ឆ៖** សម័យពេលដែលប្រយុទ្ធ ដែលខ្ញុំរស់នៅឃើញថា អត់មានដែលរឿងល្មើសវិន័យអីទេ ព្រោះបញ្ជាកងទ័ពមានតែមកប្រយុទ្ធសមរភូមិមុខ ហើយនិងអ្នកទៅខាងក្រោយចាំត្រៀមដូរសមរភូមិមុខតែប៉ុណ្ណឹង។ អ៊ីចឹងរឿងការសេរី ការល្មើសអីអត់មាន។

**ស៖** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា ក្នុងនាមលោកជាកងទ័ព និងលោកជាប្រធានក្រុមសម័យនោះ តើលោកអ្នកណាជាអ្នកថ្នាក់ដឹកនាំខ្ពស់បំផុតនៃកងទ័ព?

[០៩:២០:០០]

**ឆ៖** បាទ ខ្ញុំបានជម្រាបហើយថា ខ្ញុំអត់បានដឹងទេ ថ្នាក់ដឹកនាំធំៗខាងលើ ដឹងតែត្រឹមកងពលហើយកងពលនេះ ឮតែឈ្មោះ ហើយនិងស្គាល់លេខ បាទ ដែលខ្ញុំបានដឹងច្បាស់ហ្នឹង ស្គាល់ច្បាស់ត្រឹមតែអនុសេនាធំ មកដល់ក្រុមហ្នឹងហើយ អនុសេនាតូចប៉ុណ្ណឹង។

**ស៖** ឥឡូវ ខ្ញុំសូមឆ្លងចូលទៅមួយចំណុចទៀត គឺការវាយចូលភ្នំពេញ ហើយនិងការជម្លៀស។ លោកបញ្ជាក់ពីម្សិលមិញហើយ នៅមុខអង្គជំនុំជម្រះថា មុនវាយចូលភ្នំពេញ លោកបានចូលរួមប្រជុំពីផែនការវាយចូលភ្នំពេញ។ តើអ្នកណាជាអ្នកដឹកនាំអង្គប្រជុំហ្នឹង លោក?

[០៩:២០:៥៥]

**ឆ៖** បាទ ពេលមានផែនការប្រជុំនេះគឺថ្នាក់ដឹកនាំចាប់ពីអនុសេនាតូច អនុសេនាធំ គេឡើងទៅប្រជុំថ្នាក់លើៗគេទៅ។ ពេលដែលប្រជុំមានផែនការ អនុសេនាតូចនេះ មកប្រជុំក្រុម ហើយប្រជុំដល់បណ្ដាយុវជនទាំងអស់ ដែលបញ្ជាធំៗពីលើ គឺខ្ញុំអត់ដឹង ពីណាអ្នកបញ្ជា។

**ស៖** លោកបានបញ្ជាក់ថា ការទទួលផែនការ គឺថ្នាក់ធំៗ ជាអ្នកដាក់បញ្ជា។ អ៊ីចឹង បានថាឥឡូវពេលនោះ លោកទទួលធ្វើអីខ្លះ ក្នុងផែនការហ្នឹង?

**ឆ៖** បាទ ពេលដែលទទួលបទបញ្ជាពីថ្នាក់អនុសេនាតូច អនុសេនាធំ ដែលមានបទបញ្ជាជាចុងក្រោយនេះ គឺមានតែបញ្ជាលើកកម្លាំងរួម បាទ ដើម្បីប្រយុទ្ធ គឺថាសម្រុកចូលទីក្រុងភ្នំពេញជាចុងក្រោយនេះ ឲ្យបានជោគជ័យ។ អ៊ីចឹង ពេលដែលប្រយុទ្ធចុងក្រោយនេះ គឺថាកម្លាំងបូកទាំងអស់ គឺអត់មាននៅក្រោយ នៅមុខទេ គ្រាន់តែមានចាត់តាំងកម្លាំងមួយចំនួនសម្រាប់សែងសព ហើយនិងអ្នករបួស។ បាទ អ៊ីចឹងកម្លាំង គឺថាបូកទាំងអស់ វាយចូលទីក្រុងភ្នំពេញ។

[០៩:២២:២៥]

**ស៖** អរគុណលោក។ មុនវ៉ៃចូលភ្នំពេញ តើលោកចូលទទួលមុខព្រួញណា? ហើយអ្នកណាជាមេរបស់លោក?

**ឆ៖** បាទ មុខព្រួញខ្ញុំបាទទទួលចំ ចំណុចគេហៅ អន្លង់ក្ងាន បន្ទាយភូមិធំ ដែលមានវរសេនាតូច ឈ្មោះ យឹម។ បាទ ក្នុងវរៈហ្នឹង គឺទទួលមុខព្រួញនេះដែលមាន បីអនុសេនាធំ ហើយមាន៩អនុសេនាតូច បន្ទាប់មកក្នុងមួយអនុសេនាតូច គឺមានបីក្រុមទៅទៀត។ អ៊ីចឹង កម្លាំងរួម ខ្ញុំក្ដាប់មិនបាន។

**ស៖** ក្នុងផែនការវ៉ៃចូលភ្នំពេញនេះ តើនៅក្នុងអង្គភាពរបស់លោកដែលលោកទទួលខុសត្រូវជាមួយកងវរសេនាតូចអីហ្នឹង តើមានការទទួលភារកិច្ចក្នុងការបាញ់គ្រាប់ផ្លោងចូលភ្នំពេញទេ?

**ឆ៖** បាទ បើខ្ញុំជាយុវជននៅជួរមុខ មានភារកិច្ច គឺថាជួរមុខ គឺប្រយុទ្ធផ្ទាល់ រីឯកាំភ្លើងធំខ្ញុំក្ដាប់ពុំបាន។

[០៩:២៣:៥៥]

**ស៖** ខ្ញុំចង់បញ្ជាក់សួរលោកដែរថា តើសម្ភារៈទ័ពណ៌ា គ្រឿងសព្វាវុធ ស្បៀងអីហ្នឹង អ្នកណាជាអ្នកផ្ដល់ឲ្យ? ហើយអ្នកណាជាអ្នកកាន់កាប់?

**ឆ៖** បាទ នៅស្បៀង ម្ហូបអាហារនេះ ខ្ញុំបាទ ពុំដឹងទេ។ ខ្ញុំដឹងតែ វាមានទៅដល់កន្លែងកងទ័ពគឺខ្ញុំទទួលដឹងតែត្រឹមហ្នឹង តែត្រង់អ្នកបញ្ជូនមក ថ្នាក់ណាៗ ខ្ញុំអត់ដឹង។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី ដូចជាមួយព្រឹកហើយ ២០មីនុតហើយ ២៥មីនុត ដូចមិនទាន់បានសំណួរចូលពាក់ព័ន្ធនឹងអង្គហេតុ ដែលចោទប្រកាន់ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការទាល់តែសោះ។ គួរតែតម្រង់គោលដៅក្នុងការតាំងសំណួរនេះ ឲ្យចំបញ្ហាតែម្ដង។ ហើយជាជាងការខាតបាត់បង់ពេលវេលាឥតប្រយោជន៍ ហើយគួរតែប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព។ ហើយអង្គជំនុំជម្រះសូមរំឭកមានពេល ១ម៉ោងនេះ អង្គជំនុំជម្រះមិនបន្ថែមម៉ោងឲ្យ សូម្បីតែបន្តិច ក៏មិនពន្យារឲ្យដែរ។

[០៩:២៥:១២]

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** នៅពេលដែលលោកវៃចូលភ្នំពេញ ចាស លោកទទួលភារកិច្ចមុខព្រួញណា លោកនៅក្នុងភ្នំពេញ ពេលដែលវៃឈ្នះហើយ ព្រោះម្សិលមិញលោកបានបញ្ជាក់ហើយនៅមុខសហព្រះរាជអាជ្ញា តើលោកបានទទួលបន្ទុកវៃចូលភ្នំពេញ ហើយដល់ក្រោយពីវៃឈ្នះហើយ តើលោកមានភារកិច្ចធ្វើអីទៀត?

**លោក គង់ គីម៖**

**ឆ៖** បាទ កាលដែលពេលបានជ័យជម្នះនៅទីក្រុងភ្នំពេញហើយ ខ្ញុំបាទទទួលបទបញ្ជាពីអនុសេនាធំ បាទ ទទួលខុសត្រូវតាមដងផ្លូវមួយដែលមានចេញពីវត្តភ្នំឆ្ពោះទៅស្ពានជ្រោយចង្វា អានេះគឺទទួលមួយអនុសេនាតូចដែលមានបីក្រុម គ្រប់គ្រងផ្លូវថ្នល់ហ្នឹង។ ហើយមានភារកិច្ចពេលយប់គឺយាមៗទាល់ៗព្រឹក ហើយពេលដែលយាមនេះគឺពេលយប់ មិនមានឃើញនរណាប្លែកទេ ឃើញតែថ្នាក់ដឹកនាំចាប់ពីអនុសេនាតូច អនុសេនាធំ គឺពេលយប់គេល្បី(?)អ្នកយាម។

[០៩:២៦:២៣]

**ស៖** អរគុណលោក។ នៅពេលដែលលោកឡើងឆែកឆេរ និងដេញប្រជាជនចេញពីទីក្រុង តើលោកមានជួបបាតុភាពអីខ្លះលោក? ទាំងប្រជាជន? ទាំងទាហាន? តើមានកម្លាំងអីតបតទេ ពេលនោះ?

**ឆ៖** បាទ ពេលដែលជ័យជម្នះភ្លាមនេះឃើញថា ទាំងប្រជាជននៅក្នុងក្រុងភ្នំពេញ ទាំងកងទ័ព

ខាងក្រៅ និងទាហានខាងក្នុងមានការច្របូកច្របល់គ្នា។ អ៊ីចឹងមុនដំបូងនេះគឺថា ពុំមាន -- ខ្ញុំពុំបានឡើងលើផ្ទះទេ ប៉ុន្តែមានកងដទៃដែលគេចាត់ចែង គឺថាមានការផ្សព្វផ្សាយទៅតាម -- ដាក់មីក្រូតាមឡានអីឲ្យប្រជាជនចុះពីផ្ទះថ្ម ដើម្បីគេជម្លៀសចេញបាទ។ បន្ទាប់មកក្រោយទៀតអស់រយៈពេលដែលមានការស្ងប់ស្ងាត់ ប៉ុន្តែនៅមានប្រជាជនខ្លះ ហើយនិងទាហានខ្លះដែលមាននៅក្រាញនៅតាមផ្ទះថ្មនេះ ក្រោយមកគឺថាមានការគប់គ្រាប់បែក និងការបាញ់ពីលើផ្ទះថ្មមក ប៉ះទាហានខាងក្រៅហ្នឹង -- អ៎! កងទ័ពខាងក្រៅនេះ ធ្វើឲ្យមានការប៉ះទង្គិចគ្នាជាពួកជាក្រុម ជាបន្តបន្ទាប់។

**ស៖** អរគុណលោក។ ម្សិលមិញលោកបានបញ្ជាក់ថា លោកជាអ្នកទទួលមុខព្រួញក្នុងការសម្អាតៗចុងក្រោយ ដើម្បីឲ្យប្រជាជនចេញ ហើយក្នុងបញ្ហាហ្នឹង តើលោកឲ្យប្រជាជនចេញអស់ប្រជាជនដែលចេញអស់ តើប៉ុន្មានថ្ងៃបានចេញអស់? លោកអាចប៉ាន់ស្មានបានទេចាស?

[០៩:២៨:១៤]

**ឆ៖** បាទ ប្រជាជនដែលច្រើន ដែលកំពុងតែរឹករវហ្នឹង ដែលមានការណែនណាន់តាន់តាប់ហ្នឹងរយៈពេល ៣ថ្ងៃ។ បាទ គឺក្រោមមកគឺនៅល្ហមៗ គឺរយៈកាល១អាទិត្យ ក្រោយពីអាទិត្យមកនៅកន្លះខែទៅ១ខែនេះមាននៅសល់អ្នកដែលពួនសំងំនៅតាមផ្ទះជាន់ថ្នាក់លើ ហើយមានទាហានខ្លះដែលមិនៗចុះមកទៅតាមបទបញ្ជាទៅតាមការផ្សព្វផ្សាយផងគេ។

**ស៖** អរគុណលោក។ តើក្រោយពីដែលប្រជាជនចេញអស់ តើលោកបានឃើញអ្វីខ្លះនៅក្នុងទីក្រុងភ្នំពេញ? បានឃើញទិដ្ឋភាពម៉េចខ្លះលោក?

**ឆ៖** បាទ នៅក្នុងទីក្រុងភ្នំពេញនេះ ខ្ញុំមិនបានដើរមើលគ្រប់ជ្រុងជ្រោយទេ ខ្ញុំទទួលតែភារកិច្ចនៅចំណុចដែលគេឲ្យខ្ញុំគ្រប់គ្រង។ អ៊ីចឹងចំណុចដែលខ្ញុំគ្រប់គ្រងនេះ គឺសម្អាតថ្នល់ ហើយនិងសម្អាតផ្ទះដែលយើងនៅ ក្រៅដែលផ្ទះយើងនៅនេះ យើងមិនអាចមានសិទ្ធិចូលដើរឡើងតាមផ្ទះបាន ដោយគ្មានបទបញ្ជា។

**ស៖** ពេលដែលលោកសម្អាតថ្នល់ តើលោកបានជួបប្រទះនូវសាកសពច្រើនទេនៅក្នុង -- នៅលើផ្លូវនៃទីក្រុងភ្នំពេញ? ជាពិសេសមុខព្រួញរបស់លោក?

**ឆ៖** បាទ ពេលដែលគេប្រគល់មុខសញ្ញាឲ្យខ្ញុំបោសសម្អាតនេះ គឺថាក្នុងទីក្រុងភ្នំពេញពុំមានជួបសាកសពទេ ដែលខ្ញុំបញ្ជាក់ពីមុខថាជួបសាកសព ដែលពេលសមរភូមិដែលនៅបាញ់គ្នា ចាប់ពីគីឡូលេខ៦ មកទាល់ជ្រោយចង្វានេះ គឺតាមនេះគឺមានការប៉ះទង្គិចគ្នា។ ចាប់ពីដែលគេទទួលឲ្យខ្ញុំបាន

ទទួលខុសត្រូវតាមមុខសញ្ញាក្នុងទីក្រុងភ្នំពេញ ពុំមានសាកសព។

[០៩:៣០:៣០]

**ស៖** នៅពេលដែលលោកស្ថិតនៅក្នុងទីក្រុង តើលោកដែលបានឃើញថ្នាក់ដឹកនាំណាខ្លះ នៅក្នុងទីក្រុង? លោកមានដែលជួបប្រទះអីទេចាស មានដែលឃើញ?

**ឆ៖** បាទ ពេលដែលខ្ញុំរស់នៅក្នុងទីក្រុងភ្នំពេញនេះ ខ្ញុំបាទមិនបានស្គាល់ទេ ប៉ុន្តែមានបទបញ្ជាខ្លះឲ្យការពារថ្នាក់ដឹកនាំធំៗ ហើយនឹងទូត។ ខាងបរទេសមាន កូរ៉េ មានគុយបា បាទអាហ្នឹងគឺថាឲ្យខ្ញុំទទួលខុសត្រូវតែមុខសញ្ញា ដែលខ្ញុំទទួលខុសត្រូវ នៅការពារគេ។ អ៊ីចឹងក្នុងថ្នាក់ដឹកនាំដែលដង្ហែហ្នឹងគឺថាមិនដឹងជាថ្នាក់ប៉ុនណា គឺខ្ញុំអត់ដឹង។

**ស៖** អរគុណលោក។ ខ្ញុំបកថយក្រោយបន្តិច។ ពេលដែលលោកកាន់មុខព្រួញ លោកបានបញ្ជាក់ថា លោកកាន់នៅខាងទួលគោក ខាងគីឡូលេខ៦ ខាងព្រែកព្នៅ។ ដូច្នេះពេលដែលលោកកាន់មុខព្រួញហ្នឹង ពេលដែលប្រជាជនកំពុងជម្លៀស តើនៅក្នុងឡូត៍របស់លោកដែលលោកកាន់កាប់ហ្នឹង តើមានពួកទូតទេលោក?

[០៩:៣១:៥៦]

**ឆ៖** បាទ ដែលនៅក្នុងឡូត៍នេះគឺថា និយាយតែទួលគោក គីឡូលេខ៦ គីឡូនេះអី ជាគោលដៅរបស់កងពលទេ ដោយខ្ញុំដឹងថាគោលដៅរបស់កងពលមកពីភូមិភាគឧត្តរគេទទួលអ៊ីចឹង។ តែចំពោះខ្ញុំនេះតួនាទីតូច គឺទទួលបានតែផ្លូវដែលគេកំណត់ឲ្យ គឺថាតាមនាទីរបស់យើង។

**ស៖** ពេលនោះលោកដឹងថា តើនៅស្ថានទូតបារាំងស្ថិតនៅក្នុងឡូត៍របស់លោកដែរ ស្ថិតនៅក្នុងមុខព្រួញរបស់លោកដែរឬក៏យ៉ាងម៉េចដែរលោក? ស្ថានទូតបារាំង ព្រោះនៅខាងជើងវត្តភ្នំ។

**ឆ៖** បាទ នៅវត្តភ្នំនេះការទទួលខុសត្រូវមានមួយអនុសេនាធំ។ អ៊ីចឹងអនុសេនាធំមានបីអនុសេនាតូច ហើយអ៊ីចឹងគឺថាមួយអនុសេនាតូច និងមួយអនុសេនាតូចមួយទទួលខុសត្រូវដាច់ឡែកពីគ្នា។ អ៊ីចឹងកាទូតនេះ យើងខ្ញុំមិនបានដឹងការទូតបារាំងនៅកន្លែងណាទេ បើទូតគុយបា ខ្ញុំដឹងថានៅខាងជើងឆៀងខាងកើតវត្តភ្នំ ហើយកូរ៉េនៅខាងជើងពេទ្យព្រះកេតុមាលា។ ហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៣៣:២៧]

**ស៖** តើចំពោះទូតដែលនៅក្នុងមុខព្រួញហ្នឹង ដូចទូតគុយបា ទូតកូរ៉េ លោកមានបានឃើញ តើមានភាពជ្រួលប្រចល់ ឬមានគោលការណ៍ម៉េចដែរទេចាស?

**ឆ៖** បាទ នៅក្នុងសម័យនុ៎ងឃើញថា ភ្នំពេញពុំមានការឈ្លូតរអ៊ីចឹងទេ គឺថាមានការស្ងប់ស្ងាត់។ អ៊ីចឹងផ្លូវណាដែលគេត្រឹមត្រូវ ផ្លូវហ្នឹងអាចមានមនុស្ស មានឡាន ផ្លូវណាដែលមិនត្រឹមត្រូវ ផ្លូវនោះគឺស្ងាត់។ បាទអ៊ីចឹងកន្លែងទូត គឺភារកិច្ចយើងខ្ញុំ គ្រាន់តែការពារខាងផ្លូវ រឿងផ្ទះទូតផ្ទះអី គេមានភារកិច្ច ឯកងទ័ពដែលការចាត់ចែងរបស់ថ្នាក់លើដោយឡែក។

**ស៖** ខ្ញុំចង់បញ្ជាក់លោកម្តងទៀតដែរ ពីបញ្ហាជម្លៀសហ្នឹងដដែល។ គឺប្រជាជនដែលគេជម្លៀស តើផែនការរបស់ថ្នាក់លើហ្នឹង គឺតម្រូវឲ្យគេទៅទីណាខ្លះ? ហើយមុខព្រួញណាខ្លះក្នុងពេលជម្លៀសហ្នឹង? ហើយអ្នកណាទទួលមុខព្រួញនីមួយៗហ្នឹង?

**ឆ៖** បាទ ពេលដែលជម្លៀសប្រជាជននេះ គឺខ្ញុំបាទពុំដឹងថាមុខព្រួញទៅខាងណាទេ។ ភារកិច្ចខ្ញុំបាទជាកងទ័ពចូលនៅសមរភូមិចូលក្នុងទីក្រុងភ្នំពេញនេះ ដឹងតែដេញបញ្ចេញឲ្យទៅក្រៅតែប៉ុណ្ណឹង។ រឿងទិសដៅទៅខាងណាខ្ញុំអត់ដឹងទេ។

**ស៖** នៅក្នុងករណីជម្លៀសនេះដែរ តើលោកមានក្តាប់បានទេពីផែនការអំពាវនាវប្រមូលគេឲ្យមកវិញ ឧទាហរណ៍ដូចមន្ត្រីរាជការខ្លះប្រមូលឲ្យមកវិញ អ្នកបច្ចេកទេស ដើម្បីជួយរៀបចំប្រទេសជាតិ ហើយនិងជួយសម្អាតទីក្រុង? លោកមានដឹងពីផែនការហ្នឹងទេ?

**ឆ៖** បាទ នៅក្នុងអង្គភាពកងទ័ពខ្ញុំគឺថា ផែនការនេះពុំដែលដឹង ហើយក៏ពុំដែលឃើញប្រមូលកម្លាំងដែលបានជម្លៀសទៅហើយ មកពូនផ្តុំនៅកន្លែងអង្គភាព គឺថាពុំដែលឃើញ។

[០៩:៣៦:២១]

**ស៖** លោកសាក្សី តើលោក -- ក្នុងពេលដែលលោកបម្រើក្នុងកងទ័ព លោកអាចបញ្ជាក់ប្រាប់បានទេ តើមេកោយរបស់លោកអ្នកណាខ្លះ? ហើយក្រៅពីមេកោយហ្នឹង តើលោកមានដែលដឹងឮពីឈ្មោះថ្នាក់ដឹកនាំណាផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំបាទគ្រាន់តែឮឈ្មោះ ហើយក៏មិនដែលឃើញ ហើយក៏មិនដែលជួប តែឈ្មោះតាំងពីយើងនៅក្នុងព្រៃ ដើម្បីវាយចូលទីក្រុងភ្នំពេញ គឺថាឮតែឈ្មោះ គឺថាលោក ខៀវ សំផន ជាអ្នកដឹកនាំ។

**ស៖** អរគុណលោក។ ពីម្សិលមិញលោកបានបញ្ជាក់នៅមុខអង្គជំនុំជម្រះថាលោកជាឆ្មាំគុកនៅជិតវត្តភ្នំ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថាតើគុកហ្នឹងស្ថិតនៅកន្លែងណាពិតប្រាកដ? នៅម្តុំណាលោក?

**ឆ៖** បាទ គុកនេះនៅខាងកើតឆៀងខាងត្បូងវត្តភ្នំបាទ។

**ស៖** ហើយឥឡូវនេះនៅប្រហែលកន្លែងណាឥឡូវនេះ? ប្រហែលម្តុំណាចាស?

**ឆ៖** បាទ ខ្ញុំមិនអាចស្គាល់ឈ្មោះទេ តែបើសិនជានាំខ្ញុំទៅបង្ហាញ ខ្ញុំចង្អុលបង្ហាញ។ តែឲ្យដឹងថាឈ្មោះនោះវាឈ្មោះស្អី ខ្ញុំអត់ដឹង។

**ស៖** នៅជិតកន្លែងវ៉ាទេលោក នៅជិតវ៉ារទេះភ្លើងទេ? នៅខាងកើតវ៉ារទេះភ្លើងមែនទេ?

**ឆ៖** មិនមែនជិតវ៉ាទេ ព្រោះវានៅខាងកើតវត្តភ្នំឯណោះ។ បាទ ខាងកើតហើយឆៀងខាងត្បូងបាទ។

**ស៖** អរគុណលោក។ ក្នុងពេលដែលលោកនៅជាឆ្មាំគុក តើលោកដែលឃើញថ្នាក់ដឹកនាំណាដែលឧស្សាហ៍ចុះឡើងមកញឹកញាប់ជាងគេ នៅកន្លែងគុកហ្នឹង?

[០៩:៣៩:០០]

**ឆ៖** ពេលដែលខ្ញុំចូលការពារនៅគុកនោះ ថ្នាក់ដឹកនាំដែលចូលទៅពង្រឹងគឺថា អត់មានអ្នកណាក្រៅពីអនុសេនាតូច អនុសេនាធំ ដែលជាអ្នកគ្រប់គ្រងខ្ញុំផ្ទាល់។ តែដោយឡែកគឺមានថ្នាក់ដឹកនាំផ្សេងៗដែលខ្ញុំពុំអាចស្គាល់ ហើយគេចូលទៅធ្វើការងារផ្ទៃក្នុងខាងសួរចម្លើយ ខាងចាប់ ខាងនាំអី ហ្នឹងជារឿងគេផ្សេង ហើយខ្ញុំអត់ស្គាល់។

**ស៖** អរគុណលោក។ ក្រោយពីការចាប់មេរបស់លោក ដែលមានឈ្មោះ--

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូនសិន!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ក្រោយពីការចាប់មេរបស់លោក ដែលមានឈ្មោះអឿន ឈ្មោះសុង ឈ្មោះយឹម ឈ្មោះផូមក តើលោក -- តើអ្នកណាដែលមកជំនួសគាត់?

**លោក គង់ គឹម៖**

**ឆ៖** ពេល ដល់ពេលដែលគេចាប់ថ្នាក់ដឹកនាំនៅក្នុងអង្គភាពយើងខ្ញុំ ពេលនោះហើយ គឺគេដកខ្ញុំចេញដែរបាទ។ ពេលដែលឃើញមេៗគេចាប់មក ពេលនោះគេដកខ្ញុំហើយ គេបានបញ្ជូនខ្ញុំទៅខេត្តកំពង់ឆ្នាំង។

**ស៖** លោកមានក្តាប់បានទេ តើថាតើពួកណាដែលមកជំនួសមេរបស់លោកហ្នឹង? ពួកខាងណាពួកភូមិភាគណា លោកមានដឹងទេចាស?

**ឆ៖** បាទ ពេលនោះ គឺខ្ញុំដាច់រយៈពីកន្លែងការពារគុកហ្នឹងហើយ គឺខ្ញុំដូចបានជម្រាបហើយថា គេបញ្ជូនខ្ញុំទៅខេត្តកំពង់ឆ្នាំងបាត់ហើយ។

[០៩:៤០:៥០]

**ស៖** អរគុណលោក។ តើអ្នកដែលបញ្ជូនលោកទៅខេត្តកំពង់ឆ្នាំងហ្នឹងជាពួកខាងណា? លោកមានដឹងទេ?

**ឆ៖** បាទ ខ្ញុំបាទមិនបានដឹងថា ថ្នាក់ណាជាអ្នកបញ្ជូនទៅទេ ប៉ុន្តែក្នុងពេលនោះគឺមានតែថ្នាក់ក្រុម អនុសេនាតូចដែលប្រមូលគេខ្លួនទាំងអស់គ្នាថា អង្គការប្រមូលកងទ័ពយើងដែលនៅសល់ហ្នឹង អត់មេហ្នឹង គេឲ្យទៅធ្វើព្រលាននៅកំពង់ឆ្នាំង។

**ស៖** អរគុណលោក។ លោកជាឆ្មាំគុក តើនៅក្នុងការយាមគុកហ្នឹង លោកដែលជួបប្រទះការលួចរត់របស់អ្នកទោសទេ លោក?

**ឆ៖** បាទ ពេលដែលយាមគុកនេះ ខ្ញុំពុំដែលបានឃើញអ្នកគុករត់រួចទេ តែក្នុងបទបញ្ជាអ្នកដែលយាមនេះ កំណត់ថាបើសិនជាអ្នកគុករត់ចេញ គឺត្រូវបាញ់។ បាទ បើចាប់មិនបាន ត្រូវបាញ់ ហើយបើយើងបាញ់មិនបាន ចាប់មិនបាន យើងអ្នកយាមហ្នឹងគឺត្រូវចូលជំនួសអ្នកដែលគេរត់ចេញ។ ប៉ុន្តែពេលដែលខ្ញុំយាមនោះ ពុំដែលមានរត់ចេញរួចទេ។

**ស៖** សូមអរគុណលោក។

**លោកស្រី ជេត វណ្ណលី៖**

ដោយពេលវេលាមានកំណត់ គឺថាខ្ញុំសូមឲ្យខាងសហភាតាអន្តរជាតិបន្តសំណួរតទៀត។ សូមអរគុណ។

[០៩:៤២:២៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! ហើយមេធាវីក្រុមនេះនៅមានពេលវេលា២០នាទីទៀត។

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី គង់ គីម ខ្ញុំឈ្មោះ បេនី យេ ខ្ញុំជាមេធាវីដើមបណ្តឹង

រដ្ឋប្បវេណីអន្តរជាតិ ហើយខ្ញុំនឹងសួរសំណួរមួយចំនួននៅក្នុងសម័យកាលបន្ទាប់ពីភ្នំពេញដួលរលំទៅ។ ម្សិលមិញ លោកបាននិយាយថា បន្ទាប់ពីភ្នំពេញបានដួលរលំ លោកបានក្លាយទៅជាប្រធានកង។ តើក្នុងឋានៈជាប្រធានកង តើលោកត្រូវរាយការណ៍អំពីសកម្មភាពរបស់ក្រុមរបស់កងរបស់លោកដែរឬទេ?

[០៩:៤៣:២៧]

**លោក គង់ គឹម៖**

**ឆ៖** បាទ ក្រោយពីបែកភ្នំពេញ ជម្លៀសប្រជាជនផុតអស់ ខ្ញុំបាទទទួលជាក្រុមបាទ មានចំនួនយុវជនក្រោម គឺ១២នាក់។ អ៊ីចឹងកិច្ចការដែលរាយការណ៍ជាប្រចាំនោះ ពុំមានសភាពការណ៍អីដែលត្រូវរាយការណ៍ទេ ព្រោះទីក្រុងភ្នំពេញមានការស្ងប់ស្ងាត់។ សំខាន់គឺយាមទាំងយប់ យាមទាំងថ្ងៃ គឺការពារដែលបទបញ្ជាពីលើថា ការពារខ្លាំង។ អ៊ីចឹងពេលដែលខ្ញុំយាមនេះ ពេលយប់យាមទាល់ៗព្រឹកនេះ ពុំដែលឃើញសកម្មភាពអីឈ្លូសរ មានតែថ្នាក់ដឹកនាំចាប់ពីអនុសេនាតូច អនុសេនាធំ ដែលគេល្បី(?)អ្នកយាមតែប៉ុណ្ណឹង។

**ស៖** ហើយនៅពេលដែលលោកឆែកឆេររកមនុស្សដែលនៅសល់នៅក្នុងភ្នំពេញ តើត្រូវ លោកត្រូវរាយការណ៍អំពីបញ្ហានេះដែរឬទេ?

**ឆ៖** បាទ ពេលដែលយើងទទួលតាមមុខព្រួញហើយ បើសិនជាយើងឆែកឆេរទៅតាមផ្ទះជួបប្រជាពលរដ្ឋដែលគាត់រស់នោះ បើយើងយកគាត់បាន គឺអាហ្នឹងរាយការណ៍ទៅតាមថ្នាក់ដែលពីលើៗយើង ដូចជាអនុសេនាតូច អនុសេនាធំ។ ដូចខ្ញុំជម្រាបហើយថា កម្រិតដែលខ្ញុំអាចដឹងបាន ដឹងបានពីអនុសេនាតូច អនុសេនាធំ សូម្បីជាវរសេនាតូចនេះ ពុំសូវបានជួបផង។

[០៩:៤៥:០០]

**ស៖** តើលោកដឹងថាតើប្រធានអនុសេនាតូច ឬក៏ប្រធានកងអនុសេនាធំហ្នឹងឈ្មោះអ្វីដែរ ដែលលោករាយការណ៍ទៅឲ្យពួកគាត់នោះ?

**ឆ៖** បាទ ប្រធានអនុសេនាធំ គឺឈ្មោះ រ៉េន ហើយអនុសេនាតូចខ្ញុំផ្ទាល់នេះឈ្មោះ ប៊ុន ក្រោមការដឹកនាំរបស់វរសេនាតូចមានឈ្មោះ យឹម បាទ។

**ស៖** តើអ្នកទាំងអស់នោះធ្វើការចាត់វិធានការដូចម្តេច នៅពេលដែលលោករាយការណ៍អំពីថាមានប្រជាជន ឬក៏មិនមានដែលនៅសល់នៅក្នុងភ្នំពេញក្រោយពីជម្លៀសនោះ?

**ឆ៖** បាទ ក្តាប់អត់បានសូមលោកសួរម្តងទៀត។

[០៩:៤៦:២៦]

**ស៖** នៅពេលដែលលោករាយការណ៍ទៅ រ៉េន ឬ ប៉ុន អំពីសកម្មភាពរបស់លោក អំពីកងរបស់លោក តើគាត់ប្រាប់មកលោកវិញដូចម្តេច? ហើយឬគាត់ចាត់ការដូចម្តេចបន្ទាប់ពីទទួលរបាយការណ៍ពីលោកនោះ?

**ឆ៖** បាទ នៅពេលប្រតិបត្តិការនៅតាមចំណុចគោលដៅដែលគេប្រគល់ឲ្យនេះ គឺយើងទទួលផែនការថា ឲ្យយើងឡើងបោសសម្អាតទៅតាមមុខព្រួញដែលយើង -- គេ យើងត្រួតពិនិត្យ។ អ៊ីចឹងបើសិនជាមានប្រជាពលរដ្ឋដែលនៅសល់ យើងយកគាត់បានពីលើផ្ទះ គឺយើងនាំគាត់ផ្ទាល់ទៅជូនដល់អនុសេនាធំ។ បាទយើងពុំដឹងថា ផែនការដែលគេយកហើយ គេបញ្ជូនទៅតាមរយៈណាទៀតយើងអត់ដឹង។ ដោយឡែកគឺថា សម័យនុ៎ងគឺមួយអនុសេនាធំនេះ គឺមានអនុសេនាតូចបី ហើយមានបីក្រុមទៅទៀត។

[០៩:៤៧:២១]

អ៊ីចឹងយើងមិនអាចដឹងទូលំទូលាយទេ យើងដឹងតែមុខព្រួញយើង។ មុខព្រួយយើង ក្រុមឲ្យដឹងតែតួនាទីក្រុម ទទួលខុសត្រូវចំណុចដែលក្រុមទទួលខុសត្រូវតែប៉ុណ្ណឹង។ ក្រុមគេ គេទទួលខុសត្រូវ កងគេ គេទទួលខុសត្រូវ។ អ៊ីចឹងការទទួលខុសត្រូវដាច់ដោយឡែកគ្នា គឺថាមិនអាចដឹងគ្នាទៅវិញទៅមកទេបាទ។

**ស៖** តើលោកដែលដឹងដែរឬទេថា អង្គភាពផ្សេងត្រូវធ្វើរបាយការណ៍ដូចដែលលោករាយការណ៍អ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំពុំអាចដឹងទេ។ ខ្ញុំអាចដឹងតែត្រឹមអនុសេនាតូច ព្រោះពេលវេលាដែលប្រជុំរួមហ្នឹងមានតែប្រជុំអនុសេនាតូច។ អ៊ីចឹងក្នុងការងារអនុសេនាធំ គឺថាមិនដែលបានប្រជុំគ្នាទទួលផ្នែកការរួមទេ។ ខ្ញុំទទួលតែពីបទបញ្ជាអនុសេនាតូចបីក្រុមដែលទទួលតាមមុខសញ្ញាដែលគេប្រគល់ឲ្យ ហើយនិងទទួលខុសត្រូវតាមមុខសញ្ញាក្រុមរៀងៗខ្លួន។

[០៩:៤៨:៤៣]

**ស៖** ហើយនៅក្នុងពេលប្រជុំជាមួយអនុសេនាតូចដែលថាមានកងទាំងបី តើកងទាំងបីហ្នឹងជាសមាជិករបស់អនុសេនាតូចនេះចូលរួមទាំងអស់? តើមែនឬទេ?

**ឆ៖** បាទ ពេលដែលអនុសេនាតូច គាត់ទទួលបានបទបញ្ជាពីអនុសេនាធំមក គាត់យកមកប្រជុំយុវជនទាំងអស់នៅក្នុងអនុសេនាតូចគាត់ គឺថាមានការប្រជុំរួម។ ហើយផែនការដែលដាក់ហ្នឹងគឺគ្មានអ្វីក្រៅពីការពារ បាទឱ្យបានមួយរយភាគរយ គឺថាយាមទាំងយប់យាមទាំងថ្ងៃ ហើយនិងបោសសម្អាតអ្នកដែលសេសសល់ គឺថាប្រមូលឱ្យអស់។ អ៊ីចឹងផែនការ អត់មានផែនការអីក្រៅពីការសម្អាត ហើយនិងការជម្លៀសប្រជាពលរដ្ឋដែលនៅសេសសល់ នៅតាមមុខព្រួញ។ ផែនការមានតែប៉ុណ្ណឹងកងទ័ព។

[០៩:៤៩:៤២]

**ស៖** ពីម្សិលមិញលោកនិយាយថា អនុសេនាតូច ប្រធានអនុសេនាតូចរបស់លោកបង្គាប់ ឬបញ្ជាឱ្យប្រជាជនចេញឱ្យអស់ពីភ្នំពេញ។ អ្នកដែលសេសសល់ គឺថាមានបញ្ជាពីលើមក ពីកងពលមក។ តើលោកដឹងថា កងពលនោះជាអ្នកណាទេ?

**ឆ៖** បាទ កងពលនេះ ដែលខ្ញុំបានឮឈ្មោះហើយ ដឹងលេខកងពល៣១០នេះ ហើយឈ្មោះកងពលនេះ ឈ្មោះ អឿន នេះ បាទ ជាកងពលរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបានដែលជួបគាត់ផ្ទាល់ទេ ព្រោះបទបញ្ជានេះ គាត់ដាក់មកតំណាតផ្ដាក់មកដល់អនុសេនាធំ អនុសេនាតូចមក អនុសេនាតូចមកដាក់ឱ្យខ្ញុំមក ខ្ញុំបានទទួលផ្ទាល់ពីអនុសេនាតូច។

[០៩:៥០:៤០]

**ស៖** តើលោកដឹងដែរឬទេ អឿន ជាមេបញ្ជាកងពលនោះ ថាតើ អឿន នោះ ទទួលបញ្ជាមកពីណាដែរ?

**ឆ៖** បាទ ខ្ញុំពុំអាចដឹងទេ ព្រោះថ្នាក់ខ្ញុំវាតូចពេក នៅប្រធានក្រុមនោះ ក្រោមគេតូចណាស់ ហើយសម័យនោះ ពុំមានភាពសេរីដើរទៅណាបានទេ គឺថាទទួលខុសត្រូវកន្លែងណា គឺកន្លែងហ្នឹង។

**ស៖** ពីម្សិលមិញ លោកបាននិយាយថា បន្ទាប់ពីការរួលរលំភ្នំពេញ គឺកងពលរបស់លោកបានមកដល់ទីក្រុង ហើយលោកជាផ្នែករបស់មជ្ឈិម។ តើមុនមកដល់ភ្នំពេញ លោកនៅក្នុងកង ឬក៏ក្រុមស្ថិតនៅក្នុងផ្នែកណា ដែលថាមកដល់ភ្នំពេញបានជាផ្នែករបស់មជ្ឈិម?

**ឆ៖** បាទ នៅក្នុងអង្គភាពដែលមុនវៃចូលទីក្រុងភ្នំពេញនេះ កងទ័ព គេបែងចែកជាតាមភូមិភាគ បាទ គេហៅថា ទ័ពភូមិភាគ។ ដូចខ្ញុំជម្រាបហើយថា ភូមិភាគឧត្តរ មានកំពង់ចាម កំពង់ធំ សៀមរាប។ ក្រោយដែលយើងរំដោះភ្នំពេញ គេយកទ័ពនេះ ប្រមូលប្លុកជាទ័ពមជ្ឈិម បាទ។ នេះ ខ្ញុំអាចដឹងប៉ុណ្ណឹង។

[០៩:៥២:២៨]

**ស៖** តើភាពខុសគ្នា ដែលថាជាទ័ពរបស់មជ្ឈិម ហើយនិងទ័ពរបស់ភូមិភាគហ្នឹង ខុសគ្នាដូចម្ដេច?

**ឆ៖** បាទ រីឯកងទ័ពហ្នឹង អង្កាល់សម័យនុំង គេមានកងទ័ពតំបន់ការពារ វ៉ៃចូលខេត្ត។ កងទ័ពភូមិភាគ គឺថាវ៉ៃចូលភ្នំពេញ។ អ៊ីចឹងពេលដែលផ្ដាច់ចេញពីភូមិភាគមកចូលមជ្ឈិមនេះ គឺថាកងទ័ពតែមួយ មនុស្សដដែល ហើយរបៀបរបបតែមួយ គឺគ្រាន់តែបញ្ចូលឈ្មោះជាមជ្ឈិម។

**ស៖** នៅពេលដែលលោកក្លាយជាកងទ័ពរបស់មជ្ឈិម តើគេប្ដូរភារកិច្ចការងារ ឬក៏ខ្សែបញ្ជា ឬក៏បុគ្គលិក បានន័យថា យោធាមានផ្លាស់ប្ដូរអ្វីដែរទេ?

**ឆ៖** បាទ នៅក្នុងសម័យនោះ គឺថាកងទ័ព ដែលពេលយើងចងក្រងមុនបែកភ្នំពេញ ក៏ដូចជាពេលបែកភ្នំពេញ គឺថាកងទ័ព អត់មានបញ្ចូលថ្មី ឬក៏កាត់ចោល គឺអត់មាន។ រក្សាកងទ័ពដែលនៅរស់ដែលចូលទីក្រុងភ្នំពេញទាំងប៉ុន្មាន គឺមានប៉ុណ្ណឹង។ អត់រើសថែម ក៏អត់មានកាត់ចេញ គឺរក្សាចំនួនដែលបាននៅសល់។

[០៩:៥៤:០៧]

**ស៖** ឥឡូវនេះ សំណួរចុងក្រោយរបស់ខ្ញុំ គឺសំណួរបន្តពីអ្វីដែលលោកបាននិយាយព្រឹកមិញនេះ លោកនិយាយថា លោកបានបោសសម្អាតចេញ ដែលថាបោសសម្អាតចេញពីផ្ទះនីមួយៗនោះ តើមានន័យដូចម្ដេច ពេលដែលលោកនិយាយពាក្យនេះ?

**ឆ៖** បាទ ពាក្យថា “បោសសម្អាត” ព្រឹកមិញនេះ ខ្ញុំនិយាយថា ទទួលខុសត្រូវបោសសម្អាតតាមដងផ្លូវនេះ គឺសម្អាតអនាម័យ ដែលយើងទទួលហ្នឹង ឲ្យផ្លូវផ្ដានុំង ឲ្យវាសម្អាត។ អ៊ីចឹងផ្លូវណាដែលយើងអត់ទទួលខុសត្រូវ គឺយើងមិនអាចទៅទេ។ អ៊ីចឹង គឺថាសម្អាតតែផ្លូវដែលយើងទទួលខុសត្រូវនេះ។ ពាក្យដែលថា សម្អាតនេះ ខ្ញុំសម្អាតតាមផ្លាផ្លូវដែលទទួលខុសត្រូវ សម្រាប់ភ្ញៀវដែលមានភ្ញៀវថ្នាក់ធំៗ ឬក៏ទូតអីគេចេញចូល ឲ្យវាមានការសម្អាតតាមដងផ្លូវថ្នល់ប៉ុណ្ណឹង។

[០៩:៥៥:១៥]

**ស៖** តើខ្ញុំយល់ត្រូវដែរឬទេ តើលោកសម្អាតក្នុងផ្ទះ ឬក៏នៅក្រៅផ្ទះ សូមលោកបញ្ជាក់?

**ឆ៖** បាទ ពេលដែលទទួលខុសត្រូវតាមមុខសញ្ញានេះ គឺយើងមានសិទ្ធិសម្អាតតែតាមថ្នល់បាទ ថ្នល់ដែលគេប្រគល់ឲ្យសម្អាត។ រីឯតាមផ្ទះហ្នឹង យើងគ្មានសិទ្ធិចូលតាមផ្ទះគ្រប់ផ្ទះទេ តែផ្ទះណាគេឲ្យ

យើងរស់នៅ យើងសម្អាតបានតែផ្ទះមួយហ្នឹង។

**លោកស្រី បេនី យេះ៖**

សូមអរគុណលោកសាក្សី គង់ គីម។ ហើយខ្ញុំមិនមានសំណួរអ្វីសួរទេ។ សូមឲ្យលោកធ្វើដំណើរត្រឡប់ទៅលំនៅដ្ឋានវិញដោយសុវត្ថិភាព។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរសាក្សីរូបនេះទេ?

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:៥៦:៣១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរទៅសាក្សី។ ជម្រាបសួរលោក គង់ គីម ខ្ញុំជាចៅក្រម ឡាវែន៍ ខ្ញុំចង់សួរសំណួរមួយចំនួនទៅកាន់លោក។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជាដំបូងលោកបានពន្យល់ថា មុនចូលដល់ទីក្រុងភ្នំពេញ លោកធ្វើជានីរសារ បន្ទាប់មកធ្វើជាទាហាន។ ខ្ញុំចង់ដឹងថានៅក្នុងសកម្មភាពរបស់លោកមុនពេលវាយយកទីក្រុងភ្នំពេញ តើលោកបានចូលរួម ឬក៏បានដឹងអំពីការវាយយកក្រុងផ្សេងទៀតទេ មុនចូលភ្នំពេញនោះ? ឧទាហរណ៍ដូចជាលោកដឹងអំពីការវាយយកទីក្រុងក្រចេះ ក្រុងឧដុង្គ ឬក៏ក្រុងផ្សេងៗទៀត មុននឹងវាយយកទីក្រុងភ្នំពេញដែរឬទេ?

**លោក គង់ គីម៖**

**ឆ៖** បាទ ខ្ញុំបានទទួលផែនការមុនវាយចូលទីក្រុងភ្នំពេញនេះ មិនអាចដឹងពីសមរភូមិផ្សេងៗ ហើយមិនអាចដឹងពីមុខសញ្ញាដែលគេប្រគល់ឲ្យទេ ព្រោះប្ដេជ្ញាយកជោគជ័យតែមុខព្រួញដែលគេឲ្យយើងវាយ តែមុខសញ្ញាផ្សេងៗជាតួនាទីរបស់កងទ័ពដោយឡែកៗពីគ្នា។ អ៊ីចឹងខ្ញុំប្រឹងគឺថាក្នុងអង្គភាពខ្លួនដែលគេប្រគល់ឲ្យមុខសញ្ញាបន្ទាយណា គឺបុកតាមតែមុខសញ្ញាដែលគេប្រគល់ឲ្យ។

[០៩:៥៨:០៦]

**ស៖** លោកបានពន្យល់ថា លោកមិនដឹងអំពីផែនការជម្លៀសទីក្រុងភ្នំពេញមុនពេលវាយយកភ្នំពេញទេ ក៏ប៉ុន្តែលោកអាចបញ្ជាក់បានទេថា តើបញ្ជានេះចេញមកភ្លាមៗក្រោយពីការវាយយកទីក្រុងភ្នំពេញមែនទេ? ហើយគេមានផ្តល់ពីមូលហេតុ -- បញ្ជាក់អំពីមូលហេតុ អំពីការជម្លៀសនេះទេ?

**ឆ៖** បាទ ពេលដែលវាយចូលទីក្រុងភ្នំពេញនេះ នៅពេលដែលកំពុងតែវាយខ្លាំងគឺថា យើងមិនអាច -- មិនបានទទួលផែនការពីថ្នាក់លើថា ជាបញ្ជាចូលដល់ទីក្រុងភ្នំពេញជម្លៀសប្រជាជនអី គឺខ្ញុំអត់ក្តាប់បានទេ គឺខ្ញុំអត់មានទទួលបានបទបញ្ជានោះទេ។ បទបញ្ជាទទួលធ្វើម៉េចឲ្យយកជោគជ័យ ហើយចូលទៅតាមមុខព្រួញៗ ដែលថ្នាក់ដឹកនាំតូចៗដែលនៅពីលើយើងនេះ គេចង្អុលឲ្យយើងចូលទៅតាមច្រកដែលជាមុខព្រួញដែលយើងទទួលខុសត្រូវ។ លុះដល់បែកភ្នំពេញហើយ បានយើងខ្ញុំឃើញនឹងភ្នែកឃើញថាប្រជាពលរដ្ឋហ្នឹងមានការជម្លៀស អ៊ីចឹងជាផែនការមុន គឺខ្ញុំអត់បានទទួលទេ។

**ស៖** ចំពោះលោកផ្ទាល់ តើនៅពេលណាដែលលោកដឹងថាមានការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏លោកដឹងនៅពេលដែលលោកឃើញប្រជាជនចេញ ឬក៏មានការចេញបញ្ជាឲ្យជម្លៀស? ហើយនៅពេលណាដែលមានការចេញបញ្ជាបែបនេះ?

**ឆ៖** បាទ ពេលដែលចូលដល់ទីក្រុងភ្នំពេញដែលខ្ញុំដឹងថា មានផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ គឺខ្ញុំចូលទៅកាន់គោលដៅដែលគេឲ្យខ្ញុំឈរជើង។ បាទ ដូច្នេះមានក្រុមនេះឈរជើងចំណុចនេះ ក្រុមនេះឈរជើងចំណុចនេះ ពេលដែលឈរជើងហើយ គេឲ្យយើងត្រួតពិនិត្យនៅក្នុងរង្វង់ដែលយើងឈរជើងនេះ ចំពោះប្រជាជន គឺគេដាក់ផែនការឲ្យជួយជម្លៀសប្រជាជនដែលស្ថិតនៅក្នុងការគ្រប់គ្រងឡូត៍យើងហ្នឹង។

[១០:០០:៣៩]

**ស៖** នៅពេលនោះក្នុងនាមលោកទាហាន តើគេមានពន្យល់មូលហេតុទេ ហេតុថាហេតុអ្វីបានជាត្រូវធ្វើការជម្លៀសប្រជាជននោះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថា ការដែលផែនការជម្លៀសប្រជាពលរដ្ឋនេះ ពីមុនមកខ្ញុំអត់ដឹង ហើយពេលដែលដឹងនេះ ដឹងតែឲ្យជម្លៀសចេញពីទីក្រុងភ្នំពេញ តែមូលហេតុរបស់ថ្នាក់លើ គឺយ៉ាងណាៗ ខ្ញុំអត់ដឹងទេ។

**ស៖** លោកបានឆ្លើយថា លោកបានសង្កេតឃើញថា គេផ្សាយសារតាមមីក្រូ ដើម្បីឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ។ តើលោកអាចប្រាប់បានទេថា នៅក្នុងសារនោះគេនិយាយអ្វីខ្លះទៅដល់

ប្រជាជន? ហើយវាមានខ្លឹមសារយ៉ាងម៉េច? ហើយសម្ភារៈដែលប្រើប្រាស់សម្រាប់ផ្សព្វផ្សាយសារនោះជារបស់អ្នកណា? ជាសម្ភារៈរបស់កងពលធំ ឬក៏ជាសម្ភារៈដែលមកពីអង្គភាពយោធាណាមួយផ្សេងទៀត?

[១០:០២:០៩]

**ឆ៖** បាទ នៅពេលនុ៎ងគឺខ្ញុំក្តាប់ការដែលជម្លៀសប្រជាជន គឺថាក្តាប់ន័យមិនបានអស់។ ប៉ុន្តែគឺថាគ្រាន់តែឃើញ ហើយនិងដឹងថាមានកងគេដោយឡែក បាទកងនោះគេហៅថា កងចល័ត។ អ៊ីចឹងចំណែកខ្ញុំនេះគ្រាន់តែឈរជើងកំណត់កន្លែងណានៅកន្លែងហ្នឹង។ អ៊ីចឹងកងចល័តដែលគេដើរផ្សព្វផ្សាយចាក់មីក្រូហ្នឹង គេផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋចាកចេញពីទីក្រុងភ្នំពេញ ដើម្បីគេយកទីក្រុងភ្នំពេញនេះរៀបចំ។ បាទ គ្រាន់តែដឹងតែប៉ុណ្ណឹងជាខ្លឹមសារ។ ហើយពេលដែលបែកភ្នំពេញនេះមានការច្របូកច្របល់ណាស់ ដូចខ្ញុំជម្រាបហើយ ថាទាំងកងទ័ពខាងក្រៅ កងទ័ពទាហានខាងក្នុង ទាំងប្រជាជនអ៊ីចឹងមានការដែលគាត់នៅត្រើយចុះមកតាមថ្នល់ វាមានការលំបាក មនុស្សច្រើនអ៊ីចឹង។ ចំណែកខ្ញុំជាកងទ័ពហ្នឹង ដែលទទួលបទបញ្ជាឈរត្រង់ណាហើយ ទី១គ្រប់គ្រងកម្លាំង រក្សាដើម្បីកុំឲ្យមានគ្រោះថ្នាក់។ បាទគិតតែប៉ុណ្ណឹង។

**ស៖** តើលោកស្តាប់ឮដោយខ្លួនឯងផ្ទាល់អំពីសារ ដែលគេប្រកាសផ្សាយនោះទេ? ហើយបើស្តាប់ឮ ថាតើគេផ្សាយថាយ៉ាងម៉េចខ្លះ?

**ឆ៖** បាទ ពេលនុ៎ង ខ្ញុំក្តាប់មិនបានអស់ទេ ប៉ុន្តែខ្ញុំគ្រាន់តែចាំបានថា សារនុ៎ងគេនឹងអញ្ជើញប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញឲ្យគាត់ចេញទៅខាងក្រៅសិន។ បាទ គ្រាន់ថាឲ្យចេញឲ្យអស់ ដើម្បីគេរៀបចំ បាទ យកទីក្រុងភ្នំពេញរៀបចំសាជាថ្មីវិញ។ អ៊ីចឹងដឹងតែប៉ុណ្ណឹង ត្រង់ថាខ្លឹមសារអីផ្សេងៗខ្ញុំអត់បានដឹង។

[១០:០៣:៥៥]

**ស៖** លោកឆ្លើយថាមានកងចល័ត ដែលដើរចុះឡើងៗនៅក្នុងក្រុង ហើយជាអ្នកទទួលបន្ទុកផ្សព្វផ្សាយសារ។ តើអង្គភាពចល័តនុ៎ងជាអង្គភាពរបស់កងពលធំ ឬក៏ជារបស់កងទ័ពណាផ្សេងទៀត? តើអង្គភាពចល័តហ្នឹងស្ថិតនៅក្រោមឱវាទរបស់អង្គភាពណា? ហើយគេប្រើឧបករណ៍របស់កងពល ឬក៏របស់អ្នកណា? ដូចជាឧទាហរណ៍ មីក្រូផ្សាយជាដើមហ្នឹង តើជារបស់អ្នកណា?

**ឆ៖** បាទ បញ្ហាហ្នឹងខ្ញុំអត់ដឹង ដូចខ្ញុំបានជម្រាបថា ខ្ញុំថ្នាក់តូច។ អ៊ីចឹងនេះជាផែនការរបស់ថ្នាក់

មេធំៗ មិនដឹងជាគាត់ចងក្រងយកក្រុមណា យកអង្គភាព។ ហើយតួនាទីខ្ញុំនេះគ្រាន់តែឲ្យនៅកន្លែងណាការពារតែកន្លែងហ្នឹងទេ ព្រោះមិនអាចដើរឆ្លងកាត់ពីតួនាទីខ្លួនទៅកន្លែងគេបាន។ អ៊ីចឹងភារកិច្ចអ្នកដែលចល័តនេះជាភារកិច្ចរបស់ថ្នាក់លើ ដែលមិនអាចខ្ញុំដឹងបាន។

**ស៖** តើលោកអាចបញ្ជាក់បានទេថា នៅក្នុងកងពលរបស់លោកនោះមានសម្ភារៈអ្វីខ្លះដើម្បីផ្សព្វផ្សាយជូនប្រជាជននោះ? ឧទាហរណ៍ដូចជាមានមីក្រូទេនៅក្នុងអង្គភាពរបស់លោកនោះ?

**ឆ៖** បាទ ចំពោះនៅកងខ្ញុំផ្ទាល់នេះពុំមានទេ។ តែដែលកង ដែលខ្ញុំថា ជាកងចល័តដែលគេដើរផ្សព្វផ្សាយនោះ គេមានឡាន គេមានដាក់មីក្រូបើកផ្សព្វផ្សាយជាបន្តបន្ទាប់។

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីការពិពណ៌នាអំពីភូមិភាគ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលរបស់លោក។ ខ្ញុំដឹងថា នៅពេលណាមួយនោះគឺទីក្រុងភ្នំពេញត្រូវបានបែងចែកដោយភូមិភាគផ្សេងៗ ហើយមានកងពលខ្លះកាន់តំបន់ ភូមិភាគនេះ ភូមិភាគនោះអ៊ីចឹង។ ហើយខ្ញុំដឹងថា កងពលរបស់លោកនោះគឺកាន់ផ្នែកខាងជើងនៅទីក្រុងភ្នំពេញ។ តើអ៊ីចឹងទេ?

[១០:០៦:២៤]

**ឆ៖** បាទកងពលខ្ញុំនេះ ដែលមុនបែកភ្នំពេញ គេឲ្យមុខសញ្ញាពីព្រែកក្ដាមមកទាល់ទីក្រុងភ្នំពេញ។ ក្រោយដែលយើងវៃបែកហើយ ទទួលចាប់ពីវត្តភ្នំនេះឆ្ពោះទៅជើងវិញ។ បាទ ត្រឹមវត្តភ្នំទៅខាងជើងវិញ។ អ៊ីចឹងឈរជើងរបស់កងពល៣១០ គឺនៅម្ដុំខាងជើងវត្តភ្នំហ្នឹង។

**ស៖** មុខព្រួញខាងជើងវត្តភ្នំនេះ គឺទៅរហូតដល់មាត់ទន្លេសាប ហើយនិងទៅដល់ស្ពានជ្រោយចង្វា ទួលគោក ស្ថានីយរថភ្លើង ហើយទៅដល់មហាវិថីនរោត្តមទេ ពេលនុ៎ង?

**ឆ៖** បាទ ខ្ញុំនៅក្នុងភូមិសាស្ត្រដែលគ្រប់គ្រងរបស់កងពលនេះ ខ្ញុំបាទមិនដឹងអស់ទេ។ ប៉ុន្តែខ្ញុំបាទដឹងថា ប៉ុស្តិ៍វិទ្យុនៅខាងលិចវត្តភ្នំហ្នឹង គឺស្ថិតនៅក្រោមដីកងពលរបស់ខ្ញុំ ហើយទៅកើតគឺត្រឹមមាត់ស្ទឹង -- អូ៎! មាត់ទន្លេខាងលិចបាទ ហើយទៅលិចនេះ មានស្ថិតនៅក្នុងទួលគោក ទួលអីនេះ ក៏ជាដីរបស់កងពលយើងខ្ញុំដែរ។

**ស៖** មានអគារសាធារណៈមួយចំនួនដែលមាននៅក្នុងមុខព្រួញទាំងអស់នោះ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលរបស់លោក។ ឧទាហរណ៍ដូចជាធនាគារជាតិនៃកម្ពុជា ដែលស្ថិតនៅក្នុងមុខព្រួញនៃកងពលរបស់លោក តើក្រោយពីវាយយកទីក្រុងភ្នំពេញបាននោះ តើមានអ្វីកើតឡើងចំពោះធនាគារជាតិនេះ?

**ឆ៖** បាទ ពេលដែលចូលដល់ទីក្រុងភ្នំពេញនេះ ហើយខ្ញុំបាទនេះអត់ស្គាល់កន្លែងណាថា ធនាគារជាតិទេ អត់ដឹង។ បាទដោយសម័យនុ៎ងគឺថា ដូចខ្ញុំជម្រាបហើយថា ប្រគល់ដីប្រវែងណា គឺនៅប្រវែងហ្នឹង ទទួលខុសត្រូវប៉ុណ្ណឹង។ ហើយក្រុមណា ទទួលខុសត្រូវក្រុមនុ៎ង គឺថាមិនអាចដើរឆ្លងកាត់ទៅក្រុមគេ ឬក៏មានពេលវេលាដើរទៅនិយាយលេងគ្នា គឺថាអត់មានទេ គឺថាទទួលខុសត្រូវ គឺ និយាយរួម២៤ម៉ោងលើ២៤ម៉ោង កាំភ្លើងខោអាវគឺថាការពារជាប់ បាទ គឺនៅឈរជើងជាប់តែម្តង តែកន្លែងខ្លួនហ្នឹង។

[១០:០៩:២៧]

**ស៖** លោកសាក្សី លោកនៅភ្នំពេញ ហើយលោកមិនដែលទៅដល់ធនាគារជាតិទេមែនទេ លោកមិនដែលដឹងថាកន្លែងហ្នឹងជាធនាគារជាតិទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ទោះបីជាដីឡូត៍នេះជាដីឡូត៍របស់កងពលខ្ញុំពិតមែន ប៉ុន្តែតួនាទីខ្ញុំនេះ ដូចខ្ញុំជម្រាបហើយថា គេឲ្យនៅប៉ុនណា គឺបានតែប៉ុណ្ណឹងទេ។ ព្រោះតួនាទីក្រុមវាមាន ការតូចណាស់ដែលនៅ -- ឲ្យក្រុមទទួលខុសត្រូវ។ អ៊ីចឹងស្គាល់តែមួយដីឡូត៍ក្រុមខ្លួនឯងទេ។ រីឯវង្វង់កងពលនោះមិនអាចដឹងទេថាអត់មានសិទ្ធិទទួលដឹងដល់នុ៎ង។

**ស៖** លោកសាក្សី ក្រៅពីធនាគារជាតិនៃកម្ពុជា នៅមុខព្រួញរបស់លោកនោះមានអគារសាធារណផ្សេងទៀត។ តើមាន -- ឧទាហរណ៍ដូចជាមានមន្ទីរពេទ្យ។ តើលោកអាចប្រាប់បានទេថាមានមន្ទីរពេទ្យណាខ្លះដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលលោក?

**ឆ៖** ខ្ញុំបាទ វាពុំបានដឹងនូវមន្ទីរពេទ្យក្នុងកងពលទេ ប៉ុន្តែក្នុងមុខសញ្ញាក្រុមរបស់ហ្នឹងមានមន្ទីរពេទ្យព្រះកេតុមាលា បាទនៅក្នុងហ្នឹងដីឡូត៍ក្រុមខ្ញុំហើយ។

[១០:១១:១៥]

**ស៖** យើងនិងនិយាយអំពីមន្ទីរពេទ្យនេះ។ តើលោកមានបានទៅមន្ទីរពេទ្យព្រះកេតុមាលានេះទេ? ហើយក្នុងបញ្ហាជាទូទៅដែលចេញដោយថ្នាក់លើឲ្យជម្លៀសប្រជាជនភ្នំពេញ តើការបញ្ហានេះឲ្យមានការជម្លៀសពាក់ព័ន្ធទៅនឹងមន្ទីរពេទ្យព្រះកេតុមាលានេះទេ?

**ឆ៖** បាទ យើងខ្ញុំនៅក្នុងមន្ទីរទេ ពេលដែលកំពុងជម្លៀស ខ្ញុំបាទមិនបានដឹង ហើយពុំបានចូលទៅក្នុងមន្ទីរពេទ្យនេះទេ។ លុះត្រាដែលជម្លៀសអស់ហើយ ហើយគេបោសសម្អាតមន្ទីរពេទ្យនេះឲ្យស្អាត ហើយគេយកកងទ័ពរបស់យើងខ្ញុំដែលពេលប្រយុទ្ធចូលក្រុងភ្នំពេញនេះ ដែលមានរបួសហ្នឹងយក

មកដាក់ក្នុងមន្ទីរពេទ្យនេះ ហើយគេបន្តព្យាបាលទៀត។

**ស៖** តើមានន័យថាម៉េចដែរ នៅពេលដែលលោកនិយាយថាមន្ទីរពេទ្យត្រូវបានបោសសម្អាតនោះ? តើមានន័យថាយ៉ាងម៉េច?

**ឆ៖** បាទ ពេលដែលយើងបែកទីក្រុងភ្នំពេញ គឺថាការជម្លៀស ការច្របូកច្របល់ ដូចខ្ញុំបានជម្រាបហើយ ដូច្នេះ ខ្ញុំមិនបានដឹងថាក្នុងមន្ទីរពេទ្យនេះគេចូលជម្លៀសពេទ្យក្នុងនុ៎ងយ៉ាងណាៗខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែពេលដែលគេជម្លៀសអស់ហ្នឹង គឺមានបុគ្គលិកខាងៗក្រៅដែលគេចូលមក គេបោសសម្អាតបានថាធ្វើអនាម័យ គេបោសសម្អាតហើយ គេបញ្ចូលអ្នកជំងឺដែលមានរបួសទៅនៅសមរភូមិពេលវាយចូលភ្នំពេញនេះ ឲ្យមកសម្រាកនៅមន្ទីរពេទ្យព្រះកេតុមាលាវិញ ហើយក៏មានពេទ្យខាងកងទ័ពហ្នឹង គេមកព្យាបាល តែពីមុនមក ខ្ញុំអត់ដឹងទេ ដឹងតែពេលក្រោយដែលរំដោះហើយ ជម្លៀសអស់បានខ្ញុំដឹង។

[១០:១៣:៣០]

**ស៖** តើមានជនស៊ីវិលដែលត្រូវបានព្យាបាលនៅក្នុងមន្ទីរពេទ្យនោះទេ?

**ឆ៖** បាទ ដែលក្រោយពេលរំដោះហ្នឹង គឺថាពុំមានជនស៊ីវិលទេ ឃើញសុទ្ធតែទាហាន ដែលវាយសម្រុកទីក្រុងភ្នំពេញហ្នឹង គឺថាមានរបួស គឺគេយកមកព្យាបាលនៅក្នុងមន្ទីរពេទ្យហ្នឹង។ ឯជនស៊ីវិលគឺថាពុំមានឃើញ។

**ស៖** តើកងពល៣១០ ទទួលបន្ទុកក្នុងការពិនិត្យមើលផ្ទៀងផ្ទាត់ថាតើអគារសាធារណាផ្សេងៗនោះត្រូវបោសសម្អាតដែរឬទេ? ឧទាហរណ៍ដូចជាមានអគារក្រសួងចាស់ៗ ឧទាហរណ៍ដូចជាអគារក្រសួងប្រៃសណីយ៍ អគារស្ថានីរថភ្លើងជាដើម។ តើមានប្រតិបត្តិការដើម្បីពិនិត្យមើលផ្ទៀងផ្ទាត់ថាអគារទាំងអស់នេះ គឺត្រូវជម្លៀសចេញឲ្យអស់ស្អាតទេ?

[១០:១៤:៤៦]

**ឆ៖** បាទ ពេលដែលចូលដល់ទីក្រុងភ្នំពេញនេះ ហើយពេលនោះខ្ញុំក៏មិនបានស្គាល់ថាអគារណាជាអគារណា ហើយកន្លែងណាជាកន្លែងអី គឺខ្ញុំអត់បានស្គាល់ទេ។ ដោយទី១ វានៅវាងក្មេងផង ហើយមិនដែលចូលទីក្រុងភ្នំពេញ។ អ៊ីចឹងហើយដល់ពេលដែលចូលមកនេះ គេមិនបើកសិទ្ធិឲ្យដើរសម្រាប់មើលថា ពិភាក្សាគ្នាថាកន្លែងនេះជាកន្លែងអីៗ គឺថាអត់បានដឹង។ ដឹងតែកន្លែងថា ឲ្យនៅត្រង់ណាគឺនៅត្រង់ហ្នឹង។ បាទ ទាំងយប់ទាំង ទាំងថ្ងៃគឺល្វី(?)តែកន្លែងខ្លួន អ៊ីចឹងមិនបានមានសិទ្ធិសេរីភាព

ថា បែកហើយដើរពីណាទៅណា នឹកឃើញថាតាមចិត្តខ្លួនគឺអត់មាន។ អ៊ីចឹងគឺមិនអាចដឹងថា អគារណាជាអគារណាកន្លែងណាអីគឺអត់ដឹងបាទ។

**ស៖** យើងបាននិយាយបន្តិចបន្តួចរួចមកហើយ ក៏ប៉ុន្តែនៅក្នុងមុខព្រួញរបស់លោកដែលស្ថិតនៅក្នុងកងពល ៣១០ នុ៎ង គឺមានស្ថានទូត។ អម្បាញ់មិញនេះ លោកនិយាយអំពីអ្នកការទូតកូរ៉េ ហើយនិងគុយបា។ ប្រហែលជាខ្ញុំអាចយល់មិនច្បាស់ លោកបាននិយាយថា "កងពលរបស់លោកនុ៎ងទទួលបន្ទុកក្នុងការការពារអ្នកការទូតគុយបា និងកូរ៉េ"។ តើលោកបានឆ្លើយអ៊ីចឹងទេ ឬក៏ខ្ញុំស្ដាប់មិនច្បាស់ទេ?

[១០:១៦:១៩]

**ឆ៖** បាទ នៅក្នុងកងពលយើងខ្ញុំនេះ គឺពាក្យថា នៅទូតកូរ៉េ និងទូតគុយបា នេះ វានៅក្នុងក្រុមរបស់ខ្ញុំបាទ។ ផ្លូវផ្ទាល់នេះ គឺគេឱ្យក្រុមខ្ញុំអ្នកការពារ។ បាទ អ៊ីចឹងបានកន្លែងឡូត៍ខ្ញុំវាមានទូតកូរ៉េ និងទូតគុយបា ដែលនៅឆៀងខាងជើងវត្តភ្នំនេះ។ តែតួនាទីខ្ញុំគ្រាន់តែនៅក្រៅទេ ក្នុងកិច្ចការការពារទូតហើយនិងនៅក្នុងទូតនោះ គឺខ្ញុំអត់ដឹងទេ។ ភារកិច្ចយ៉ាងណាៗខ្ញុំអត់ដឹង ខ្ញុំដឹងតែការពាររង្វង់ក្រៅ។

**ស៖** តើស្ថានទូតទាំងអស់នោះត្រូវបានជម្លៀសមនុស្សចេញហើយ ឬក៏នៅក្នុងស្ថានទូតនោះនៅមានអ្នកការទូតនៅឡើយ? ឧទាហរណ៍ តើមានភៀសខ្លួនទៅពួននៅក្នុងស្ថានទូតទាំងអស់នោះទេ?

**ឆ៖** បាទ នៅពេលដែលបែកភ្នំពេញនេះ ខ្ញុំមិនបានដឹងថា កន្លែងស្ថានទូតនោះមានមនុស្សនៅឬអត់គឺខ្ញុំអត់បានដឹង។ ដែលខ្ញុំដឹងនេះ គឺស្ថានទូតនេះ ពេលដែលរំដោះទីក្រុងភ្នំពេញហើយ រៀបចំបានស្អាត បានល្អហើយ គឺតាមរយៈដែលសម័យដែលគេរំដោះហ្នឹង គឺទូតហ្នឹងមកក្នុងសង្គមហ្នឹងទេ មិនមែននៅក្នុងសង្គមមុនទេបាទ។ គឺតាមរយៈក្រោយទេ។

[១០:១៨:១០]

**ស៖** ក្នុងពេលលោកបំពេញសកម្មភាពក្នុងការការពារ តើលោកមានបានគ្រប់គ្រងទៅលើជនបរទេសទេ ហើយលោកមានបានទទួលការណែនាំជាក់លាក់ពាក់ព័ន្ធនឹងជនបរទេសដែរទេ? តើមានកន្លែងណាមួយដែលត្រូវជម្លៀសជនបរទេសទាំងអស់នោះទៅ ហើយនៅក្នុងកងពលរបស់លោកនុ៎ងមានមនុស្សណាម្នាក់ដែលទទួលបន្ទុកខាងបញ្ហាជនបរទេសទេ?

**ឆ៖** បាទ បញ្ហាហ្នឹង ខ្លួនខ្ញុំផ្ទាល់គឺអត់បានដឹងអំពីបញ្ហាជនបរទេស គឺថាអត់ដឹង។ ខ្ញុំដឹងតែភារកិច្ច គឺថាតាមចំណុចគោលដៅដែលគេដាក់ឱ្យ ភារកិច្ចបទបញ្ជាយ៉ាងណាធ្វើយ៉ាងនុ៎ង តែត្រង់ជនបរទេស គឺថាខ្ញុំអត់ដែលដឹង អត់ដែលឃើញទៀត។

**ស៖** តើលោកស្គាល់អ្នកណាម្នាក់ឈ្មោះ ណែម ដែរឬទេ -- ឈ្មោះ ញ៉ែម ដែលមានតួនាទីនៅក្នុងកងពល ៣១០ដែរ?

**ឆ៖** បាទ នៅកងពលនេះ ខ្ញុំពុំបានស្គាល់អង្គភាពថ្នាក់ធំៗកងពលគ្រប់រូបទេ ប៉ុន្តែខ្ញុំស្គាល់តាអឿន នេះគឺគាត់ជាប្រធាន។ បាទ ដែលស្គាល់នេះ គឺស្គាល់ទៅតាមរយៈអនុសេនាធំ អនុសេនាតូចគាត់មកប្រជុំថា កងពលយើងឈ្មោះ អឿន តែឲ្យបានជួបមុខ ជួបអីធ្លាប់ជិតស្និទ្ធគឺថាអត់ដែលបានជិតស្និទ្ធ ហើយក្រៅពីនុ៎ងអនុ ឬសមាជិកអីបន្តបន្ទាប់ គឺអត់ដែលដឹងថាអ្នកណាៗ ខ្ញុំអត់ដែលស្គាល់។

[១០:២០:០០]

**ស៖** លោក គង់ គីម តើលោកមានបានស្តាប់វិទ្យុដែរទេ នៅពេលដែលលោករើចូលភ្នំពេញ ហើយនៅពេលដែលមកនៅភ្នំពេញ លោកមានបានស្តាប់វិទ្យុទេ?

**ឆ៖** បាទ មុនពេលចូលភ្នំពេញ ហើយនិងចូលដល់ទីក្រុងភ្នំពេញ គឺថាភារកិច្ចហ្នឹង អត់បានដឹងពីវិទ្យុទេ គ្រាន់តែថា ទទួលបទបញ្ជាផ្ទាល់ៗក្នុងការងាររបស់ខ្លួន គឺថាព័ត៌មានទៅតាមវិទ្យុ គឺអត់បានស្តាប់។

**ស៖** តើលោកមានឮគេនិយាយអំពីជនមហាក្បត់ទាំង៧ ដែលត្រូវកម្ទេចចោលទេ?

**ឆ៖** បាទ នៅចំណុចនេះ ខ្ញុំអត់ដែលឮ ហើយក៏អត់ដែលដឹងដែរ។

**ស៖** ចុះឈ្មោះ សិរិមត:, ឡុង បូរ៉េត ...។ល។ លោកធ្លាប់ឮទេ?

**ឆ៖** បាទ ឈ្មោះហ្នឹង ខ្ញុំអត់ដែរឮ។

**ស៖** លោកបានឆ្លើយថា លោកបានចូលរួមក្នុងការបោសសម្អាតផ្លូវថ្នល់ ដើម្បីទទួលភ្ញៀវសំខាន់ៗ ដែលមកទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ តើលោកផ្ទាល់នោះ លោកមានបានចូលរួមទទួលគណ:ប្រតិភូដោយផ្ទាល់ទេ? លោកមានតួនាទីអ្វីទេ ក្នុងការទទួលនុ៎ង? ឧទាហរណ៍ ដូចជាលោកគ្រាន់តែជាអ្នកឈរទទួលភ្ញៀវ ឬក៏លោកជាអ្នកយាមកាម។ តើលោកមានតួនាទីអ្វីខ្លះចំពោះភ្ញៀវដែលមកនេះ?

**ឆ៖** បាទ ពេលដែលទទួលភ្ញៀវនេះ មិនមែនទៅទទួលរាក់ទាក់ភ្ញៀវទេ គ្រាន់តែទទួលការពារក្នុងឡូត៍ដែលខ្លួន -- ហើយដែលពេលភ្ញៀវឆ្លងកាត់នឹងឡូត៍ខ្លួននេះ ខ្លួនត្រូវការពារ ដែលពេលដែលគេឆ្លងកាត់ហ្នឹងទេ។ ត្រង់ថា ភ្ញៀវនឹងអញ្ជើញទៅប្រជុំកន្លែងណា ឬក៏ទៅទិសដៅណា ខ្ញុំអត់ដឹងទេ។ គ្រាន់តែមានភារកិច្ច ថាពេលដែលគេឆ្លងកាត់ឡូត៍ហ្នឹង ការពារធ្វើម៉េចឲ្យផុតពីឡូត៍ខ្លួនបាទ។

[១០:២៣:០២]

**ស៖** តើលោកធ្លាប់ឮសណ្ឋាគារឡឺរ៉ូយ៉ាល់ ទេ? ហើយមានភ្ញៀវទៅស្នាក់នៅអូតែលឡឺរ៉ូយ៉ាល់ ទេ ហើយសណ្ឋាគារនេះ ស្ថិតនៅក្នុងមុខព្រួញរបស់លោកទេ?

**ឆ៖** បាទ ឈ្មោះសណ្ឋាគារនេះ ខ្ញុំអត់ស្គាល់ផង មិនដឹងសណ្ឋាគារនេះ នៅទីណា។ ប៉ុន្តែនៅខាងលិចវត្តភ្នំនេះ និងខាងជើងសួនស្មៅនេះ គឺសណ្ឋាគារនេះមួយ មានការគគ្រឹកគគ្រេងក្នុងសម័យដែលរំដោះ ក្រោយរំដោះ។

**ស៖** នៅពេលភ្ញៀវមកដល់ភ្នំពេញ តើគេមានឲ្យទាហានមួយចំនួនស្លៀកពាក់ជាស៊ីវិលដែរឬទេ? ហើយបើឲ្យស្លៀកជាស៊ីវិល តើមូលហេតុអ្វីដែរ?

**ឆ៖** បាទ នៅពេលដែលមានភ្ញៀវបរទេសឆ្លងកាត់នេះ ផ្នែកទាហាននេះ ពុំមានឲ្យស្លៀកស៊ីវិលទេ គឺថាទាហានមានតែស្លៀកខោអាវទាហាន ហើយការពារ។ រីឯអ្នកដែលស៊ីវិលនេះ បើតាមខ្ញុំដឹងក្នុងដីឡូត៍ខ្ញុំនេះ វាមានកម្មករទៅខាងកាត់ដេរ កាត់អីហ្នឹង គេយកមកស្លៀកជាស៊ីវិលទទួល បាទ ហ្នឹងដោយឡែក។

**ស៖** តើលោកមានចាំការរៀបចំព្រឹត្តិការណ៍ណាមួយដែលគួរឲ្យកត់សម្គាល់ទេ? ឧទាហរណ៍ដូចជាលោកមានចាំអំពីទស្សនកិច្ចរបស់គណៈប្រតិភូសំខាន់ៗមួយចំនួន ដូចជា ចិន កូរ៉េ ជាដើម ...។ល។

**ឆ៖** បាទ នៅកិច្ចការទាំងអស់នេះ ខ្ញុំអត់បានទេ ដូចខ្ញុំបានប្រាប់ហើយថា កាលនុំងគឹកងទ័ពជំនាន់នោះគឺថាពុំមាន មានសិទ្ធិសេរីភាពអីដើម្បីស្រាវជ្រាវឲ្យដឹងពីកិច្ចការងារអី អត់ដឹងទេ គឺថាបទបញ្ជាគឺថាទទួលខុសត្រូវគឺថាឲ្យទទួលកន្លែងណា គឺកន្លែងហ្នឹងបាទ។ ព្រោះបើកាលណាយើងប្រព្រឹត្តខុស វាទៅជាជួនកាលយើងហ្នឹងជាកងទ័ព តែបែរទៅជាខ្មាំងវិញ បាទ ទ្រឹស្តីហ្នឹង។ អ៊ីចឹង ការគោរពបទបញ្ជាហ្នឹងគឺម៉ឺងម៉ាត់ណាស់ ព្រោះគោរពបទបញ្ជានេះ គឺប្តូរនឹងជីវិត បាទ បើយើងធ្វើខុសវាខ្លាចគ្រោះថ្នាក់ដល់ជីវិត អ៊ីចឹងគឺថា គោរពកន្លែងណាគឺនៅកន្លែងហ្នឹងហើយ បទបញ្ជាដាក់ត្រង់ណាគឺត្រង់ហ្នឹងតែម្តង។

**ស៖** ឧទាហរណ៍ តើគេមានប្រាប់លោកអំពីដំណើរយាងត្រឡប់សម្តេច នរោត្តម សីហនុ មកទីក្រុងភ្នំពេញដែរឬទេ?

[១០:២៦:០១]

**ឆ៖** បាទ កិច្ចការទាំងអស់នេះគឺថា ខ្ញុំអត់បានដឹងទេ ព្រោះថាវាអត់មានសិទ្ធិអីទទួលដឹងពីការងារធំៗខាងលើគឺថាអត់ដឹងទេ។

**ស៖** ក្នុងពេលដែលលោកនៅទីក្រុងភ្នំពេញ លោកមិនដែលដឹងទេថា សម្តេចនរោត្តម សីហនុ នៅទីក្រុង -- គង់នៅក្នុងទីក្រុងភ្នំពេញ ឬក៏អត់នោះ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំ -- រយៈពេលដែលរំដោះ -- រយៈពេលខ្លីណាស់ដែលខ្ញុំបាននៅទីក្រុងភ្នំពេញ ដូចខ្ញុំបានជម្រាបហើយថា ពេលដែលខ្ញុំនៅអត់ដឹងទេ ហើយរហូតទៅដល់ខ្ញុំទៅនៅទីក្រុងកំពង់ឆ្នាំងក៏អត់ដឹងថាសម្តេច សីហនុ នៅកន្លែងណាអីកន្លែងណា ខ្ញុំអត់ដឹង។

**ស៖** លោកសាក្សី លោកបានឆ្លើយថា "លោកបានចូលរួមក្នុងការឃាមអ្នកទោស ហើយលោកក៏ឆ្លើយថា ឃើញមានប្រភេទអ្នកទោសផ្សេងៗគ្នានៅក្នុងគុក"។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺថា នៅពេលដំបូង លោកបានឆ្លើយថា មានមនុស្សធម្មតា បន្ទាប់មកទៀតឃើញមានអ្នកទោសជាអ្នកទទួលខុសត្រូវឃោធា ឬក៏នយោបាយនៅកម្ពុជាប្រជាធិបតេយ្យ។ ចំពោះអ្នកទោសធម្មតា តើអ្នកទោសហ្នឹងជាអ្នកណាដែរ?

[១០:២៧:៥៦]

**ឆ៖** បាទ ខ្ញុំ -- ពេលដែលខ្ញុំឃាមគុកហ្នឹង គឺខ្ញុំមិនបានបែងចែកថាអ្នកទោសនយោបាយ ឬក៏ទោសអី អត់ដឹងទេ គឺដឹងថាពេលគេយកមក គឺដឹងថា -- ពេលគេនាំចូលគឺដឹងថា "អ្នកទោស"។ អ៊ីចឹងពេលដែលដឹកនាំមកពីឆ្ងាយមក ឃើញថាពេលគេយកមកដាក់ក្នុងគុកនោះ វាមាន -- គុកហ្នឹងវាមានពីរជាន់ទៅលើអ៊ីចឹងទៅ ហើយគេដាក់ឲ្យគាត់សម្រាន្តនឹងគ្រែ ហើយមានទឹកតែទឹកអ៊ីចឹង ហើយជាអ្នករាងចាស់ៗ គ្រាន់ដឹងប៉ុណ្ណឹង។ រីឯគុកក្នុងដីនេះ តាមការពិនិត្យរបស់ខ្ញុំឃើញថា សុទ្ធជាកងទ័ពដែលធ្វើខុសនឹងបទបញ្ញា គឺយកទៅដាក់គុកក្នុងដីហ្នឹងហើយ។

[១០:២៨:៥២]

**ស៖** តើលោកដឹងទេថា ក្នុងចំណោមអ្នកទោសទាំងនោះ ជា -- នៅពេលដំបូងឡើងយ៉ាងហោចណាស់នោះ មានអតីតនាយទាហាន ឬមន្ត្រីរដ្ឋការរបស់របប លន់ នល់ ដែរឬទេ?

**ឆ៖** បាទ ពេលដែលខ្ញុំឃាម ហើយដោយដឹងជាប្រយោលខ្លះៗហ្នឹងគឺថា អ្នកដែលជាប់គុកនេះអត់មានជាប់អ្នករបបមុនទេ អ្នកជាប់ហ្នឹងគឺតែងតាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់ដែលចាប់មកពីថ្នាក់ខាងក្រោយៗមក។

**ស៖** តើលោកដឹងរឿងនេះដោយរបៀបណា? ហេតុអ្វីក៏លោកដឹងថាមិនមានអ្នកនៅក្នុងរបបចាស់នៅក្នុងគុកនោះ? ហើយមានតែអ្នកទោសរបស់អង្គការនោះ? តើគេប្រាប់រឿងនេះដល់លោក ឬក៏លោកកត់សម្គាល់ឃើញដោយខ្លួនឯង ឬក៏លោកអាចសួរអ្នកទោសនោះថាមកពីណាអីពីណាអីចឹង?

**ឆ៖** បាទ ក្នុងបញ្ហាដែលដឹងនេះ ដោយសារខ្ញុំជាអ្នកការពារ។ អ៊ីចឹងការពារនេះមានសិទ្ធិការពារ មានសិទ្ធិឈរមើល មានសិទ្ធិស្តាប់ខ្លះ។ តែក្នុងកិច្ចការជាមួយអ្នកដែលមានទោសនេះ យើងពុំអាចទៅសួរផ្ទាល់បានទេ ព្រោះតួនាទីយើងការពារ។ អ៊ីចឹងដែលការដឹងនេះ ដឹងអាស្រ័យទៅដោយយើងឮ ដែលពេលគេសួរចម្លើយ ហើយដែលគេប្រាប់អំពីមកពីខេត្តណា មកពីស្រុកណា។ អ៊ីចឹងពេលគេសួរចម្លើយ គេសួរទៅតាមតំបន់ភូមិភាគដែលគាត់ទទួលខុសត្រូវ។

[១០:៣១:០៣]

**ស៖** ដោយមិនចូលដល់លម្អិតអំពីអ្វីដែលលោកស្តាប់ឮ តើអ្នកទោសទាំងអស់នោះគេចោទពីបទអ្វីដែរ?

**ឆ៖** បាទ ចំណុចដែលគេសួរនេះ ខ្ញុំក្តាប់មិនបានអំពីជនជាប់ចោទត្រូវជាខ្មាំងនេះ គឺថារកចំណុចគោលដៅអី ពាក្យថាក្បត់អង្គការនោះ គឺថាអត់ដឹង។ ដឹងតែពេលគេមកសួរចម្លើយ ដោយស្តាប់បានខ្លះ មិនស្តាប់បានខ្លះ ហើយនិងឃើញតែធ្វើទារុណកម្មហ្នឹង គឺថាដឹង។ តែចំចំណុចកំហុសដាក់ទោស ទម្ងន់ឲ្យទៅខាងជនរងគ្រោះ អត់ដឹងពីមូលហេតុអី អត់ដឹង។

**ស៖** ឥឡូវយើងត្រឡប់មកក្រោយបន្តិចវិញ ជាពិសេសគឺត្រឡប់មកនិយាយអំពីការបោសសម្អាតទីក្រុង។ តើលោកធ្លាប់ស្តាប់ឮ ឬក៏ទទួលបញ្ហាពាក់ព័ន្ធទៅនឹងជ័យភណ្ឌសង្គ្រាមដែរឬទេ? តើមានការណែនាំជាក់លាក់ថា ឲ្យយកជ័យភណ្ឌសង្គ្រាមទៅធ្វើអ្វីដែរឬទេ?

**ឆ៖** បាទ នៅបញ្ហានេះគឺខ្ញុំបាទពុំដែលបានដឹង ហើយពុំដែលបានឮពីកិច្ចការទាំងអស់នេះទេ គឺថាអត់ដឹង។

[១០:៣២:៥៦]

**ស៖** តើអ្នកដែលត្រូវចេញពីទីក្រុងភ្នំពេញនេះ គេមានឆែកឆេរដែរឬទេ? ហើយប្រសិនបើគេឆែកឆេរនោះ តើមានការរឹបអូសយករបស់របរពីអ្នកដែលត្រូវជម្លៀសចេញទេ?

**ឆ៖** បាទ តាមការមើលរបស់ខ្ញុំ ហើយនិងដឹងនៅពេលប្រជាពលរដ្ឋធ្វើដំណើរចេញទៅក្រៅ

នេះ គេដកតែបញ្ហាអាវុធ បាទ។ រីឯទ្រព្យសម្បត្តិ លុយមាសប្រាក់អី គឺថាអត់មានអ្នកណាប៉ះពាល់ទេបាទ គឺថាមានអីយកទៅបាន។ តែត្រង់បញ្ហាអាវុធនេះ គឺត្រូវដកចេញ។

**ស៖** ចុះនៅក្នុងផ្ទះសម្បែងវិញ តើមានម្ហូបអាហារ ស្បៀងដែលត្រូវដឹកយកទៅកាន់ឃ្លាំងណាទេ? មានការបញ្ជាឲ្យដឹកស្បៀងអាហារដែលនៅសល់ក្នុងផ្ទះនីមួយៗ យកទៅកាន់ឃ្លាំងណាមួយស្តុកទុកទេ?

**ឆ៖** អ៊ីចឹងបញ្ហាដែលប្រមូលស្បៀងអាហារអីនេះ ខ្ញុំបាទអត់ដឹងទេ។ ព្រោះនៅពេលនោះគឺកងទ័ពដែលចូលមកដល់ទីក្រុងភ្នំពេញនេះ គឺថាអត់មានចង់បានកម្មសិទ្ធិអីទេ គឺកំណត់របស់ថ្នាក់លើគឺថាកងទ័ពឲ្យមានខោអាវតែពីរកំប្លេ ហើយនិងប្រដាប់ប្រដានៅក្នុងបាឡូ ក្រៅពីបាឡូអត់មានទេ។ ហើយមានការត្រួតពិនិត្យពីថ្នាក់ដឹកនាំពីលើៗទៀត បើសិនជាយើងមានគេល្មី(?)ដកចេញអស់។ អ៊ីចឹងកិច្ចការដែលប្រមូលជ័យភណ្ឌ ប្រមូលធនធានអី គឺក្រុមខ្ញុំនេះតូចណាស់ គឺថាមិនដឹងពីការងារហ្នឹងបាន។

[១០:៣៥:០៨]

**ស៖** ខ្ញុំមិននិយាយអំពីការប្រមូលយកអីវ៉ាន់ផ្ទាល់ខ្លួនដោយពួកយោធាទេ។ ខ្ញុំនិយាយអំពីការរៀបចំពីថ្នាក់លើមួយ ដើម្បីប្រមូលស្បៀងទាំងអស់នោះយកទៅដាក់ក្នុងឃ្លាំងណាមួយរបស់អង្គការ។ តើមានការបញ្ជាបែបហ្នឹងទេ?

**ឆ៖** បាទ ដូចខ្ញុំបានឆ្លើយថា កិច្ចការទាំងអស់នេះខ្ញុំអត់បានទទួលបញ្ជា ឬក៏ឃើញអីសកម្មភាពនេះគឺថាអត់ដឹងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅការិយាល័យ -- នៅបន្ទប់សម្រាកសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោង

ដប់មួយ។ មេធាវីប្រឹក្សាសាក្សីដូចគ្នា។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៦ នាទី ដល់ម៉ោង ១១:០០ នាទី)*

[១១:០០:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងក្នុង ទាំងក្រៅបន្ទប់សវនាការ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** លោក គង់ គីម សូមអរគុណណាស់ដែលលោកមានវត្តមានជាមួយយើងខ្ញុំថ្ងៃនេះ។ ខ្ញុំឈ្មោះ ហ្សាស្តេ ប៉ៅ ជាមេធាវីការពារក្តីឲ្យលោក នួន ជា ជាមួយនិងសហភាតារបស់ខ្ញុំលោក សុន អរុណ។ ខ្ញុំនឹងតាំងសំណួរមួយចំនួនទាក់ទងទៅនឹងចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ក៏ដូចជាចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១១:០១:៤៩]

បាទ ខ្ញុំព្យាយាមនិយាយឲ្យបានយឺតៗដើម្បីឲ្យបកប្រែទៅបានពេញលេញ។ សំណួររបស់ខ្ញុំពាក់ព័ន្ធទៅនឹងអំឡុងពេលមុនភ្នំពេញដួលរលំទៅគឺ មុន១៧មេសា ៧៥។ លោកបានលើកថា “មុនពេលភ្នំពេញ ដួលរលំទៅគឺថាគេមានការវាយប្រយុទ្ធគ្នា ហើយមានអ្នករងរបួសទាំង -- ភាគីទាំងសងខាង”។

លោកអាចប៉ាន់ប្រមាណបានទេ ថាតើលោកចូលរួមប្រយុទ្ធអស់រយៈពេលប៉ុន្មានដែរ មុននឹងលោកចូលមកកាន់ទីក្រុងភ្នំពេញនោះ?

**លោក គង់ គីម៖**

**ឆ៖** បាទ មុនវាយចូលដល់ទីក្រុងភ្នំពេញ ខ្ញុំជម្រាបបានថា ពីមុនដំបូងខ្ញុំជានីរសាររមួយសម្រាប់ជញ្ជូនបាយ ហើយនិងនាំសារពីសមរភូមិមុខទៅសមរភូមិក្រោយ។ ក្រោយមក គឺថាការធ្វើនីរសារនេះអាចឆ្លងកាត់គ្រាប់ បាទទាំងគ្រាប់ផ្លោង ហើយនិងមានការប្រយុទ្ធគ្នាហ្នឹងយើងបញ្ជូនបាយទៅវាចំមានការប្រយុទ្ធគ្នា។ អ៊ីចឹងក្រោយមក គឺថាអស់រយៈពេល ២ខែ គេដកខ្ញុំពីនីរសារនេះ ឲ្យចូលទៅតាមខ្សែត្រៀមជួរមុខបាទ។ អ៊ីចឹងរយៈពេលចំនួនប្រហែល ២ខែ ក្រោយមកបានយើងវាយដល់ដាច់ទីក្រុងភ្នំពេញ។ អ៊ីចឹងពេលដែលខ្ញុំធ្វើសកម្មភាពហ្នឹង គឺថាពេលថ្ងៃពើបប្រយុទ្ធដែលមានរថក្រោះ មានកប៉ាល់ហោះដែលទម្លាក់គ្រាប់បែកផង ហើយពេលថ្ងៃៗទាហានឡើងបុកពីភូមិធំត្រពាំងព្រាយ ដែលបុកទៅតាមមុខសញ្ញាខ្ញុំនេះ គឺថាមានការគ្រោះថ្នាក់ជាបន្តបន្ទាប់។ បាទ ពេលទាហានបុកទៅម្តងៗ គឺថាមានជួនកាលរហូតដល់ទី២០, ៣០នាក់ពលី ពេលដែលប្រយុទ្ធគ្នា។ នេះទិដ្ឋភាពជាក់ស្តែងដែលខ្ញុំបានចូលរួមប្រយុទ្ធ គឺថាមានបញ្ហាប៉ុណ្ណឹង។

[១១:០៣:៥១]

**ស៖** លោកដឹងទេ ថាអ្នកណាជាអ្នកទម្លាក់គ្រាប់មកលើកងទ័ពរបស់លោកហ្នឹង?

**ឆ៖** បាទ ពេលនុ៎ងគឺយើងខ្ញុំបានដឹង ហើយបានគេប្រាប់គ្រាន់ៗដឹងថា កប៉ាល់ហោះដែលទៅទម្លាក់ជាកប៉ាល់ហោះអាមេរិកាំងដែលជំនួយឲ្យខាងពួក លន់ នល់ គ្រាន់តែដឹងប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកស្ថិតនៅក្នុងសមរភូមិ តើលោកមានបានដឹងថាទាហាន លន់ នល់ ធ្វើយ៉ាងម៉េចជាមួយនឹងកងទ័ពខ្មែរក្រហមដែលត្រូវបានគេ ទាហាន លន់ នល់ ចាប់ខ្លួនដែរនោះ? តើខាងទាហាន លន់ នល់ ធ្វើម៉េចមកលើកងទ័ពខ្មែរក្រហមដែលត្រូវបានចាប់ខ្លួននោះ?

**ឆ៖** បាទ សំណួរហ្នឹងខ្ញុំក្តាប់អត់បានថា ទាហាន លន់ នល់ ចាប់ទាហានខាងក្រៅ ឬក៏ទាហានខាងក្រៅចាប់ទាហាន លន់ នល់?

[១១:០៥:០៥]

**ស៖** សំណួរខ្ញុំព្យាយាមបញ្ជាក់ឡើងវិញ។ ថាតើលោកបានឃើញ ឬក៏លោកមានបទពិសោធន៍អ្វីដែរទេ ថាតើទាហាន លន់ នល់ ដែលធ្លាប់បានចាប់បានទាហានខ្មែរក្រហមដែរឬទេ?

**ឆ៖** បាទ តាមការប្រយុទ្ធជាក់ស្តែង គឺយើងខ្ញុំពុំបានឃើញទាហានខាង លន់ នល់ ចាប់បានទាហានខាងក្រៅទេ។ ព្រោះពេលប្រយុទ្ធនេះ គឺថាខាងទាហានខាងក្រៅមានការដាច់ខាតណាស់ គឺថា ដរាបណាបើសិនជាទាហាន លន់ នល់ ចាប់ គឺគេបំផុសថា ការងារធ្វើទារុណកម្មខ្លាំង។ អ៊ីចឹងទាហានខាងក្រៅគឺថាប្រយុទ្ធលុះត្រាតែស្លាប់នៅនឹងកន្លែង។ បាទ អត់ដែលមានចាប់ទេ។

**ស៖** សំណួរមួយទៀតទាក់ទងទៅនឹងការប្រយុទ្ធគ្នានៅមុនការដួលរលំទីក្រុងភ្នំពេញ។ បាទ ខ្ញុំសូមរៀបសំណួរខ្ញុំឡើងវិញ មុននឹងចូលទៅប្រធានបទមួយទៀត។ ឥឡូវនេះ យើងកំពុងនិយាយគ្នាអំពីការបញ្ជា គឺប្រហែលជាលោកធ្លាប់បានទទួលមុនភ្នំពេញដួលរលំនោះ។ នៅក្នុងសំណុំរឿងមានកិច្ចសម្ភាសន៍ស្តាប់ចម្លើយ កិច្ចសម្ភាសន៍ជាមួយលោក ហេង សំរិន ដែលសម្ភាសដោយលោក ប៉ែន ឃៀរនិន នៅក្នុងខែធ្នូ ឆ្នាំ១៩៩១។ ឯកសារនេះគឺ E3/1568, ERN ជាភាសាអង់គ្លេស 00651886, ERN ជាភាសាខ្មែរ 00713958។ បាទ នៅពេលចាប់ផ្តើម គឺលោក ហេង សំរិន ជាមេបញ្ជាការកងពលនៅភូមិភាគបូព៌ា នៅចូលមកដល់ភ្នំពេញនៅថ្ងៃ-- នៅព្រឹកថ្ងៃទី១៧ មេសា ៧៥ ហើយលោកបានជម្រាបទៅលោក ប៉ែន ឃៀរនិន អំពីបទពិសោធន៍របស់លោក នៅពេលដែលលោកប្រឈមមុខទៅនឹងការប្រយុទ្ធនៅទីក្រុងភ្នំពេញនេះ។ តែសំណួររបស់ខ្ញុំ គឺពាក់ព័ន្ធមុនភ្នំពេញដួលរលំនេះ។ ខ្ញុំសូមដកស្រង់សម្តីរបស់លោក ហេង សំរិន នៅក្នុងអំឡុងពេលនោះ។

[១១:០៧:៥៨]

ខ្ញុំសូមដកស្រង់ “នៅពេលនោះ យើងបានទទួលផែនការពីមជ្ឈិម ពីថ្នាក់លើ ពាក់ព័ន្ធទៅនឹងការស្ទូងស្រូវ ប៉ុន្តែហើយយើងមិនមានពេលណាមួយដែលត្រូវសួរប្រជាពលរដ្ឋបាននោះទេ។ កងទ័ពត្រូវតែឧបត្ថម្ភខ្លួនឯង ត្រូវតែដាំដំណាំ ត្រូវតែដកស្ទូងស្រូវ។ នេះគឺជាបទបញ្ជា ជូនដាក់ទៅកងទ័ព។ ដូច្នេះកងពលរបស់ខ្ញុំត្រូវដាំដំណាំ ត្រូវស្ទូងស្រូវ ហើយក៏បានឧបត្ថម្ភទៅដល់ប្រជាជនឲ្យគាត់ហូបចុកផងដែរ” បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ លោក គង់ គីម! តើលោកបានទទួលបទបញ្ជាប្រហាក់ប្រហែលគ្នា មិនឲ្យសួរប្រជាជន មិនឲ្យសួរអ្វីទៅកាន់ប្រជាជននោះដែរឬទេ?

[១១:០៨:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមលោកប្រធាន សូមជំទាស់ចំពោះសំណួរនេះ។ បច្ចេកទេសនៃការអានមកសួរនេះ គឺថាគាត់មកពីអង្គភាពមួយផ្សេង ហើយការសួរទៅនឹងសាក្សី ទៅនឹងសំណួរនេះ គឺថាមិនជាការត្រឹមត្រូវនោះទេ។ ចម្លើយដែលមេធាវីការពារក្តីអាចសួរបានដោយផ្ទាល់ គឺសួរបទពិសោធន៍របស់គាត់ដោយផ្ទាល់តែម្តង។ ហើយសួរអំពីការយល់ដឹងរបស់គាត់។ ហេតុដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការយកចម្លើយអ្នកដទៃមកសួរ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសួរសាក្សីនេះអំពីបទពិសោធន៍របស់គាត់។ ជាការពិត គឺថាវាមានការពាក់ព័ន្ធដោយសារតែលោក ហេង សំរិន បានចូលរួមក្នុងការរំដោះទីក្រុងភ្នំពេញ។ គាត់ចូល -- គាត់ជាកងទ័ពរបស់ខ្មែរក្រហម។ ពីម្សិលមិញ ព្ញសួរសហព្រះរាជអាជ្ញាជជីកសួរសាក្សីថា តើគោលនយោបាយរបស់ខ្មែរក្រហមវាយ៉ាងម៉េចដែរ? ច្បាស់ហើយថា វាពិតជាមានការពាក់ព័ន្ធ ដោយសារថាគាត់ជាមេបញ្ជាការកងពលដែលមានឋានៈខ្ពស់ បានទទួលបទបញ្ជាថា មិនឲ្យសុំអ្វីពីប្រជាជនទេ។ ដូច្នេះ ខ្ញុំសូមត្រឡប់ចូលទៅសំណួររបស់ខ្ញុំវិញ ថាតើសាក្សីរូបនេះ បានទទួលបទបញ្ជាដូចគ្នានេះដែរឬទេ? នេះគឺជាចម្លើយមួយ ដែលមាននៅក្នុងសំណុំរឿង ដែលសហព្រះរាជអាជ្ញា ក៏ត្រូវយកមកយោងនោះ ចង់យកមកធ្វើការ -- យកមកយោងដែរ។ ថាតើសាក្សីនេះ បានទទួលបទបញ្ជាដូចគ្នា ឬក៏មិនដូចគ្នានោះ គឺវាពាក់ព័ន្ធ។

[១១:១០:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៣:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើង គឺត្រឹមត្រូវ មានមូលដ្ឋានសមស្រប។ ដូច្នេះ សេចក្តីជំទាស់នេះ មានប្រសិទ្ធភាព។ លោកមេធាវី មិនអាចលើកយកនូវបទសម្ភាសន៍សាក្សីដទៃទៀត យកមកធ្វើជាមូលដ្ឋានក្នុងការតាំងសំណួរ ចំពោះសាក្សីដែលនៅចំពោះមុខអង្គជំនុំជម្រះដែលកំពុងដេញដោលដូច្នេះបានទេ។ តែលោកអាចតាំងសំណួរណាដែលលោកយល់ឃើញថាចាំបាច់ចំពោះសាក្សីផ្ទាល់នូវបទពិសោធន៍ ដែលគាត់បានឆ្លងកាត់ ឬក៏បានធ្វើការកត់សម្គាល់ដោយខ្លួនគាត់ផ្ទាល់ នៅក្នុងអង្គហេតុដែលពាក់ព័ន្ធបាន។

**លោក ហ្សាស្តើ ប៉ៅ៖**

ខ្ញុំមិនដឹងតើខ្ញុំយល់ស្តាប់លោកប្រធានបានយល់ច្បាស់ពេញលេញនោះៗទេ? បើសិនណាខ្ញុំតាំងសំណួរទៅទៀត ខ្ញុំសុំសួរបញ្ជាក់។ ខ្ញុំសួរលោកប្រធាន ថាតើយើងមិនអាចយកមូលដ្ឋាននៃបទសម្ភាសន៍ដែលមាន E3/1568 នេះ មកតាំងសំណួរបានទេ? អ៊ីចឹង យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាចេញជាករណីយុត្តិសាស្ត្រតែម្តងក្នុងៗរឿងនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ែខល កាណាវាស!

[១១:១៥:១៦]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ កាលពីមុន ខ្ញុំបានប្រើបច្ចេកទេសដូចគ្នាតាំងសំណួរទៅលើសាក្សីដែលខ្ញុំអាចយកចម្លើយ យកបទសម្ភាសន៍ ហើយនៅពេលនោះគឺថាខាងសហព្រះរាជអាជ្ញាមិនបានជំទាស់ទេ ហើយអង្គជំនុំជម្រះក៏បានអនុញ្ញាត។ ឥឡូវហាក់ដូចជាកំពុងតែមានជំហរផ្សេងគ្នានៅពេលដែលសហព្រះរាជអាជ្ញាបានលើកឡើង ហើយអង្គជំនុំជម្រះក៏បានសម្រេចបែបនេះ។ វាមិនមែនជាការច្របូកច្របល់ទេ ប៉ុន្តែសូមឲ្យធ្វើម៉េចឲ្យមានយុត្តិកម្មត្រឹមត្រូវ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់គឺថា យើងមិនធ្វើការជំទាស់ចំពោះមេធាវីការពារក្តីយកចម្លើយមកសួរទៅលើសាក្សីដែលទាក់ទងទៅនឹងអង្គហេតុ ដែលសាក្សីនៅចំពោះមុខកំពុងផ្តល់សក្ខីកម្មនោះទេ។ ការដែលខ្ញុំជំទាស់នេះគឺៗសាក្សីនេះ គឺថាគាត់មិនបានដឹងអំពីសក្ខីកម្មដែលគេសួរពីមុននោះទេ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

[១១:១៦:២៨]

សាក្សីគឺ គេមិនបានសួរសាក្សីអំពីជីវភាពរស់នៅ អំពីផលិតកម្មក្រោយពីការដួលរលំទីក្រុងភ្នំពេញនោះទេ។ ការជំទាស់របស់ខ្ញុំគឺគ្រាន់តែថា វាមិនត្រឹមត្រូវទេការតាំងសំណួរទៅលើប្រធានបទមួយថ្មីដោយយកចម្លើយរបស់ -- បទសម្ភាសន៍របស់សាក្សីផ្សេងមកតាំងសំណួរនោះទេ។ យើងខ្ញុំមិនជំទាស់

ដែលថា សហមេធាវីការពារក្ដីយកចម្លើយរបស់សាក្សីផ្សេង យកអង្គហេតុមកសួរនោះទេ។ ក្នុងករណីនេះគឺយើងខ្ញុំយល់ឃើញថា វាមិនមានលក្ខណៈត្រឹមត្រូវនោះទេ ហេតុដូច្នេះហើយបានខាងសហព្រះរាជអាជ្ញាជំទាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ដើម្បីធ្វើការពន្យល់ និងដោះស្រាយលើបញ្ហានេះ។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាអ្វីដែលអង្គជំនុំជម្រះចង់បញ្ជាក់នោះ គឺថាយើងមានការលំបាកក្នុងការរៀបចំសំណួរសួរដោយមេធាវីការពារក្ដី។ ហើយជាពិសេស គឺឯកសារយោងដែលប្រើពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍លោក ហេង សំរិន។ ការយោងទៅលើឯកសារនោះ ដូចជាមិនមានសារៈសំខាន់អ្វីដើម្បីយកមកចោទសួរសំណួរទេ ពីព្រោះថាសាក្សីត្រូវបានចោទសួរដោយផ្អែកទៅលើការយល់ដឹងផ្ទាល់របស់គាត់។ ចម្លើយរបស់លោក ហេង សំរិន នោះមិនមានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការយល់ដឹងរបស់សាក្សីរូបនេះទេ។ ដូច្នេះ សាក្សីអាចឆ្លើយទៅនឹងសំណួរដែលចោទសួរបាន ក៏ប៉ុន្តែយើងត្រូវផ្ដោតទៅលើការយល់ដឹងរបស់គាត់ផ្ទាល់ ប្រសិនបើគាត់មានការយល់ដឹងផ្សេងពីនេះ នោះមិនអីទេ ខាងមេធាវីការពារក្ដីអាចសួរបាន។

[១១:១៨:៣៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអាចបន្តសំណួរបានហើយ!

**លោក ហ្សាស្តេី ប៉ោ៖**

យើងខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់ថា ខ្ញុំបានយល់ត្រឹមត្រូវជំហររបស់យើងខ្ញុំដែលយកបទ-សម្ភាសន៍របស់លោក ហេង សំរិន នេះគឺថាវាជាបញ្ហានៃ -- វា១ជាកត្តា -- ជាភស្តុតាងដោះបន្ទុកមួយដោយមានកាលៈទេសៈមួយថាមិនត្រូវសុំអ្វីពីប្រជាជន ផែនការនេះវាមកពីមជ្ឈិម ពីថ្នាក់លើ។ ហើយយើងខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើបទបញ្ជាមកពីថ្នាក់លើនេះត្រូវបានបញ្ជូនទៅដល់កម្មាភិបាលថ្នាក់ក្រោមតួយ៉ាងដូចជាលោក គង់ គីម នេះជាដើម ឬក៏យ៉ាងណា? អ៊ីចឹងគឺថាយើងខ្ញុំយល់ថា វាមានការពាក់ព័ន្ធចង់ឲ្យឃើញថាវាមានយុត្តិសាស្ត្រវិជ្ជមានពីថ្នាក់ដឹកនាំខ្មែរក្រហមមកដែរ ដែលត្រូវបានបញ្ជូនទៅដល់

កម្មាភិបាលថ្នាក់ក្រោម។ ដូច្នេះ យើងខ្ញុំសូមស្នើថា យើងខ្ញុំគួរណាតែអនុញ្ញាតឲ្យធ្វើដូចនេះបាន។

[១១:១៩:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១១:២០:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ យើងមិនជំទាស់ទៅនឹងការសួរសំណួររបស់លោកនោះទេ លោកអាចចោទសំណួរបែបនេះបាន។ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺថា គឺយើងប្រើការបញ្ជាក់អះអាងរបស់សាក្សីផ្សេង យកមកសួរសាក្សីនេះ។ ប្រសិនបើលោកពិនិត្យឃើញថា មានការឆ្លើយផ្សេងបែបនោះនោះ លោកអាចយោងទៅលើឯកសារផ្សេងទៀតបាននៅក្នុងសំណុំរឿង។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺថាសំណួរបែបនេះគឺមិនមានភាពពាក់ព័ន្ធច្បាស់លាស់នោះទេ ដូច្នេះអាចផ្លាស់ប្តូរនូវប្រភេទសំណួររបស់លោកបាន។ ក៏ប៉ុន្តែជាគោលការណ៍នោះ យើងមិនជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះ ដែលមាននៅក្នុងសំណុំរឿងដើម្បីធ្វើជាមូលដ្ឋានសម្រាប់សួរសំណួរនោះទេ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ លោកចៅក្រម ឡាវែន៍ ដែលលោកបានបញ្ជាក់យ៉ាងច្បាស់លាស់នេះ។

[១១:២១:០៥]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោក គង់ គីម តើលោកបានទទួលបញ្ជាដែរឬទេ នៅពេលដែលលោកជាកងទ័ព ថាកុំឲ្យសុំអ្វីពីប្រជាជនឲ្យសោះ គឺថាត្រូវតែឧបត្ថម្ភខ្លួនឯង?

**លោក គង់ គីម៖**

**ឆ៖** បាទ ពេលដែលខ្ញុំធ្វើកងទ័ពនៅសមរភូមិមុខនេះ គឺថាមិនបានទទួលបទបញ្ជា អំពីការឧបត្ថម្ភស្បៀងពីប្រជាជន ឬក៏ឲ្យកងទ័ពធ្វើស្រែដើម្បីផ្គត់ផ្គង់ស្បៀងទៅជាប្រជាពលរដ្ឋ គឺអត់មានបានទទួល។ គឺទទួលតែបទបញ្ជា គឺវាយខ្លាំងតែប៉ុណ្ណឹង គឺថាបទបញ្ជាផ្សេងៗអត់ដែលមាន។

**ស៖** យោងទៅលើសម្រង់មួយដែលខ្ញុំទើបតែអានទៅលោក ដែលលោក ហេង សំរិន គាត់បានមានប្រសាសន៍អំពីបទពិសោធន៍របស់គាត់ គាត់បានលើកឡើងថា “នៅពេលនោះយើងបានទទួលផែនការ

ពីមជ្ឈិម ពីថ្នាក់លើ ដើម្បីឲ្យយើងពាក់ព័ន្ធទៅនឹងការបង្កបង្កើនផល ខ្លួនឧបត្ថម្ភខ្លួន ហើយក្នុងពេលណាក៏ដោយមិនត្រូវសុំអ្វីពីប្រជាជនសោះឡើយ។ កងទ័ពត្រូវតែឧបត្ថម្ភខ្លួនឯង"។ ដូច្នេះ ខ្ញុំសូមរំឭកថា លោក ហេង សំរិន គឺគាត់ជាមេបញ្ជាការកងពលនៅពេលនុ៎ង។ តើលោកដឹងទេថា មេបញ្ជាការកងពលរបស់លោក លោក អឿន នេះបានទទួលបញ្ជាដូចគ្នា ប្រហាក់ប្រហែល -- បានទទួលបញ្ជាដូចគ្នាពីមជ្ឈិម ពីថ្នាក់លើដែរឬទេ?

[១១:២២:៥៧]

**ឆ៖** បាទ ផែនការហ្នឹងមុនវាយចូលទីក្រុងភ្នំពេញ គឺថាខ្ញុំក្តាប់មិនបាន។ ពេលដែលយើងរំដោះភ្នំពេញបានហើយ នៅពេលក្រោយដែលយើងរក្សាតាមទីតាំងគោលដៅហើយ គឺខ្ញុំបានដឹងផែនការមួយ គឺថាគេឲ្យកងទ័ពមួយចំនួនទៅតាម "គ" ហ្នឹង បញ្ជេញទៅធ្វើស្រែនៅអន្លង់ក្ងាន។ នេះពេលដែលយើងបែកទីក្រុងភ្នំពេញហើយ។ តែពីមុនបែកភ្នំពេញ គឺអត់មានផែនការហ្នឹងទេ។

**ស៖** សូមអរគុណ។ នេះជាចម្លើយច្បាស់លាស់ហើយ។ ប៉ុន្តែសំណួរជាក់លាក់របស់ខ្ញុំនេះ ថាតើលោកមានបានដឹងទេ ថាមេបញ្ជាការកងពលរបស់លោកឈ្មោះ អឿន នេះ បានទទួលបញ្ជាដូចគ្នាដែលអ្វីលោក ហេង សំរិន បានអះអាងថា គាត់បានទទួលបញ្ជាពីមជ្ឈិមនោះ? បើសិនណាលោកមិនដឹងក៏មិនបញ្ហាអ្វីដែរ។

**ឆ៖** អ៊ីចឹងបញ្ហានេះខ្ញុំអត់ដឹងទេ។ រឿងនេ៎ះ ចំពោះប្រធានកងពលដែលបានបញ្ជាពីថ្នាក់លើមក។ ប៉ុន្តែខ្ញុំបានដឹងត្រង់ថា ក្រោយដែលយើងរៀបចំទីក្រុងភ្នំពេញបានរាបហើយ នៅក្នុងវរសេនាតូចខ្ញុំនេះ គេចាត់តាំងមួយ "គ" បានន័យថា មួយអនុសេនាធំ បញ្ជេញទៅធ្វើស្រែនៅអន្លង់ក្ងាន។

[១១:២៤:៣៤]

**ស៖** សូមអរគុណចំពោះចម្លើយនេះ។ និយាយរួមទៅ (សូមអធ្យាស្រ័យ) និយាយរួមគឺលោកបាននិយាយអំពីបញ្ហានេះកាលពីម្សិលមិញនិងថ្ងៃនេះរួចហើយ តែខ្ញុំគ្រាន់តែចង់សួរបញ្ជាក់ឲ្យច្បាស់។ ថាតើលោកមុន ឬក៏ក្រោយពេលចូលទីក្រុងភ្នំពេញនេះ បានទទួលបញ្ជាជាលាយលក្ខណ៍អក្សរណាមួយទេ គឺថាបញ្ជានេះគឺជាបញ្ជាផ្ទាល់មាត់ ឬក៏ជាបញ្ជាលាយលក្ខណ៍អក្សរ?

**ឆ៖** បាទ នៅក្នុងសម័យនុ៎ង ការបញ្ជាហ្នឹងគ្មានជាលាយលក្ខណ៍ដោយអក្សរទេ ឃើញថាការប្រជុំ ការប្រាប់ ការបញ្ជាដោយមាត់បាទ។

**ស៖** ហើយនៅមុនរំដោះភ្នំពេញ នៅពេលលោក គឺថាសម្រុកចូលមកភ្នំពេញនេះ តើគ្រប់ពេលទាំងអស់លោកបានរាយការណ៍ថា លោកបានបាញ់ទាហានភាគីម្ខាងទៀតជូនទៅថ្នាក់លើរបស់លោកជូនទៅមេផ្ទាល់របស់លោកដែរទេ?

**ឆ៖** បាទ នៅពេលប្រយុទ្ធសម្រុកចូលទីក្រុងភ្នំពេញនេះ ដោយនៅពេលនោះខ្ញុំនៅតូចផង ហើយភារកិច្ចជាយុវជន។ អ៊ីចឹង ខ្ញុំពុំបានធ្វើការរាយការណ៍ទៅថ្នាក់លើជាបន្តបន្ទាប់ទេ គឺភារកិច្ចនេះទៅតាមតួនាទីដែលគេអ្នកគ្រប់គ្រងខ្ញុំពីលើ។

[១១:២៦:២៧]

**ស៖** ពីម្សិលមិញលោកបានជម្រាបជូនតុលាការថា ខ្ញុំសូមដកស្រង់ចេញពីប្រតិចារឹកនៅលើទំព័រ៧៧ សវនាការថ្ងៃ១,២,៣ (១២៣)។ ពីម្សិលមិញគឺលោកបានឆ្លើយ ខ្ញុំសូមដកស្រង់ "ក្រោយពីទទួលបញ្ហា ខ្ញុំមានការពាក់ព័ន្ធនៅក្នុងសមរភូមិប្រយុទ្ធ ខ្ញុំមិនដែលជួបជនស៊ីវិលទេ ខ្ញុំជួបតែទាហាន។ យើងគឺថា បានវាយប្រយុទ្ធគ្នាជាមួយនឹងទាហានម្ខាង ប៉ុន្តែយើងមិនដែលធ្លាប់បានជួបជនស៊ីវិលនៅក្នុងសមរភូមិទេ" សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ត្រង់នេះ ថាតើចម្លើយនេះវាត្រឹមត្រូវទេ ដែលថាខ្លួនលោកផ្ទាល់ មិនធ្លាប់បានឃើញជនស៊ីវិលនៅក្នុងសមរភូមិនោះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅក្នុងសមរភូមិដែលយើងប្រយុទ្ធគ្នាជាបន្តបន្ទាប់ មិនទាន់ដល់ជាយក្រុងភ្នំពេញទេ អ៊ីចឹងសមរភូមិដែលមានបន្ទាយទាហាននៅបន្តបន្ទាប់តាមខ្សែក្រវាត់បន្ទាយទាហាន ហើយខ្ញុំក៏នៅជួរខ្សែត្រៀមមុខ។ អ៊ីចឹងក្នុងទីធ្លាកណ្តាលគឺថាពុំមានប្រជាជនទេ។ សូម្បីទាហាន លុះត្រាតែមានផែនការវាឡើងទៅជាវរៈ ជាកង បានមាន។ បាទ ឲ្យថាប្រជាពលរដ្ឋមានដើរកាត់តាមហ្នឹង គឺថាពុំដែលឃើញមាន។

[១១:២៨:១៥]

**ស៖** ហើយក្រោយមក លោកបានចូលមកក្នុងទីក្រុង លោកផ្តល់សក្ខីកម្មថា លោកទទួលខុសត្រូវក្នុងការជម្លៀសប្រជាជនចេញ -- បណ្តេញប្រជាជនចេញពីផ្ទះរបស់ពួកគាត់។ ខ្ញុំសូមដកស្រង់សម្តីរបស់លោក ដែលលោកឆ្លើយជូនខាងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារ 19.96, ERN ជាភាសាអង់គ្លេស 00633875, ERN ជាភាសាខ្មែរ 00054835។ លោកបានឆ្លើយថា នៅក្នុងបទសម្ភាសន៍នោះថា "ប្រជាជនខ្លះ គឺថានៅក្នុងផ្ទះ មានកាំភ្លើង ហើយធ្លាប់ចេះប្រើប្រាស់កាំភ្លើងផង។ ប្រជាជនខ្លះគឺថាបានបាញ់មកកាន់កងទ័ពរបស់យើង នៅពេលកងទ័ពរបស់យើងឡើងទៅលើផ្ទះនោះ ហើយអ្នកខ្លះ

បោះគ្រាប់បែក នៅពេលដែលយើងកំពុងដើរនៅលើដងផ្លូវ" បញ្ចប់ការដកស្រង់។ ដូច្នេះ នៅត្រង់នេះ លោកនិយាយអំពីប្រជាជននៅក្នុងផ្ទះរបស់គាត់នៅពេលហ្នឹង ប្រជាជននៅក្នុងផ្ទះមានបទពិសោធន៍ ហើយចេះប្រើប្រាស់កាំភ្លើងនោះទៀតផង។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា តើប្រជាជនហ្នឹងជាជនស៊ីវិល ឬក៏ជាទាហាន ឬក៏ជាទាហាន ប៉ុន្តែស្លៀកឯកសណ្ឋានជាជនស៊ីវិល ឬក៏យ៉ាងម៉េច?

[១១:២៩:៤៨]

**ផ៖** បាទ សភាពការណ៍ដែលមានគប់គ្រាប់បែក មានបាញ់នេះ ក្រោយដែលយើងបានជម្លៀសប្រជាជនចំនួនច្រើនដែលអស់ហើយ។ អ៊ីចឹងអ្នកដែលមិនបានចុះ មកដល់ដី ដែលជម្លៀសទៅតាមផែនការដែលគេផ្សព្វផ្សាយតាមមីក្រូនេះ។ អ៊ីចឹងជាផែនការរបស់ថ្នាក់លើដូចជាខ្ញុំបានទទួលពីថ្នាក់អនុសេនាតូចមកនេះ ឲ្យយើងបោសសម្អាតមនុស្សនៅផ្ទះចំពោះដីឡូត៍ដែលយើងទទួលខុសត្រូវ។ តែអ្នកដែលនៅក្រាញនេះ គឺថាជួនកាលយើងដើរទៅមានគប់គ្រាប់បែកពីលើ។ អ៊ីចឹង ការគប់គ្រាប់បែកនេះ យើងអត់បានមើលឃើញមនុស្សទេ ឃើញតែធ្លាក់គ្រាប់បែកមក មកដល់ក្រោម។ អ៊ីចឹងគេមានបញ្ជាឲ្យមានបទបញ្ជាថា ព័ទ្ធហើយឲ្យឡើងទៅ។ អ៊ីចឹងពេលដែលយើងឡើងទៅនេះ ឃើញថាក្នុងចំណោមបីបួននាក់វាមានទាហានហ្នឹងស្លៀកខោអាវទាហានពីរអីទៅ មានប្រជាជនហ្នឹង ប៉ុន្តែប្រជាជនអត់មានតូចទេ អត់មានក្មេងក្មេងទេ សុទ្ធតែអ្នកដែលអាចប្រើប្រាស់អាវុធបានបាទ។ អ៊ីចឹងផែនការការងារហ្នឹងហើយដែលថា ទទួលបទបញ្ជាថា ក្នុងដីឡូត៍យើងត្រូវកម្ទេចបាទ ត្រូវកម្ទេច ព្រោះថា បើសិនជាយើងទៅមិនកម្ទេច ពួកនុ៎ងគឺវាបាញ់ទ័ពខាងខ្ញុំ។

[១១:៣១:១០]

**ស៖** តើជាការសង្ខេបត្រឹមត្រូវតាមពាក្យរបស់លោកដែរទេ ដែលនិយាយថា នៅពេលដែលចូលមកដល់កន្លែងនោះ ហើយលោកមិនបាននិយាយឲ្យបានប្រាកដទេ ថាមិនដឹងថាអ្នកណាទេ ច្បាស់ជាអ្នកបាញ់មកខាងលោកនោះ?

**ផ៖** បាទ ពេលដែលយើងប្រតិបត្តិការទៅ យើងដឹងថា ពេលដែលមានគ្រាប់បែកធ្លាក់ពីលើផ្ទះ ហើយមកចំខាងកងទ័ពខ្ញុំ ហើយពេលខ្លះមានបាញ់ពីលើផ្ទះ យើងកំណត់ថា ផ្ទះនេះមានទាហាន។ បានន័យថាជាខ្មាំងនៅលើផ្ទះនេះ។ អ៊ីចឹងផែនការរបស់ថ្នាក់លើដែលជាអ្នកបញ្ជាផ្ទាល់របស់ខ្ញុំនឹងឲ្យយើងធ្វើការឡោមព័ទ្ធ ហើយនិងធ្វើការបោសសម្អាតទៅលើផ្ទះហ្នឹង។

[១១:៣២:១៣]

**ស៖** ហើយឥឡូវនេះ លោកបានបញ្ជាក់ចម្លើយនោះថា គេបានគប់គ្រាប់បែកមក ហើយខ្ញុំសូមដកស្រង់ចម្លើយរបស់លោកថា "មានមនុស្សនៅក្នុងផ្ទះនេះក៏គេមានអាវុធ ហើយមានបទពិសោធន៍ក្នុងប្រើ ហើយគេឲ្យ គេបាញ់មកខាងយើងមុន មុននៅពេលដែលយើងឡើងទៅលើផ្ទះនោះ"។ តើលោកដឹងទេអ្នកណាជាអ្នកបាញ់មកខាងក្រុមរបស់លោកនោះ?

**ឆ៖** បាទ សកម្មភាពហ្នឹងគឺថាពិនិត្យជាក់ស្តែង គឺជាទាហាន អ៊ីចឹងនៅពេលវេលាដែលយើងរំដោះភ្នំពេញនេះ មិនមែនជាការឈប់បាញ់ហើយជា១ឯកភាពទូទៅឈប់បាញ់ទេបាទ។ មានខ្លះនៅជាកង ខ្លះនៅជាបុគ្គល ខ្លះនៅជាពួក គឺមានការប្រយុទ្ធ តាមកន្លែង១។ ដូច្នេះថា មិនការឈប់បាញ់ទេថា ឈប់ទូទៅទេ គឺមានតាមបុគ្គលនៅមានការបាញ់បោះគ្នា។

[១១:៣៣:២៦]

**ស៖** តាមអ្វីដែលលោកបានប្រទះឃើញ ថាតើទាហានទាំងអស់នោះដែលបាញ់មកលោកនោះតើអ្នកទាំងអស់នោះស្លៀកពាក់ជាឯកសណ្ឋាន ឬក៏ទាហានខ្លះបានប្តូរសម្លៀកបំពាក់ជាជនស៊ីវិល?

**ឆ៖** បាទ តាមការត្រួតពិនិត្យជាក់ស្តែងដែលយើង ជួនកាលយើងឡោមព័ទ្ធហើយកម្ទេចបាន គឺថានៅឯកសណ្ឋានទាហានបាទ។

**ស៖** តើលោកធ្លាប់ឮដែរឬទេ នៅពេលនោះថា ទាហាន លន់ នល់ ដែលដោះសម្លៀកបំពាក់ឯកសណ្ឋានចេញហើយបន្តធ្វើការវាយប្រហារខ្មែរក្រហមនោះ?

**ឆ៖** បាទ ខ្ញុំបាទនៅសមរភូមិផ្ទាល់ចំពោះភារកិច្ចខ្ញុំ គឺថាមិនដែលឃើញទាហាន លន់ នល់ដែលដោះខោអាវទាហានហើយ មកបាញ់ទាហានខាងក្រៅ អត់ដែលមាន។ តែចំពោះទាហាន ខាងក្រៅគឺបានដោះខោអាវខ្លួនហើយពាក់ខោអាវទាហាន ធ្វើឲ្យទាហាខាងក្រៅ និងខាងក្រៅមានការបាញ់គ្នាស្លាប់។

[១១:៣៥:១០]

**ស៖** សូមអរគុណដែលលោកបានឆ្លើយចម្លើយនេះ។ លោកក៏បាននិយាយផងដែរកាលពីម្សិលមិញ គឺនិយាយអំពីការអនុវត្តចំពោះការជម្លៀសប្រជាជន។ ហើយខ្ញុំនឹងដកស្រង់មកពីទំព័រ១០៤នៃប្រតិចារឹកនៅបន្ទាត់ទី៨ នៅម៉ោង នាទី២៦:០៨។ ហើយខ្ញុំសូមដកស្រង់ "តាមការពិត នៅពេលដែលគេជម្លៀសប្រជាជន មិនមានការបាញ់តទាល់គ្នារវាងទ័ពខាងក្នុង និងខាងក្រៅ។ ក្រោយមក ប្រជាជនមិនត្រូវបានរងការ រងគ្រាប់កាំភ្លើងទេ។ ហើយបើមានការបាញ់គ្នានៅក្នុងជនស៊ីវិល ពេលនោះគឺអាចនឹង

ត្រូវជនស៊ីវិលខ្លះ។ បើត្រង់កន្លែងណាដែលមានសុទ្ធតែប្រជាជនស៊ីវិល គឺយើងមិនទទួលបញ្ជា គេមិនបញ្ជាឲ្យយើងបាញ់នោះទេ"។ ចប់សេចក្ដីដកស្រង់។ តើនេះជាការសមស្របដើម្បីសង្ខេបចម្លើយរបស់លោកដែរឬទេ? ប្រសិនបើមានការប្រយុទ្ធគ្នាបាញ់ចេញពីកន្លែងណាមួយមក ពេលនោះគេបញ្ជាឲ្យលោកបាញ់ត្រឡប់ទៅវិញ។ ប៉ុន្តែបើកន្លែងណាសុទ្ធតែមានជនស៊ីវិល មិនមានការបញ្ជាឲ្យបាញ់ទៅលើជនស៊ីវិលទេ។ តើត្រូវដែរឬទេបែបនេះ?

**ផ៖** បាទ នៅក្នុងចំណុចនេះ ប្រជាពលរដ្ឋដែលមានការគ្រោះថ្នាក់ ដូចជាបញ្ហានៅតាមដងផ្លូវថ្នល់ចាប់ពីព្រែកព្នៅទៅភ្នំពេញ។ ព្រោះកន្លែងនេះគឺមានប្រជាពលរដ្ឋខាងក្នុងរស់នៅខ្លះ ហើយកន្លែងនេះនៅជាសមរភូមិនៅឡើយបាទ។ អ៊ីចឹងទាហាននៅមានការតតាំងជាមួយទាហានអ្នកក្រៅ។ ក្រោយដែលយើងរំដោះចូលដល់ទីក្រុងភ្នំពេញ គឺថាដែលពេលជម្លៀសប្រជាជនកកកុញ គឺថាអាវុធអត់មានផ្ទុះទេ។ អ៊ីចឹងប្រជាពលរដ្ឋ គឺមានការធ្វើដំណើរកកកុញទៅតាមផ្លូវ។ អ៊ីចឹងយើងឃើញថាការច្របូកច្របល់មនុស្សច្រើនពិតមែន ទាំងកងទ័ពខាងក្នុង កងទ័ពខាងក្រៅ ប៉ុន្តែអាវុធ គឺមានការស្ងប់ស្ងាត់ដែលពេលចូលដល់ក្រុងភ្នំពេញ។

ក្រោយមកដល់ពេលយើងជម្លៀសចេញអស់ ចំនួនភាគច្រើន អាវុធចាប់ផ្ដើមផ្ទុះវិញ។ បាទ ផ្ទុះអាពួក ផ្ទុះជាក្រុម ដោយឆ្នក់ ដោយមានលាក់ពួកនូវទាហានខ្លះដែលតាមផ្ទះថ្មហ្នឹង ធ្វើឲ្យមានការផ្ទុះអាវុធបន្តបន្ទាប់វិញ។

[១១:៣៨:០០]

**ស៖** ដូចដែលលោកបានធ្វើសក្ខីកម្មរួចមកហើយផងដែរ។ លោក ឬក៏កងរបស់លោកក៏បានប្រទះឃើញអតីតទាហាន លន់ នល់ ហើយលោកក៏បានឆ្លើយផងដែរ កាលពីម្សិលមិញនៅពេលដែលសហព្រះរាជអាជ្ញាសួរលោកនោះ។ ខ្ញុំដកស្រង់ចេញពីទំព័រ១០៦ បន្ទាត់ទី២៣ ចម្លើយរបស់លោកឆ្លើយថា "នៅពេលដែលមកដល់ភ្នំពេញទាហានដែលមិនៗច្បាំងតបទេ ហើយយល់ព្រមទៅជាមួយប្រជាជនយើងឲ្យគេទៅចុះ។ ប៉ុន្តែអ្នកដែលប្រយុទ្ធជាមួយយើង ដែលនៅក្នុងក្រុមរបស់គេ មិនព្រមចុះចាញ់ យើងត្រូវបាញ់ពួកអ្នកទាំងនោះ" ចប់សេចក្ដីដកស្រង់។ ហើយលោកក៏បានឆ្លើយផងដែរលើប្រធានបទនេះកាលពីមុន ចំពោះមុខអ្នកតំណាងរបស់ ឌី.ស៊ី.ខេម គឺឯកសារ 1996, អង់គ្លេស ERN 00633878, ខ្មែរ ERN 00054839។ នៅលើទំព័រនេះលោកបាននិយាយថា "ម្នាក់ៗត្រូវតែចាកចេញរួមទាំងទាហានរបបមុនផង ហើយបើសិនជាទាហានដែលស្លៀកពាក់ឯកសណ្ឋានមិនអាចរស់នៅយូរទេ ប៉ុន្តែបើសិន

ជាគេដោះចេញ គឺគេអាចទៅបាន។

ដើម្បីឱ្យខ្ញុំច្បាស់អំពីបញ្ហានេះ តាមអ្វីដែលបទពិសោធន៍ដែលលោកបានឃើញនោះ តើលោកធ្លាប់ជួបប្រទះទាហានលន់ នល់ ដែលគេផ្តល់ឱកាសឱ្យអ្នកទាំងអស់នោះ ដោះឯកសណ្ឋានចេញ ហើយអនុញ្ញាតឱ្យអ្នកទាំងអស់នោះ ជម្លៀសទៅជាមួយប្រជាជនដែរឬទេ? តើអ៊ីចឹងដែរឬទេ តាមអ្វីដែលលោកបានជួបប្រទះនោះ?

**ឆ៖** បាទ ពេលដែលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្ញុំបាទបានឃើញផ្ទាល់ដែលពេលមានការធ្វើដំណើរចេញទៅតាមផ្លូវជាតិលេខ៥ហ្នឹង ដែលចេញពីជ្រោយចង្វាទៅ ឃើញថាការចេញទៅនេះ លាយឡំទៅដោយទាហាន ប៉ុន្តែទាហានអត់មានអាវុធ បាទ។ ហើយព្រះសង្ឃ ប្រជាពលរដ្ឋទូទៅ ធ្វើដំណើរដោយណែនផ្លូវអ៊ីចឹង។

[១១:៤០:៥៥]

អ៊ីចឹង ដកតែអាវុធ រឿងដែលទាហាននៅខោអាវទាហាន គឺអត់បានបែងចែកក្រៅពីប្រជាជន គឺថាធ្វើម៉េចទីក្រុងភ្នំពេញនេះ ឱ្យតែអ្នកនៅខាងក្នុង រើចេញឱ្យអស់ ទាំងទាហាន ទាំងស៊ីវិល ទាំងព្រះសង្ឃ។ ទីក្រុងភ្នំពេញ បានន័យថា ទុកតែទ័ពចូលមកពីក្រៅ មកនៅទីក្រុងភ្នំពេញវិញ។

**ស៖** តាមអ្វីដែលលោកអាចនៅចាំបាន ហើយលោកនៅចងចាំនោះ តើនយោបាយរបស់ខ្មែរក្រហម របស់ទាហានខ្មែរក្រហមនោះ គឺៗទុកឱ្យពួកទាហានលន់ នល់ គេទម្លាក់អាវុធរបស់គេ ហើយមិនឱ្យយកអាវុធទៅជាមួយទេ។ តើបែបនេះ ឬយ៉ាងម៉េច?

**ឆ៖** បាទ ជាគោលនយោបាយថ្នាក់លើ ខ្ញុំមិនអាចដឹងបានទេ។ គោលបំណងដែលឱ្យទម្លាក់អាវុធចេញយ៉ាងណាៗនោះ ខ្ញុំអត់ដឹង។ ប៉ុន្តែក្នុងបទបញ្ជាកងទ័ព ឃើញថាទាហានក៏ដោយ តែនៅអាវុធនៅដៃ គឺថាបើអត់លើក គឺមានកម្ទេច។ ព្រោះអ្នកដែលមានអាវុធហ្នឹង សម្រាប់បាញ់តទល់ជាមួយទាហានខាងក្រៅ។ តែបើស្លៀកខោអាវទាហានពុំមានអាវុធ គឺយើងចាត់ទុកដូចជាប្រជាជន។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយចម្លើយនេះ។ ថ្ងៃនេះ លោកក៏បាននិយាយហើយដែរ អំពីអ្វីដែលថាប្រជាជនអាចយកទៅជាមួយបាន ហើយខ្ញុំមានពេលខ្លីខ្ញុំមិនសួរលម្អិតទេ។ ខ្ញុំគ្រាន់តែសួរបន្ថែម តាមអ្វីដែលលោកបានប្រទះឃើញ តើប្រជាជនទាំងនោះ អាចយកទ្រព្យសម្បត្តិផ្ទាល់បានទៅជាមួយទេ ប្រសិនបើគេចង់យកនោះ?

[១១:៤៣:១៥]

**ឆ៖** បាទ ពេលដែលជម្លៀសចេញ ខ្ញុំបាទបានឃើញផ្ទាល់ ឃើញថាចំពោះបញ្ហាប្រាក់ ឬទ្រព្យសម្បត្តិ គឺថាអត់មានការហាមឃាត់ទេ បាទ។ ដាច់ឡែកតែអាវុធមួយដែលភារកិច្ចទ័ពខាងខ្ញុំនេះ ត្រូវដក។ ជាសម្ភារៈមាស ប្រាក់ ឬមួយក៏សម្ភារៈប្រើប្រាស់សម្រាប់ផ្ទាល់ខ្លួន គឺអត់មានបញ្ហាអីដកទេ។

**ស៖** តើលោកបានឃើញប្រជាជនយកទ្រព្យសម្បត្តិអ្វីក្រៅពីអលង្ការ ក្រៅប្រាក់កាសដែរឬទេ? តើអ្នកទាំងនោះ មានសេរីភាពខ្លះក្នុងការយកទ្រព្យសម្បត្តិខ្លះទៅជាមួយដែរឬទេ?

[១១:៤៤:១០]

**ឆ៖** បាទ ខ្ញុំឃើញផ្ទាល់អំពីបញ្ហាជម្លៀសប្រជាពលរដ្ឋចេញនេះ គឺថាដោយឡែក គឺថាការបង្ខំឲ្យចេញនេះ វាមិនមែនតាមការស្ម័គ្រចិត្តទេ តែសម្ភារៈគាត់ខ្លះ រែក ខ្លះទូល ហើយក៏ខ្លះក៏រុញឡាន ហើយកកកុញនឹងផ្លូវនេះ។ បញ្ហានេះ គឺថាចំពោះប្រជាពលរដ្ឋតាមគំនិត គាត់យកអី គឺជារឿងរបស់គាត់។ តែរឿងខាងខ្ញុំនេះ អត់ឲ្យមានដក អត់មានទាញចេញទេ គឺថាដំណើរដែលគាត់យកអី យកបានយកទៅ។

**ស៖** សូមអរគុណ ខ្ញុំច្បាស់ហើយ។ ប្រធានបទមួយទៀតដែលលោកបានឆ្លើយដោយសង្ខេបពីព្រឹកមិញនេះ គឺដូចខាងក្រោមនេះ៖ លោកបាននិយាយអំពីហេតុការណ៍ដែលថាទីក្រុងត្រូវបានបែងចែកទៅជាតំបន់ផ្សេងៗ ក្រៅពីការរំដោះទីក្រុងភ្នំពេញ។ តើលោកដឹងដែរឬទេ គេបានបែងចែកទៅជាប៉ុន្មានផ្នែក ប៉ុន្មានតំបន់នៅ ក្នុងទីក្រុងភ្នំពេញក្រោយពីរំដោះនោះ?

**ឆ៖** បាទ បញ្ហាច្រើនផ្នែក ពិតមែន ប្រាកដមែន ប៉ុន្តែខ្ញុំមិនអាចដឹងថា ភូមិភាគមានប៉ុន្មាន ហើយភូមិភាគណាទទួលចំណុចណា។ ខ្ញុំបាទដឹងតែថាភូមិភាគរបស់ខ្ញុំនេះ ដឹងឬកតែត្លួនាទីតួចរបស់ខ្ញុំទេ គ្រាន់តែឡូត៍មួយកងពលនេះ អត់បានដឹងផងបាទ។ ហើយនៅភូមិភាគដទៃៗ ខ្ញុំមិនអាចដឹងថាគេបែងចែកកំណត់ពីត្រឹមណាៗ ខ្ញុំអត់ដឹង។

**ស៖** ដើម្បីឲ្យច្បាស់លើបញ្ហានេះ តំបន់ ទិសដៅដែលអង្គភាពរបស់លោកត្រួតត្រានោះ ក្រោយពីរំដោះទីក្រុងភ្នំពេញ តើជាកន្លែងដដែល ដែលលោកបានឆែកឆេរនៅក្នុងអំឡុងពេលដែលជម្លៀសទីក្រុងភ្នំពេញហ្នឹងដែរឬទេ?

**ឆ៖** បាទ ផែនការជម្លៀសនេះ វាមួយ គឺដាក់បន្ទុកទៅលើភូមិសាស្ត្ររបស់កងពល តែខ្ញុំនេះគឺជាមុខសញ្ញាមួយតូចទទួលខុសត្រូវក្នុងមួយក្រុមនេះ គឺទទួលខុសត្រូវជម្លៀសតែប្រជាពលរដ្ឋនៅក្នុងប្លុកដែលខ្ញុំទទួលខុសត្រូវ។

[១១:៤៧:១៧]

**ស៖** ខ្ញុំគិតថាលោកបានឆ្លើយសំណួរខ្ញុំហើយ ក៏ប៉ុន្តែខ្ញុំចង់ឲ្យច្បាស់ ហើយខ្ញុំនឹងសួរឡើងវិញក្នុងវិធីផ្សេងពីហ្នឹងបន្តិច។ ទីកន្លែង ឬក៏ទិសដៅដែលលោកត្រូវឈរជើង ឬធ្វើការកន្លែងមួយដែលលោកនិយាយគឺថា ដែលថាលោកមិនអាចចេញពីកន្លែងតូចដែលគេចាត់តាំងឲ្យធ្វើការបាននោះទេ។ ថាតើកន្លែងនោះជាកន្លែងតែមួយដែលលោកបានផែកឆេរទៅលើផ្ទះមួយចំនួននៅក្នុងថ្ងៃទី១៧ ខែមេសា ឬក៏បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ហ្នឹង ឬក៏ជាកន្លែងផ្សេងខុសពីកន្លែងដែលលោកចូលមកកាន់កាប់ដំបូងនោះ?

**ឆ៖** បាទ ពេលចូលដល់ទីក្រុងភ្នំពេញនេះ ចំពោះខ្ញុំនៅក្នុងក្រុមខ្ញុំនេះ អនុសេនាតូចខ្ញុំនេះ មិនទាន់បានទទួលផែនការជម្លៀសពី អ៎! ជម្លៀសប្រជាពលរដ្ឋចេញទេ។ ប៉ុន្តែគ្រាន់តែចូលមកដល់ប្រជាពលរដ្ឋគឺមានការចុះចេញ ការធ្វើដំណើរតាមផ្លូវជាហូរហែ គឺថាណែនណាន់តាន់តាប់ នេះជាផែនការថ្នាក់លើ ហើយខ្ញុំកំណត់មកដល់ទីតាំងដែលគេឲ្យឈរហ្នឹង គឺប្រមូលកម្លាំងដែលទទួលខុសត្រូវហ្នឹងឈរ នៅទីកន្លែងហ្នឹង ហើយគ្រាន់តែត្រួតពិនិត្យ ដែលប្រជាពលរដ្ឋដែលចេញទៅ ត្រួតពិនិត្យសំខាន់គឺទាហានដែលមានអាវុធបាទ។ ត្រូវដកអាវុធទុកតែប៉ុណ្ណឹង។ តែផែនការដែលដើរសម្អាតតាមផ្ទះ តាមសម្បែងនេះ ជាផែនការក្រោយដែលប្រជាជនគគ្រឹកគគ្រេងបានចេញអស់។ អាហ្នឹងជាផែនការក្រោយ។

[១១:៤៩:០៥]

**ស៖** សូមអរគុណដែលលោកបានផ្តល់ការបំភ្លឺបែបនេះ។ នៅពេលដែលលោកនៅក្នុងផ្នែកមួយនៃ ទីក្រុងដែលអង្គភាពរបស់លោកកាន់កាប់ ដែលហៅថាជាទិសដៅដែលលោកឈរជើង ឬក៏ធ្វើការនោះ។ សំណួរសួរថា ហេតុអ្វីបានជាលោកមិនអាចដើរចេញពីកន្លែងមួយ ដែលជាកន្លែងតូចដែលលោកទទួលខុសត្រូវ នោះទៅកន្លែងផ្សេងទៀតបាននោះ?

**ឆ៖** បាទ នៅពេលនោះគឺថា គេកំណត់ អ៊ីចឹងបានថាកំណត់អត់មានយើងចូលទៅប្លុកគេទេ គឺថាជាបទបញ្ជា។ បទបញ្ជាបើយើងទទួលខុសត្រូវនៅកន្លែងណា គឺយើងនៅកន្លែងនោះ។ បើយើងចេញពីកន្លែងយើងទៅផ្សេង បានន័យថា យើងចាកពីវិន័យបទបញ្ជា គេចោទថាយើងជាល្មើសនឹងបទបញ្ជា។ អ៊ីចឹង យើងអាចមានទោស។

**ស៖** តើមានទាហានប៉ុន្មាននាក់នៅក្នុងកន្លែងតូចមួយ ដែលលោកត្រូវឈរជើង ដែលថាលោកមិនអាចចេញក្រៅពីកន្លែងហ្នឹងបាននោះ? បាទ ខ្ញុំចង់ឲ្យលោកឆ្លើយជាក់លាក់ថា មានគ្នាប៉ុន្មាននាក់ជា

ទាហានក្រុមរបស់លោកនោះ?

[១១:៥០:៤៤]

**ឆ៖** បាទ ទាហានដែលខ្ញុំចូលដល់ទីក្រុងភ្នំពេញនេះ នៅក្នុងក្រុមរបស់ខ្ញុំផ្ទាល់ គឺនៅសល់គ្នាតែប្រាំពីរនាក់ទេ ដោយការស្លាប់ពេលវាយចូលក្នុងភ្នំពេញនេះ។ អ៊ីចឹង បណ្ដោយដែលឲ្យស្គាល់គ្នា គឺចំនួនបីក្រុម ដែលមានផ្លូវចាប់ពីវត្តភ្នំ ឆ្ពោះទៅជើងទៅទល់នឹងក្បាលស្ពានជ្រោយចង្វានេះ គឺមានទទួលខុសត្រូវបីក្រុម។ បីក្រុមនេះ យើងអាចទំនាក់ទំនងសហការគ្នាក្នុងការងារការពារបាទ។ ក្រៅពីនេះទៅ ខគេគឺ កន្លែងគេគឺរឿងគេ បាទ ការទំនាក់ទំនង មានតែមេទេដែលគេចេញចូលបាន។

**ស៖** លោកបាននិយាយអំពីប្លុកនេះ និយាយថាប្លុកហ្នឹងគឺ តើមានប៉ុន្មានប្លុកដែលលោកនិយាយពីប្លុកនេះបាទ?

**ឆ៖** បាទ ការចាត់ចែងរបស់ថ្នាក់អនុសេនាធំ ប្រគល់អនុសេនាតូចនេះ គឺជាភូមិសាស្ត្រដែលគេបង្ហាញផ្ទាល់បាទ។ គេដើរបង្ហាញផ្ទាល់ពីកំណត់ពីត្រឹមណា ទៅទល់ត្រឹមណា ហើយផ្លូវណាទល់នឹងកន្លែងណា គឺយើងអនុវត្តទៅតាមការបង្ហាញផ្ទាល់របស់ថ្នាក់ដឹកនាំ ប្រធានអនុសេនាធំ ដែលគេប្រគល់ឲ្យអនុសេនាតូច។

**ស៖** លោកបាននិយាយអំពីថា លោកកាន់កាប់នៅប្លុកច្រើន។ តើលោកអាចនិយាយឲ្យជាក់លាក់ជាងនេះបន្តិចទេ ទាក់ទងទៅនឹងថា ចំនួនប្លុក ចំនួនទីតាំងហ្នឹង ដែលអង្គភាពរបស់លោកជាអ្នកយាមនោះ?

[១១:៥២:៤៤]

**ឆ៖** បាទ ខ្ញុំបានដឹងតែប្លុកដែលយើងខ្ញុំគ្រប់គ្រងផ្ទាល់ គឺថាមានការតូច។ តែប្លុកកងពលនេះដែលខ្ញុំបានជម្រាបថាច្រើននេះ ជាប្លុករបស់កងពលរបស់វរសេនាធំ របស់វរសេនាតូច ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់កងពល។ អ៊ីចឹង ខ្លួនខ្ញុំមួយនេះ គឺរស់នៅក្នុងកងពលហ្នឹងដែរ។ អ៊ីចឹង ខ្ញុំគ្រាន់តែដឹងថា ប្លុករបស់កងពលនេះមានដីធំ។ ប៉ុន្តែផ្ដាច់ពីកងពលមក ដែលតួនាទីខ្ញុំគឺប្លុកតូច ព្រោះខ្ញុំតួនាទីតូចគេប្រគល់ឲ្យត្រឹមតូចមើលការខុសត្រូវ។

**ស៖** លោកទើបតែបាននិយាយថា មេរបស់លោកមិនអនុញ្ញាតឲ្យលោកដើរទៅណាដោយសេរីទេ តើលោកដឹងដែរថា តើ អឿន គេអនុញ្ញាតឲ្យគាត់ធ្វើដំណើរទៅកន្លែងណាផ្សេងៗទេ នៅក្នុងទីក្រុងនេះ? ដែលថា ទៅកន្លែងពលផ្សេងទៀត ដែលគេមានប្រធានកងពលគេនៅទីនោះ តើ អឿន អាច

ធ្វើអ៊ីចឹងបានទេ?

**ឆ៖** បាទ តាមការជាក់ស្ដែងរបស់ខ្ញុំ ដែលខ្ញុំដឹង ដែលខ្ញុំរស់នៅក្នុងកងពល៣១០នេះ ហើយកងពល៣១០នេះ បានប្រគល់តួនាទីកំណាត់ផ្លូវឲ្យខ្ញុំ។ អ៊ីចឹងពេលដែលកងពលគេធ្វើដំណើរគេ ជិះឡានទៅ ហើយគ្រាន់តែបញ្ជាពីអនុសេនាតូចអ៊ីចឹង ឲ្យការពារ តែចេញពីឡូត៍ខ្ញុំទៅ ត្រង់គាត់ទៅជួបថ្នាក់ណា ឬក៏ប្រជុំថ្នាក់ណា គឺអត់ដឹងទេ។ ពេលគេចូលមកវិញ ឆ្លងកាត់នឹងឡូត៍យើង យើងគ្រាន់តែការពារផុតទៅ គេចូលទៅកន្លែងគេវិញ។ អ៊ីចឹងត្រង់ថា កិច្ចការរបស់គេ គឺយើងអត់ដឹង។

[១១:៥៥:០០]

**ស៖** អ៊ីចឹងមានន័យថា អឿន អាចដើរហើរដោយសេរី ធ្វើដំណើរបាននោះ? ចំពោះលោកវិញ ឬតើលោកដឹងទេ ថាតើគាត់អាចធ្វើដំណើរទៅផ្នែកណាផ្សេងទៀតក្នុងភ្នំពេញ ឬគាត់អាចធ្វើដំណើរតែក្នុងរង្វង់ជាដែនដែលគេកំណត់ឲ្យកងពល៣១០ ហ្នឹងធ្វើការ?

**ឆ៖** បាទ ចំពោះប្រធានកងពលនេះ ខ្ញុំពុំអាចដឹងថា ពេលដែលគាត់ចេញដោលមានផែនការថ្នាក់ធំជាងគាត់ហៅទៅ ឬមួយក៏គាត់ដើរក្នុងសម្រេចចិត្តរបស់គាត់ មិនដឹង។ ដូចជា តួនាទីរបស់ខ្ញុំនេះ ខ្ញុំធ្វើតែតាមតែបទបញ្ជា ពេលប្រធានអនុសេនាតូចហៅអីនោះបានទៅ បើគេមិនហៅប្រគល់តួនាទីនៅត្រង់ណានៅត្រង់ហ្នឹង។ ហើយដូចជា វរសេនាតូច វរសេនាធំនេះគឺមានការឆ្លងកាត់ទៅវិញទៅមក ប៉ុន្តែត្រង់ថា ភារកិច្ចរបស់គាត់ហ្នឹង គាត់ដើរត្រួតពិនិត្យ មិនដឹង ហើយគាត់ទៅប្រជុំកន្លែងកងពល ក៏ខ្ញុំមិនដឹង ហើយកងពលដែលចេញពីកន្លែងឈរជើងរបស់គាត់ នៅពេលដែលចេញកាត់កន្លែងខ្ញុំការពារទៅដឹងតែដើរត្រួតពិនិត្យ មិនដឹងថា គាត់ទៅប្រជុំជាមួយថ្នាក់លើ។ អ៊ីចឹងរឿងផែនការទាំងអស់ថា អត់ដឹងបាទ។

[១១:៥៦:៣៣]

**ស៖** សូមអរគុណលោកសាក្សី ដែលលោកបានឆ្លើយជាក់លាក់ ដែលថាមានប្រយោជន៍សម្រាប់យើងខ្ញុំ ហើយយើងមិនចង់ឲ្យលោកនិយាយស្មាននោះទេ។ លោកបាននិយាយថា លោកត្រូវនៅតែកន្លែងមួយដែលគេចាត់តាំងឲ្យអង្គភាពរបស់លោកយាមនោះឯង។ តើលោកដឹងអ្វីផ្សេងទៀតដែរទេ ថាតើនៅភ្នំពេញហ្នឹងមានហេតុការណ៍អីកើតឡើងទេ នៅខាងក្រៅតំបន់ ដែលលោកយាមការពារនោះ?

**ឆ៖** បាទ ពេលដែលខ្ញុំយាមនេះ គឺគ្រាន់តែបទបញ្ជាឲ្យយាមគឺថា ពេលយប់គឺយាមទាល់ៗព្រឹក ហើយពីស្ដាប់បញ្ជា ឬក៏មានដំណឹង ឬក៏សភាពការណ៍អីផ្សេងៗ ក៏មិនដែលដឹងដែរបាទ។ ក៏មិនដែល

ថ្នាក់លើយកមកផ្សព្វផ្សាយ ថាសភាពការណ៍អីដែលត្រូវកើតឡើង ឬមួយក៏ចលនាត្រូវតតាំងជាមួយអ្នកណា គឺអត់ដែលដឹង។ ដឹងតែភារកិច្ចដែលឲ្យយាមតែប៉ុណ្ណឹង ហើយពេលដែលខ្ញុំយាម ដូចខ្ញុំជម្រាបហើយថា ពេលយប់ក៏មិនដែលឃើញអ្នកណាទេ ឃើញតែថ្នាក់ដឹកនាំ អនុសេនាតូច អនុសេនាធំដែលគេចេញល្បី(?)មើលអ្នកយាមហ្នឹង ក្រែងយើងអត់បានយាមតែប៉ុណ្ណឹង។

**ស៖** តើនេះជាការសង្ខេបត្រឹមត្រូវតាមពាក្យរបស់លោកដែរទេ ដែលលោកមានការដឹងតិចតួចណាស់អំពីហេតុការណ៍នានាដែលកើតឡើងនៅក្នុងទីក្រុងភ្នំពេញនាពេលនោះ?

**ឆ៖** បាទ នេះជាការពិតមែនហើយ ដោយពេលវេលានោះគឺថា ទី១ ខ្ញុំនៅក្មេងផង។ បើប៉ាន់ជាអាយុគឺអាយុត្រឹម១៦ ទៅ១៧ឆ្នាំ ហើយឋានៈនេះតូចណាស់ បាទ តូចណាស់។ ហើយការដែលឲ្យដឹងពីសភាពការណ៍ថ្នាក់លើធំៗ មានផែនការអីផ្សេងៗ គឺថាពុំអាចដឹងបានទេបាទ។ ខ្ញុំដឹងតែត្រឹមភារកិច្ច និងតួនាទីដែលគេប្រគល់ឲ្យខ្ញុំ បាទ។

[១១:៥៩:១០]

**ស៖** សូមអរគុណ។ ខ្ញុំសូមអភ័យទោស ដែលថាខ្ញុំត្រូវត្រឡប់មកបញ្ហានេះឡើងវិញ ប៉ុន្តែខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹង ថាតើអ្វីជាការងារពិតប្រាកដរបស់លោក នៅពេលដែលលោកចូលមកភ្នំពេញ ហើយជាពិសេសទៅទៀតខ្ញុំចង់ដឹង តើផ្នែកណាមួយនៅក្នុងភ្នំពេញដែលលោកចូល ហើយលោកបន្តធ្វើការនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ? ហើយខ្ញុំព្យាយាមចង់ឲ្យលោកពិនិត្យមើលចំណុចជាក់លាក់មួយចំនួនថែមទៀត ដើម្បីឲ្យខ្ញុំបានយល់ច្បាស់ តាមអ្វីដែលលោកឆ្លើយ។ ម្សិលមិញលោក គង់ គីម គឺថាអង្គភាពរបស់លោកទទួលបន្ទុកក្នុងការយាម ការពារប្លុកតូចៗនៃអគារ នៅខាងជើងវត្តភ្នំ។ នៅពេលដែលលោកបានចូលមកភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា នៅពេលដែលលោកជួយក្នុងការជម្លៀសប្រជាជនចេញពីភ្នំពេញនោះ តើការជួយនោះកើតមានឡើងនៅកន្លែងទីតាំងតូច ប្លុកនៃអគារដែលលោកឈរជើង ដែលថានៅខាងជើងវត្តភ្នំហ្នឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំបានឆ្លើយថា ពេលដែលខ្ញុំចូលដល់ទីក្រុងភ្នំពេញនេះ រយៈពេល៣ថ្ងៃដែលចូលមកនេះខ្ញុំពុំបានចូលរួមជម្លៀសប្រជាពលរដ្ឋទេ ប៉ុន្តែខ្ញុំឃើញប្រជាពលរដ្ឋគឺចេញតែម្តង គាត់ដើរចេញណែនៗថ្នល់ ដោយមានផែនការថ្នាក់លើជម្លៀស។ អ៊ីចឹង រឿងខ្ញុំអត់បានទទួលផែនការជម្លៀសទេ ដែលរយៈពេល៣ថ្ងៃមុនដំបូង។ ខ្ញុំស្រួតតែពីទីតាំងដែលគេប្រគល់ឲ្យ ធ្វើម៉េចឲ្យបានដល់កន្លែងទីតាំង ហើយគ្រប់គ្រងកម្លាំងបាទ។ គ្រប់គ្រងកម្លាំងការពារកន្លែងដែលខ្លួនឈរជើងបាទ។ រហូតដល់ក្រោយមក

ដែលប្រជាពលរដ្ឋចេញស្ងប់ស្ងាត់ហើយ គេប្រគល់ឡូត៍ដែលមានផ្លូវហ្នឹង គេឲ្យយើងដើរបោសសម្អាតទៅតាមផ្ទះ ដោយគេដឹងថា មានអ្នកដែលបង្កប់នៅតាមផ្ទះមិនព្រមចេញ។ អ៊ីចឹងបានចម្លើយរបស់ខ្ញុំពីម្សិលមិញ ខ្ញុំនិយាយថា ដោយមានការលាក់ពួននៅលើផ្ទះនេះហើយ បានជាមានផែនការពីថ្នាក់លើគេកំណត់ថាឲ្យគេបិទទឹកបាទ បិទទឹករយៈពេលកន្លះខែ កុំឲ្យអ្នកនៅលើផ្ទះហ្នឹងប្រើប្រាស់បាន។ អាហ្នឹងការរួមចំណែករបស់ខ្ញុំគឺថា ជម្លៀសពេលដែលនៅសល់តិចតួចទេ ដែលជម្លៀសក្រោយទេ តែកំពុងតែបញ្ហាថ្មីៗនោះ ខ្ញុំអត់បានចូលរួមទេ។

[១២:០២:២៦]

**ស៖** ចម្លើយនេះបានធ្វើឲ្យយើងខ្ញុំច្បាស់បន្ថែមទៀត។ ខ្ញុំមានសំណួរបន្ថែមទៀត ដើម្បីឲ្យខ្ញុំយល់បានទាំងស្រុងអំពីចម្លើយរបស់លោក។ លោកបាននិយាយថា នៅថ្ងៃទី១៧ ខែមេសា បន្ទាប់ពីការវាយដណ្តើមនោះគឺថា លោកបានព្យាយាមមកដល់ទីតាំងដែលគេចាត់តាំងឲ្យបានឆាប់ ហើយទីតាំងនោះ -- បាទ និយាយអំពីផ្នែកទីតាំងនោះ ដែលក្រោយមក លោកជាអ្នកទទួលខុសត្រូវលើផ្នែកតូចមួយ ដែលមានប្លុកមួយចំនួន ដែលមានអគារមួយចំនួននៅខាងជើងវត្តភ្នំ។

**ឆ៖** បាទ ដែលពេលខ្ញុំចូលដល់ទីក្រុងភ្នំពេញនេះ អ៊ីចឹងមានការរៀបចំរបស់ថ្នាក់អនុសេនាធំបានប្រគល់ ដើរចង្អុលប្រគល់ទីតាំងឲ្យយើងឈរជើងបាទ។ ពេលដែលមានការជម្លៀសច្របូកច្របល់នេះគឺថា ភារកិច្ចខ្ញុំនេះ មិនបានចូលរួមជម្លៀសទេ ចូលរួមឈរជើង ហើយនិងត្រួតពិនិត្យ។ ទី១ ការពារកម្លាំង។ ទី២ ពិនិត្យពីទាហាន ហើយនិងអ្នកដែលមានអាវុធ បើសិនជាអ្នកដែលដើរតាមថ្នល់ហ្នឹងចេញទៅហើយ ទាហានហ្នឹងបើមានអាវុធ គឺឲ្យអាវុធចេញបាទ។ តែបើសិនជាទាហានហ្នឹងអត់មានអាវុធគឺដើរឲ្យគេដើរទៅជាមួយប្រជាពលរដ្ឋ។ អ៊ីចឹងពេលថ្មីៗរយៈពេល២ថ្ងៃ ៣ថ្ងៃនេះ ខ្ញុំបាទហ្នឹង និងក្រុមខ្ញុំមិនទាន់បានមានការ បទបញ្ជាឲ្យជម្លៀសឡើយទេ។ ការជម្លៀសនេះជាផែនការរបស់ថ្នាក់លើ ហើយជាកម្លាំងដាច់ឡែកពីកងខ្ញុំ។

[១២:០៤:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ និងមេធាវីប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីនៅរសៀលនេះ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១២:០៥:០០]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ លោក នួន ជា សូមអនុញ្ញាតល្ងាចនេះទៅតាមដានពីបន្ទប់ខាងក្រោមនេះ គាត់មានការឈឺក្បាល ឈឺខ្នង ហើយនិងមិនអាចផ្តង់អារម្មណ៍បានល្អ ហើយខ្ញុំនឹងដាក់លិខិតបោះបង់សិទ្ធិជូនអង្គជំនុំជម្រះតាមនីតិវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាព មិនអាចអង្គុយតាមដានក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះបាន។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

[១២:០៥:៥៨]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:២៤]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក គង់ គីម។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ខ្ញុំសូមបន្តសួរទៅលោកអំពីមេបញ្ជាការរបស់លោក គឺលោក អឿន។ តាមបទពិសោធន៍របស់លោក តើ អឿន ជាមេបញ្ជាការមួយ ដែលល្អ ឬក៏មិនមែន?

**លោក គង់ គីម៖**

**ឆ៖** បាទ ខ្ញុំបាទគឺថាក្តាប់មិនបានទេ ពីរឿងល្អ មិនល្អចំពោះមេបញ្ជាការកងពលនេះ។

**ស៖** តើលោកមានដែលទាក់ទងផ្ទាល់ខ្លួនតែម្តង ជាមួយលោក អឿន ដែរទេ?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំបាទនេះបានស្គាល់តែត្រឹមអនុសេនាតូច និងអនុសេនាធំ ហើយនិងវរសេនាតូចនេះ គឺថាមានពេលវេលាយូរណាស់ ដែលបានឃើញម្តងៗ។

**ស៖** ដូច្នេះលោកមិនមានការជជែកលេងដោយផ្ទាល់ខ្លួនអីជាមួយ អឿន ដែលជាមេបញ្ជាការកងពលនេះទេ មែនទេ?

**ឆ៖** បាទ មិនដែលបានជួបជាមួយ ហើយក៏មិនដែលបាននិយាយជាមួយ។ និយាយរួមថាមិនស្គាល់ឲ្យច្បាស់ផង។

**ស៖** លោកបាននិយាយអំពីលោក យីម ក៏ជាមេរបស់លោកដែរ។ តើលោកមានទាក់ទងនិយាយគ្នាអីជាមួយលោក យីម ក្នុងពេលណាមួយដែរទេ?

**ឆ៖** បាទ ចំពោះឈ្មោះ យីម គាត់តួនាទីជាវរសេនាតូចនេះ មិនដែលបានជិតស្និទ្ធជាមួយខ្ញុំទេ ប៉ុន្តែខ្ញុំបានឃើញដោយពេលវេលាដែលគាត់បានមកប្រជុំ បាទចុះមកប្រជុំនៅតាមអនុសេនាធំរបស់ខ្ញុំ។

**ស៖** តើលោកពេញចិត្តគាត់ទេ ក្នុងឋានៈគាត់ជាមេបញ្ជាការរបស់លោកពេលលោកទាក់ទងជាមួយគាត់នុ៎ង?

[១៣:៣៦:១៩]

**ឆ៖** បាទ ពេលដែលខ្ញុំបំពេញភារកិច្ចនៅកងទ័ពនៅក្រោមការដឹកនាំផងប្រធានវរៈនេះ មិនមានការពេញចិត្តអីជាបុគ្គល ជាមនោសញ្ចេតនា គឺអត់មាន។ តែខ្ញុំបាទ គឺថាបានគោរពនូវបទបញ្ជាដែលគាត់បានបញ្ជា គឺគោរពម៉ឺងម៉ាត់ គឺថាបញ្ជាធ្វើយ៉ាងណា គឺយើងខ្ញុំនឹងធ្វើយ៉ាងហ្នឹង។

**ស៖** តើលោកអាចនិយាយបានថា ជាមេតឹងរ៉ឹង តឹងតែង ឬក៏ជាមេមួយដែលមានលក្ខណៈទន់ភ្លន់ក្នុងពេលដែលគាត់ក្តោបក្តាប់លោកហ្នឹង?

**ឆ៖** បាទ បើតាមខ្ញុំដឹង ហើយនិងការដែលធ្លាប់រស់នៅជាមួយ គាត់ជាថ្នាក់ដឹកនាំឃើញថា ឈ្មោះ យីម ហ្នឹងមានការដឹកនាំគឺម៉ឺងម៉ាត់បាទ។ អ៊ីចឹងគឺថាមានការតឹងតែងទៅតាមបទបញ្ជាថ្នាក់លើ ហើយគាត់ក៏មកប្រើយើងខ្ញុំជាថ្នាក់ក្រោម គឺថាមានការម៉ឺងម៉ាត់ដែរ។

**ស៖** ហើយនៅក្នុងរចនាសម្ព័ន្ធនៃកងអនុសេនាធំរបស់លោកហ្នឹង ថាតើមានៗអ្នកណាម្នាក់ដែលតូចជាងលោក យីម ហ្នឹង ដែលតូចជាងលោក យីម ហ្នឹងទាក់ទងជាមួយលោកទេ?

**ឆ៖** បាទ ចំពោះវរសេនាតូចក្រោមគាត់ គឺខ្ញុំមិនដែលបានជួបទេ គឺជួបតែគាត់ ហើយក្រោម

គាត់ហ្នឹងគឺមានតែអនុសេនាធំ បាទអនុសេនាធំឈ្មោះ រ៉េន ហ្នឹង គឺគាត់ឧស្សាហ៍ចុះមកអនុសេនាតូចរបស់យើងខ្ញុំហ្នឹង ហ្នឹងបានស្គាល់ច្បាស់ ហើយនិងបានធ្លាប់និយាយជាមួយ។

[១៣:៣៨:៣៣]

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់នូវសម្រង់មួយ ចេញពីសៀវភៅរបស់អ្នកនិពន្ធឈ្មោះ ហ្វីលីព ស្សូត ហៅថា "ប្រវត្តិនៃសុបិន្តអាក្រក់" គឺ E3/9 ERN ជាភាសាអង់គ្លេស ដែលខ្ញុំត្រូវអានជូននេះគឺ 00396489, ហើយ ERN ជាភាសាបារាំង 800639818 (ស៊ីក)។ សូមដកស្រង់ "ខុសពីបក្សកុម្មុយនីស្តកម្ពុជា គឺថាបក្សកុម្មុយនីស្តគឺដែលផ្តោតទៅលើតែមជ្ឈិមនេះ គឺខ្មែរក្រហមកម្ពុជា គឺវារួមបញ្ចូលគ្នា--

**ប្រធានអង្គជំនុំ៖**

ឈប់! ផ្អាកសិនលោកមេធាវី! ដូចជាមានបញ្ហាផ្នែកខាងបច្ចេកទេសក្នុងការលើកឡើងនូវឯកសារនេះមក ដកស្រង់មកដេញដោល។

[១៣:៣៩:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់ ប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយបំភ្លឺទៅលោកមេធាវី ហ្សាស្គ្រី ប៉ោ ដែលជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ក្នុងការដែលដកស្រង់នូវខ្លឹមសារនៃឯកសារ E3/9 នេះមកក្នុងការតាំងសំណួរសាក្សីរូបនេះ។ ដោយបញ្ហានេះដូចជាអង្គជំនុំជម្រះបានធ្លាប់ជួបប្រទះរួចហើយ ហើយបានដោះស្រាយបញ្ហានេះរួចហើយ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ទោះបីជាស្ថានភាពនេះមិនដូចគ្នាទាំងស្រុងក៏ដោយក៏ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកថា នៅកាលពីសប្តាហ៍មុននៅពេលដែលមានសវនាការបង្ហាញឯកសារ អង្គជំនុំជម្រះបានជម្រាបជូនហើយថា មិនមែនជាការសមស្របនោះទេ ក្នុងការបង្ហាញឯកសារដែលសរសេរដោយសាក្សី ឬក៏អ្នកជំនាញដែលនឹងយើង -- តុលាការស្តាប់នៅថ្ងៃមុខនោះ។ អ៊ីចឹងអានសម្រង់

របស់អ្នកជំនាញមួយដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះនោះ វាមិនមែនជាការសមស្របនោះទេ។ ក៏ប៉ុន្តែពុំមានអ្វីរាំងឲ្យ -- រាំងខាងការពារក្តីប្រើឯកសារ ឬក៏ខ្លឹមសារឯកសារនោះទេ ក្នុងការចោទសំណួរនោះ ក៏ប៉ុន្តែត្រូវតែជៀសវាងក្នុងការផ្តល់សម្រង់ទាំងស្រុងនៅក្នុងសវនាការនេះតែម្តង។ ខ្ញុំគិតថាយើងមិនមែនជំទាស់ ហាមឃាត់មិនឲ្យចោទសំណួរនោះទេ ក៏ប៉ុន្តែហាមឃាត់មិនឲ្យប្រើសម្រង់នេះទាំងស្រុងតែម្តង។ អ៊ីចឹងលោកមេធាវីអាចរៀបពាក្យពេចន៍ឡើងវិញ ចោទសំណួរឡើងវិញ។ បាទ សូមអរគុណ។

[១៣:៤៤:៣៧]

**លោក ហ្វូស្តេរ ប៉ោះ**

សូមអរគុណលោកចៅក្រម ឡាវែន៍ គឺថាវាស្ទើរតែនឹងច្បាស់លាស់ហើយ ក៏ប៉ុន្តែសំណួរបីបន្ទាប់នេះ។ ប្រហែលជាលោកចៅក្រមអាចផ្តល់សេចក្តីណែនាំ ព្រោះនឹងអាចជួបបញ្ហានេះនឹកញាប់ហើយ។ ទី១ លោកអាចពន្យល់មូលហេតុនៅពីខាងក្រោយសេចក្តីសម្រេចនេះបានទេ។ ដោយសារលោក ហ្វីលីព ស្សូត បានសរសេរអំពីរបបខ្មែរក្រហម។ ហើយបើទោះបីជាបញ្ហាដែលលោក ហ្វីលីព ស្សូត សរសេរហ្នឹង វាត្រូវ ឬក៏មិនត្រូវនោះ។ នោះគឺជាបញ្ហានៅពេលនោះទេ។ ក៏ប៉ុន្តែក្នុងករណីនេះ គឺខ្ញុំដឹងថាលោក គង់ គីម គាត់មានវត្តមាននៅភ្នំពេញនាពេលនោះ។

ដូច្នេះ ខ្ញុំមិនមានឃើញព្យសនកម្មអ្វីដែលប៉ះពាល់រឿងនេះទេ។ ពីព្រោះទ្រឹស្តីដែលលោក ហ្វីលីព ស្សូត សរសេរនេះគឺវាស៊ីសង្វាក់គ្នាទៅនឹងការអះអាងនេះ ដែលថាទ្រឹស្តីទោះបីផ្លូវមួយណាក៏ដោយវាកៀកទៅនឹងការពិតហើយ។ ដូច្នេះ ខ្ញុំក៏សួរគាត់ ឲ្យគាត់ផ្តល់សក្ខីកម្មទៅតាមបទពិសោធន៍របស់គាត់។ ដូច្នេះ បញ្ហាដែលវាកើតមានឡើងនេះ។ ឧទាហរណ៍ថា លោក ហ្វីលីព ស្សូត មកផ្តល់សក្ខីកម្មប៉ុន្មានខែទៀតខាងមុខនេះ។ សាក្សីនេះ គឺថាអាចនឹងមកចូលខ្លួនចំពោះមុខអង្គជំនុំជម្រះនៅ២ខែមុខទៀត។ ដូច្នេះអាចនឹងសួរគាត់ ថាតើមានបញ្ហាអ្វីខុសគ្នាជាមូលដ្ឋានរវាងស្ថានភាពទាំងនោះ។

[១៣:៤៦:១៥]

កាលពីមុនគឺថាភាគីទាំងអស់អាចលើកឯកសារមកនេះមកសួរ -- ឯកសាររបស់អ្នកជំនាញមកសួរសាក្សី។ ដូច្នេះប្រហែលជាអង្គជំនុំជម្រះអាចនឹងសួរទៅសាក្សីជំនាញនេះ។ នៅពេលនោះគឺថាសៀវភៅរបស់ ប៉ែន យៀវនិន គឺក៏ត្រូវយកមកសាកសួរស្តាប់ចម្លើយ។ ហើយ ប៉ែន យៀវនិន ក៏បានមកផ្តល់សក្ខីកម្ម ហើយសៀវភៅដែលសរសេរដោយលោក ស៊ីវ ហេងឌ័រ ក៏បានយកមកសាកសួរ។

ដូច្នេះ ថាតើអង្គជំនុំជម្រះអាចនឹងជម្រាបអំពីមូលហេតុនេះបានទេ ថាតើសាក្សីនោះធ្លាប់បានស្តាប់ចម្លើយហើយឬក៏នៅ? យ៉ាងហោចណាស់ ក៏ជួយមកដល់ខាងក្រុមយើងខ្ញុំដឹងដែរ។ យើងខ្ញុំគិតថា យើងខ្ញុំប្រហែលជាមិនមែនជាក្រុមតែមួយដែលចង់បាននូវការបញ្ជាក់បំភ្លឺនេះទេ។ សូមអរគុណ។

[១៣:៤៧:១២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមឆ្លើយដោយសង្ខេប ជាការពិតហើយដែលថាយើងត្រូវតែគោរពតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះ។ ខ្ញុំចង់ចោទសួរទៅតែម្តង នេះបញ្ហាៗសៀវភៅនេះ គឺដើម្បីឲ្យអង្គជំនុំជម្រះពិចារណា។ ជាគោលការណ៍ ដោយសារតែវាជាទ្រឹស្តីមួយ វាពាក់ព័ន្ធទៅនឹងអង្គហេតុដែលសាក្សីត្រូវសាកសួរអំពីការយល់ដឹងផ្ទាល់របស់គាត់។ យើងខ្ញុំមិនជំទាស់ទេ ការយកចំណែកណាមួយពាក់ព័ន្ធទៅនឹងអង្គហេតុមកតាំងសំណួរទៅលើសាក្សីនេះ ដើម្បីចង់បញ្ជាក់ឲ្យគាត់ឆ្លើយនោះ។ ក៏ប៉ុន្តែជំហររបស់សហព្រះរាជអាជ្ញានៅពេលនេះ គឺថាខុសគ្នា សារដែលសហ -- ដែលមេធាវីការពារក្តីលើកឡើង គឺពាក់ព័ន្ធទៅនឹងរបៀបដែលគណៈអចិន្ត្រៃយ៍ សេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍គឺថាត្រូវយល់ និងអនុវត្តដោយរបៀបណា គឺថាត្រូវអនុវត្តដោយថ្នាក់ភូមិភាគ។ មុនសម្រាក មេធាវីការពារក្តីបានសួរទៅសាក្សីនូវអ្វីដែលសាក្សីមិនបានដឹងនោះទេ ក្រៅពីសមត្ថភាពហួសពីកងពលរបស់គាត់នោះ ថាគាត់ដឹងតែបញ្ហាណាដែលជាបញ្ហានៅក្នុងកងពលរបស់គាត់។ ដូច្នេះមិនមានមូលដ្ឋានណាច្បាស់លាស់ ដើម្បីយកចំណុចរបៀបនេះមកសួរសាក្សី ហើយឲ្យគាត់ឆ្លើយស្មានៗនោះទេ។ នេះវានាំឲ្យសាក្សីឆ្លើយស្មានហើយ។

[១៣:៤៩:០០]

ដូច្នេះសហព្រះរាជអាជ្ញាសូមជំទាស់ក្នុងការយកឯកសារមកសួរបែបនេះក្នុងពេលនេះ។ ប៉ុន្តែនិយាយឲ្យទូលាយទៅគឺថាត្រូវតែមានចំណងពាក់ព័ន្ធច្បាស់លាស់ ដោយយកមកសាកសួរនោះ។ យើងខ្ញុំនឹងមិនជំទាស់ទេ បើមានចំណងជាប់ទាក់ទងច្បាស់លាស់នោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ។ ខ្ញុំគ្រាន់តែឆ្លើយនូវអ្វីដែលសហព្រះរាជអាជ្ញាបានអះអាងនោះ បើសិនណាមិនរំខានខ្ញុំទេ ប្រហែលជាខ្ញុំអានទៅច្បាស់ហើយ នឹងឃើញថាមានទំនាក់ទំនងច្បាស់លាស់យ៉ាងម៉េចរវាង

សៀវភៅនេះជាមួយនឹងសាក្សី។

[១៣:៤៩:៥៧]

ខ្ញុំមិនអានទាំងមូលនេះទេ ខ្ញុំនិយាយតែអំពីបញ្ហានៃការជម្លៀសចេញពីទីក្រុងភ្នំពេញ ធ្លាក់ទៅដល់ថ្នាក់ភូមិភាគ ធ្លាក់ទៅដល់ថ្នាក់ក្រោម ចាប់ -- គិតរាប់ -- ខ្ញុំយល់ព្រមទៅនឹងថា សហព្រះរាជអាជ្ញាយល់ថា បើសិនណាជាមានទំនាក់ទំនងរវាងសៀវភៅ ហើយនិងសាក្សីនោះ គឺថាអាចនឹងយកមកតាំងសួរសាក្សីបាន។

[១៣:៥០:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៣:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានឃ្លាទាំងស្រុងដែលខាងមេធាវីការពារក្ដីចង់អាន។ ដូច្នេះ វាអាចមានបង្កឲ្យមានផលប៉ះពាល់ ក៏ប៉ុន្តែអង្គជំនុំជម្រះសូមឲ្យជៀសវាងនូវការដកស្រង់នូវការវិភាគដែលធ្វើឡើងដោយអ្នកជំនាញ នៅពេលដែលអ្នកជំនាញទាំងនោះមិនទាន់បានស្ដាប់សក្ខីកម្មនោះ។ យើងសូមជៀសវាងកុំឲ្យដកស្រង់នូវឃ្លាទាំងស្រុងបែបនេះ។ ដូច្នេះ វាមិនសមស្របទេ ដែលស្នើសុំឲ្យសាក្សីបញ្ជាក់អំពីការវិភាគដែលធ្វើឡើងដោយអ្នកជំនាញខាងប្រវត្តិ-សាស្ត្រនោះ។ ហើយយើងបានបញ្ជាក់ជូនភាគី ហើយនិងមេធាវីការពារក្ដីហើយ ថាយើងមិនហាមឃាត់ឲ្យចោទសួរសំណួរពាក់ព័ន្ធដោយផ្ទាល់ ផ្ដោតទៅលើការដឹងឮ និងបទពិសោធន៍របស់គាត់ទេ។ ប៉ុន្តែសំណួរនោះត្រូវតែពាក់ព័ន្ធទៅនឹងការវិភាគ ដោយអ្នកជំនាញ។

នៅពេលអនាគតនោះ យើងចង់ធ្វើឲ្យភាគីទាំងអស់ ធ្វើឲ្យយ៉ាងណាគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។

[១៣:៥៤:៣៧]

**លោក ហ្សាស្ដេ ប៉ៅ៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។ នេះ គឺជាអ្វីដែលខ្ញុំកំពុងតែធ្វើ ខ្ញុំមិនអានទាំងស្រុងទេ។ ខ្ញុំ

កំពុងតែអនុវត្តទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ហើយមូលហេតុវាអាចជួយឲ្យយើងខ្ញុំមានការយល់ដឹង។ ដូច្នេះ យើងខ្ញុំសូមស្នើសុំ ក្នុងពេល គឺថាសូមឲ្យបង្ហាញ -- ខ្ញុំថា មិនអានសម្រង់របស់អ្នកជំនាញដែលវាមិនសមស្របនោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះផ្ដល់មូលហេតុ ចំពោះការសម្រេចសេចក្ដីនេះ។ ហើយឥឡូវនេះ ខ្ញុំសូមចាប់ផ្ដើមចូលសំណួរបន្ទាប់ទៀត។ ដូច្នេះខ្ញុំគិតឃើញថា ដោយសារតែសេចក្ដីសម្រេចនេះគឺថា ខ្ញុំមិនអាចដកស្រង់សេចក្ដីណាមួយ ចេញពីសៀវភៅណាមួយរបស់ ហ្វីលីព ស្សូត ទេ។

[១៣:៥៥:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៦:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ខ្ញុំសង្ឃឹមថា ខ្ញុំច្បាស់ហើយ ក៏ប៉ុន្តែលោកនៅតែថា ខ្ញុំមិនច្បាស់ទៀត។ ខ្ញុំសូមលើកឡើងម្ដងទៀតថា ការដកស្រង់នូវការវិភាគរបស់អ្នកជំនាញណាមួយ ដើម្បីយកមកចោទសួរសាក្សីនោះ វាមិនមែនជា -- មានភាពសមស្របទេ ដោយសារតែការវិភាគនោះ មិនអាចត្រូវបានអះអាង។ ដូច្នេះ យើងមិនអាចយកការវិភាគនេះ មកចោទសួរសាក្សីបានទេ។ យើងធ្វើយ៉ាងម៉េចចាប់ផ្ដើបង្កើតទៅជាមូលដ្ឋានសម្រាប់ការវិភាគមួយនេះ ហើយយើងសួរសាក្សីពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលលើកឡើងនៅក្នុងការវិភាគនេះ។ បន្ទាប់មកយើងអាចចាប់ផ្ដើមសួរគាត់ អំពីការថាតើគិតយ៉ាងម៉េច ចំពោះការវិភាគរបស់អ្នកជំនាញ។ ក៏ប៉ុន្តែនៅពេលដែលយើងផ្ដើមមកភ្លាម ដោយយកការវិភាគទាំងស្រុងមកចោទសួរម្ដងនោះ វាមិនមែនជាទង្វើល្អទេ។ ដូច្នេះ ខ្ញុំគិតថា អ្វីដែលខ្ញុំបានជម្រាបនេះ គឺច្បាស់សម្រាប់លោកហើយ។

**លោក ហ្សាស្ដើ ប៉ោះ៖**

បាទលោកចៅក្រម ឡាវ៉ែន៍ ខ្ញុំយល់ហើយ។ ខ្ញុំមិនចង់ឲ្យបញ្ហានេះស្មុគស្មាញឡើងៗនោះទេ។ ឥឡូវនេះគឺថា តើយើងខ្ញុំមិនអាចប្រើការវិភាគណាមួយ របស់អ្នកជំនាញមកសួរសាក្សីបានទេឬ? មានន័យថា គ្រប់អ្នកជំនាញទាំងអស់ ដែលសរសេរអំពីបញ្ហាខ្មែរក្រហម មិនអាចយកមកបានទេឬ? ទី២ តើខ្ញុំអាចសួរសំណួរទៅលើសាក្សីនេះបានទេ បន្ទាប់ពី ហ្វីលីព ស្សូត គាត់ចូលខ្លួនមកផ្ដល់សក្ខីកម្មជូន

តុលាការនោះ? តើមធ្យោបាយណាមួយ? សុំមេត្តាបញ្ជាក់។ សូមអរគុណ។

[១៣:៥៨:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

យើងបានបញ្ជាក់ហើយថា លោកអាចចោទសួរ សំណួរយ៉ាងណាក៏បានទៅកាន់សាក្សីនេះ ពាក់ព័ន្ធទៅនឹងព័ត៌មានដែលមាននៅក្នុងការវិភាគរបស់សាក្សី ដូចដែលមាននៅក្នុងសៀវភៅរបស់អ្នកជំនាញ។ ក៏ប៉ុន្តែលោកមិនចាំបាច់ក្នុងការដកស្រង់នូវការវិភាគទាំងស្រុង មកអានឲ្យសាក្សីស្ដាប់ទេ ព្រោះថា អ្នកជំនាញទាំងនុ៎ងមិនទាន់បាន ផ្ដល់សក្ខីកម្មទេ។ យើងដឹងថា លោក ហ្វីលីព ស្សូត នេះគឺនឹងមកផ្ដល់សក្ខីកម្មនៅពេលខាងមុខ។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំនឹងបន្តទៅមុខទៀត ដោយសារពេលវេលាខ្លីហើយ។ ខ្ញុំមិនទទួលបានពេលវេលាបន្ថែមនោះទេ ដូច្នេះ ខ្ញុំសូមបន្តទៅមុខទៀត។ ដើម្បីឲ្យស្មោះត្រង់នោះគឺថា បញ្ហានេះគឺ ខ្ញុំនៅតែយល់មិនច្បាស់នៅឡើយ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** យើងខ្ញុំបានដកស្រង់ចម្លើយរបស់លោក នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយជាមួយនឹងចៅក្រមស៊ើបអង្កេត លោក គង់ គីម ត្រង់ទំព័រ 00278682, ខ្មែរគឺ 00274164, ឯកសារលេខ D166/74។ លោកបានឆ្លើយថា នៅពេលដែលលោកនិយាយអំពីកងទ័ព ឬទាហាន ដែលចូលរួមក្នុងការជម្លៀសទីក្រុងភ្នំពេញ លោកបាននិយាយថា "អ្នកខ្លះមានសីលធម៌មិនបាញ់នោះទេ ហើយអ្នកដែលគ្មានសីលធម៌គឺទៅដល់បាញ់តែម្ដង" បញ្ចប់ការដកស្រង់។ តើចំណុចនេះ គឺវាឆ្លុះបញ្ចាំងត្រឹមត្រូវនូវពាក្យសម្ដីរបស់លោកដែរឬទេ? គឺថាការបាញ់បោះទៅលើប្រជាជននោះ គឺអាស្រ័យទៅលើទាហានខ្លួនឯង គឺនៅពេលដែលគាត់ចង់បាញ់ គឺគាត់បាញ់ស្រេចតែគាត់ តើអ៊ីចឹងដែរឬទេ?

[១៤:០១:០៨]

**លោក គង់ គីម៖**

**ឆ៖** បាទ នៅបញ្ហាចំណុចនេះដែលខ្ញុំបានឆ្លើយនេះគឺថា ពេលដែលយើងចូលដល់ទីក្រុងភ្នំពេញ គឺថាដើមមុនដំបូងដែលយើងបុកចូលមុនដំបូង ថ្ងៃមុនដំបូងដែលយើងត្រូវចូលមកហ្នឹង ដែលទាហានខាងក្រៅ និងទាហានខាងក្នុង ដែលពើបប្រយុទ្ធគ្នាបន្តបន្ទាប់។ ក្រោយមកគឺជួបប្រជាជនដែលជម្លៀស

ទៅ ដែលនៅតិចតួចដែលទៅខាងមុននេះ។ អ៊ីចឹងដែលពេលដែលបាញ់នោះ ដោយមាននៅទាហានក្នុង ត។ បាទ អ៊ីចឹងការប្រយុទ្ធគ្នាជាមួយទាហាននឹងទាហានទេ ប៉ុន្តែវាមានពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ ដែលនៅជាមួយ។ ក្រោយមកគឺពេលដែលស្ងប់ស្ងាត់អាវុធហើយ ជម្លៀសចេញ ដែលទ័ពហ្នឹងគឺមានបទ បញ្ជាថា មានគោលដៅ ឲ្យទៅតាមគោលដៅហើយ គឺអត់មានសិទ្ធិអីបាញ់ទៀតទេ គឺថាឲ្យតែប្រជាជន គឺឲ្យចេញបានទាំងអស់។ ចំណុចដែលត្រង់ថាបានបាញ់នោះ ពេលដែលប្រជាជនចេញទៅមុនដំបូង ហើយទាហានក៏នៅនុ៎ង ហើយការប្រយុទ្ធគឺនៅថ្មីៗណាស់ គឺប្រយុទ្ធបន្តបន្ទាប់។ អ៊ីចឹងពេលនុ៎ងហើយ ដែលខ្ញុំថា ដោយកងទ័ពខ្លះដែលមានការចេះគិតគូរខ្លួនឯង ក៏អត់បាញ់ទៅ ហើយកងទ័ពខ្លះដែលវាមាន ការ ដូចថាខឹង ពេលដែលក្រោយពីប្រយុទ្ធគ្នាជាប់ហ្នឹង ដល់មានការខឹងការអីទៅ អត់បានពិចារណា អត់មានសីលធម៌ ក៏បានមានការបាញ់បោះដែរ។ ពេលដែលបាញ់បោះនោះគ្មានថ្នាក់លើដាក់ទោសដាក់ពៃរ៍ទេ ព្រោះទើបតែប្រយុទ្ធថ្មីៗ គឺមិនមានដាក់ទោសដាក់ពៃរ៍អីទេ។

[១៤:០២:៤៤]

**ស៖** សូមអរគុណ។ តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកធ្វើការបែងចែកដូច្នេះ ដែលថាលោកនិយាយថា អ្នកខ្លះមានសីលធម៌ និងអ្នកខ្លះគ្មានសីលធម៌។ លោកបាននិយាយថា អ្នកខ្លះ មានសីលធម៌មិនបាញ់ ហើយអ្នកគ្មានសីលធម៌ក៏បាញ់។ តើលោកមានន័យយ៉ាងម៉េច នៅពេលដែល លោកចែងបែកប្រភេទពីរខុសគ្នាដូច្នេះ?

**ឆ៖** បាទ នៅក្នុងចំណុចនេះគឺថា មនុស្សយើងគឺមានអត្តចរិតវាខុសគ្នាបាទ ចិត្តគំនិតក៏ខុសគ្នា ដែរ។ ដូច្នេះការបទបញ្ជា គឺបទបញ្ជាគឺឲ្យវៃចូលសមរភូមិ គឺថារំដោះ។ ដូច្នេះគឺថាអ្នកខ្លះមានកំហឹងថា ពុះកញ្ជ្រោល ដោយការមានការខឹង ហើយក្នុងជួរកងទ័ពខាងក្រៅ គឺមានការស្លាប់ មានការរបួស ច្រើន។ អ៊ីចឹងពេលដែលថ្មីៗហ្នឹងថា កំហឹងវាមិនទាន់បាត់ខឹង ដូច្នេះថាមានការប្រយុទ្ធហ្នឹងមោះមុត។ ដូច្នេះគឺដោយប្រជាជនដែលពេលដែលគាត់បាននៅចុងកាត់មាត់ញក ដែលពេលយើងចូលដល់មូលដ្ឋាន ហ្នឹង ហើយមានទាហាននៅទីនុ៎ង ដូច្នេះមានការប្រយុទ្ធគ្នាផង ហើយការការពារខ្លួនផង។ អ៊ីចឹងវា មានការ អ្នកខ្លះក៏អាចថាឃើញប្រជាជនក៏បាញ់ដែរ ពេលវេលាដែលនៅច្របូកច្របល់គ្នាហ្នឹង។

[១៤:០៤:១៦]

**ស៖** សូមអរគុណ លោកបានឆ្លើយច្បាស់ហើយត្រង់ចំណុចនេះ។ ហើយខ្ញុំក៏ចង់សាកសួរលោក ដោយផ្អែកទៅលើទ្រឹស្តីរបស់លោក ហ្វីលីព ស្បូត ផងដែរ ដែលទ្រឹស្តីនោះ ផ្អែកតាមទ្រឹស្តីនោះថាតើ

មានអ្វីកើតឡើងនៅក្នុងទីក្រុងភ្នំពេញ ជាពិសេសចំពោះមេបញ្ជាទាំងអស់នោះ។ ខ្ញុំមិនសួរសំណួរទាំងអស់នេះ ខ្ញុំសូមបន្តចូលទៅប្រធានបទមួយទៀត។ ខ្ញុំសូមសួរលោកអំពីរយៈ ពេលដែលលោកនៅទីក្រុងភ្នំពេញ។ តើនៅពេលនោះ នៅពេលដែលលោកនៅក្នុងក្រុងភ្នំពេញហ្នឹង តើលោកមានដឹងថា មានកងទ័ពខ្មែរក្រហមមកពីភូមិភាគបូព៌ា និង មកពីភូមិភាគនិរតី មកចូលរួម និងប្រតិបត្តិការនោះដែរឬទេ?

**ឆ៖** បាទ ពេលដែលវាយចូលក្នុងទីក្រុងភ្នំពេញ ខ្ញុំបាទគ្រាន់តែបានឮគេនិយាយថា ការដែលចូលនេះ គឺទទួលខុសត្រូវតាមមុខព្រួញភូមិភាគ។ អ៊ីចឹងត្រង់ថា ភូមិភាគឧត្តរនេះ គឺមកពីទិសខាងជើង បូព៌ាគឺគេបុកពីខាងកើត និរតីគេបុកពីខាងលិច។ អានេះជាការគ្រាន់តែឮ ដែលគេនិយាយ ប៉ុន្តែការពិតគឺខ្ញុំអត់បានឃើញ។

[១៤:០៦:១៣]

**សៈ** ក្នុងខណៈពេលដែលលោកនៅក្នុងទីក្រុងភ្នំពេញ យាមតាមដីឡូត៍ដែលលោកយាមនោះ តើលោកមានដឹងថាកងទ័ពមកពីភូមិភាគផ្សេងៗនោះមានតួនាទីនៅលើការងារនេះទាំងអស់នេះដែរឬទេ?

**ឆ៖** បាទ ចំពោះភូមិភាគដទៃ ហើយនិងអង្គភាពដទៃ កិច្ចការទាំងឡាយ គឺខ្ញុំអត់បានដឹងថាធ្វើដូចគ្នា ឬក៏មិនដូចគ្នា ដោយឡែកគឺខ្ញុំអត់បានឃើញ អត់បានដឹង។ ខ្ញុំដឹងតែកិច្ចការដែលខ្ញុំត្រូវទទួល។

**សៈ** នៅពេលដែលយើងនិយាយអំពីកន្លែងនុំង បានន័យថាកន្លែងដែលលោកថានៅខាងជើងវត្តភ្នំដែលលោកឈរជើងនោះ តើកន្លែងហ្នឹង តើកន្លែងដែលលោកឈរជើងនៅជាប់គ្នាទៅនឹងកងកន្លែងដែលកងទ័ពមកពីភូមិភាគបូព៌ាឈរជើងដែរឬទេ?

**ឆ៖** បាទ កន្លែងដែលខ្ញុំឈរជើងនៅខាងជើងវត្តភ្នំនេះ គឺជា បើនិយាយថាជាដីរបស់កងពលខាងភូមិភាគឧត្តរ។ អ៊ីចឹងភូមិភាគបូព៌ានេះ ដឹងតែនៅខាងកើត ប៉ុន្តែមិនដែលឃើញគ្នាផង ហើយមិនដឹងជាកិច្ចការពីត្រឹមណាទៅត្រឹមណាទេ ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងថាមាត់ទន្លេខាងលិចគឺកងពលរបស់ខ្ញុំ ហើយប្រគល់កន្លែងហ្នឹងគឺឲ្យមកក្រុមខាងខ្ញុំ។

**សៈ** សូមអរគុណ។ ដើម្បីសួរឲ្យលោករំឭកការចងចាំឡើងវិញនោះ គឺថាខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោក ហេង សំរិន។ ឯកសារ E3/1568 ខ្មែរគឺមានលេខ 00713968, អង់គ្លេសគឺ 00651892។ ផ្នែកដែលខ្ញុំសូមដកស្រង់ចេញនោះ គឺត្រង់ទំព័រខ្មែរ 00713946, អង់គ្លេសគឺ 00651879។ នៅត្រង់ទំព័រទី១ លោក ហេង សំរិន បាននិយាយថា គាត់និយាយអំពីកងពលរបស់គាត់នៅក្នុងភូមិភាគរបស់គាត់។

[១៤:០៩:០៨]

"ចំពោះខ្ញុំ ខ្ញុំវាយចូលទីក្រុងភ្នំពេញ បន្ទាប់មកគឺខ្ញុំក៏ទៅខាងលេខ ២០៩"។ លោក ហេង សំរិន ថា កងទ័ពរបស់គាត់ កងពលរបស់គាត់ចូលមកទីក្រុងភ្នំពេញមុនគេ ដែលមកពីភូមិភាគបូព៌ា។ នៅត្រង់ទំព័រទី២ ខ្ញុំសូមដកស្រង់សម្ដីផងដែរ លោក ហេង សំរិន លើកឡើងថា "នៅថ្ងៃ១៧ មេសា វេលាម៉ោងប្រាំបួនព្រឹក ខ្ញុំមកដល់វិមានឯករាជ្យ។ ក្រោយការរំដោះមានការបែងចែកការទទួលខុសត្រូវក្នុងចំណោមកងទ័ព កងពលធំបីកងមកពីបូព៌ា។ កងធំ កងពលធំទី -- លេខ១ របស់ខ្ញុំ កងពលធំលេខ២ របស់ប្អូនប្រុសខ្ញុំ និងកងពលធំលេខ៣ របស់ ឈាវ ដែលបានវ៉ៃចូលដល់ជ្រោងចង្វាជាមួយទាហានជើងទឹក"។ ហើយបន្ទាប់មកទៀត គឺយើងឃើញថា មានផ្នែកមួយទៀតដែលអាចឱ្យលោកមើល ហើយនិងនឹកឃើញការចងចាំ។ ក្រោយការរំដោះ ការ -- ផែនការនោះ គឺថាមានការបែងចែកត្រឹមវត្តភ្នំចំពោះក្រោយរំដោះ។ ភូមិភាគបូព៌ា កងពលភូមិភាគបូព៌ានៅផ្នែកម្ខាង ហើយនិងកងទ័ពម្ខាងទៀតនៅជ្រុងម្ខាងទៀត។ កងពលពិសេសត្រូវបានបង្កើតឡើងដែលមាន វន វ៉េត ជាលេខា សុន សេន ជាអនុលេខា" បញ្ចប់ការដកស្រង់។ លោក ហេង សំរិន បានលើកឡើងថា "ភូមិភាគខាងបូព៌ា កងទ័ពភូមិភាគបូព៌ាគឺនៅត្រើយម្ខាង ហើយនៅត្រើយម្ខាងពីវត្តភ្នំ"។ ដូច្នេះប្រសិន បើសិនជាលោក ហេង សំរិន និយាយត្រឹមត្រូវនោះ គឺថា កងទ័ពខាងបូព៌ានេះ ហៅថា នៅជិតវត្តភ្នំផងដែរ។ តើលោកចាំដែរឬទេ ថាមានកងទ័ពខាងភូមិភាគបូព៌ាក៏ឈរជើងនៅជិតវត្តភ្នំផងដែរ? តើលោកចាំទេ?

[១៤:១១:៣៣]

**ឆ៖** បាទ ពេលដែលចូលមកដល់ទីក្រុងភ្នំពេញដែលបានបែងចែក ដីឡូត៍ទៅតាមកងពល ហើយនិងកងពលបានទម្លាក់ឡូត៍មកតាមថ្នាក់ៗខាងក្រោមៗនេះ ចំពោះពួកខ្ញុំទទួលមុខសញ្ញាខាងជើងវត្តភ្នំនេះ ហើយមិនដែលបានឃើញកងពល ឬក៏ភូមិភាគបូព៌ា ខាងបូព៌ាមកនៅខាងលិចទន្លេទេ គឺថាអត់ដែលឃើញបាទ។

**ស៖** ក្នុងពេលរំដោះទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា និង២, ៣ថ្ងៃក្រោយនោះ តើលោកដឹងទេថា កងទ័ពខាងបូព៌ានោះធ្វើការងារអ្វីខ្លះ? ហើយបានប្រព្រឹត្តអ្វីខ្លះក្រោយពីចូលមកដល់ទីក្រុងភ្នំពេញ?

**ឆ៖** បាទ ចំពោះកងទ័ពពីភូមិភាគមួយទៅភូមិភាគមួយនោះ ខ្ញុំក្ដាប់មិនបានទេ សូម្បីតែកងពលរបស់ខ្ញុំផ្ទាល់ដែលខ្ញុំស្ថិតនៅក្នុងចំណុះកងពលនេះ ពីវរៈមួយទៅវរៈមួយ ក៏ខ្ញុំក្ដាប់អត់បានផងបាទ។

[១៤:១៣:០១]

**ស៖** តើលោកដឹងទេមានអ្វីកើតឡើងនៅក្នុងទីក្រុងភ្នំពេញ នៅក្នុងដីឡូត៍ ឬក៏កន្លែងដែលគ្រប់គ្រងដោយកងទ័ពមកពីភូមិភាគបូព៌ាក្រោយប៉ុន្មានថ្ងៃ ក្រោយពេលរំដោះនោះ?

**ឆ៖** បាទ ដោយយើងខ្ញុំមានដីឡូត៍ផ្សេង ហើយលើសភាពការណ៍ដែលក្រោយថ្ងៃរំដោះ ២, ៣ថ្ងៃនេះគឺថា យើងខ្ញុំមិនបានក្ដាប់សភាពឲ្យបានអស់ ដោយឡែកគឺខ្ញុំគ្រប់គ្រងតែកម្លាំងដែលគេប្រគល់ឲ្យ ហើយនិងគោលដៅគេឲ្យឈរជើងតែប៉ុណ្ណឹង។ រីឯព័ត៌មានក្រៅៗ គឺអត់មានការចេញចូលមកដល់ខ្ញុំបាទទេ។

**ស៖** សូមអរគុណ។ តើនេះជាការសង្ខេបសក្ខីកម្មរបស់លោកត្រឹមត្រូវដែរឬទេ ដែលថាលោកមិនអាចជម្រាបអំពីការងាររបស់ទ័ពខាងភូមិភាគបូព៌ាធ្វើនោះទេ នៅពេលដែលគេចូលមកដល់ទីក្រុងភ្នំពេញនោះ? លោកដឹងតែការងាររបស់លោក ហើយលោកមិនដឹងទេការងារដែលកងទ័ពមកពីខាងភូមិភាគបូព៌ាធ្វើការងាអ្វីៗនោះ គឺលោកមិនបានដឹងទេ។ តើនេះជាការសង្ខេបត្រឹមត្រូវនូវអ្វីដែលលោកឆ្លើយដែរឬទេ?

[១៤:១៤:២៨]

**ឆ៖** បាទ នេះជាត្រឹមត្រូវ។ គឺក្នុងសម័យដែលកងទ័ពចូលទីក្រុងភ្នំពេញនេះ បានន័យថា ខ្ញុំជាកងទ័ពពិតមែន ប៉ុន្តែគោរពបទបញ្ជា ហើយគ្មានសិទ្ធិសេរីភាពក្រៅពីបទបញ្ជាដើរទៅណាបានទេ ហើយម៉ោងការងារអត់មានម៉ោងសម្រាក អត់មានម៉ោងធ្វើការទេ គឺថាប្រចាំការជាប់។ ទិសដៅត្រង់ណាទទួលត្រង់ហ្នឹង គឺមិនអាចចេញពីគោលដៅដែលបទបញ្ជាដាក់ទេ។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។ ដូច្នេះ យើងកំពុងតែជម្រាបប្រាប់យើងខ្ញុំថា គេមិនឲ្យលោកដើរចេញទៅណាទៅណីនោះទេ។ លោកមានតួនាទីទាបតូច ហើយលោកនៅតែឈរជើងតែកន្លែងលោកតែប៉ុណ្ណោះ។ លោកមិនដឹងថាមានអ្វីកើតនៅកន្លែងផ្សេងនៅក្នុងទីក្រុងភ្នំពេញនោះឡើយ។ លោកយាមខាងឡូត៍ ខាងជើងវត្តភ្នំ ហើយលោកក៏និយាយថា មេៗរបស់លោកគឺមានសិទ្ធិដើរហើរដោយសេរី។ លោកបាននិយាយថា មេបញ្ជាការកងពលរបស់លោកនោះអាចធ្វើដំណើរទៅភូមិភាគបូព៌ា និងភូមិភាគឧត្តរបាន នៅកន្លែងខាងជើងដើរហើរដោយសេរីបាន។ នេះគឺអ្វីដែលលោកបានលើកឡើង។ តាមអ្វីដែលលោកឆ្លើយកាលពីម្សិលមិញ សហព្រះរាជអាជ្ញាបានសួរទៅលោកនូវសំណួរមួយពាក់ព័ន្ធទៅនឹងលោក អឿន។ ខ្ញុំមិនចង់សួរបញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនោះទេ។ ក៏ប៉ុន្តែខ្ញុំចង់សួរថា តើមានអ្វីកើតឡើងចំពោះគាត់ ហើយនៅពេលនេះ គឺគាត់នៅឯណាដែរ?

[១៤:១៦:២៧]

**ឆ៖** បាទ បច្ចុប្បន្នគឺឈ្មោះ អឿន នេះខ្ញុំមិនដឹងទេ ក្រោយដែលបានបែកគ្នាទៅ ព្រោះគាត់បានត្រូវគេចាប់ខ្លួន។ ហើយពេលវេលាដែលខ្ញុំបានឃើញគាត់ដើរឆ្លើយកាត់នៅតំបន់ដែលខ្ញុំការពារនេះ គ្រាន់តែឃើញគាត់ឆ្លងកាត់ តែត្រង់ទិសដៅគាត់ទៅជួបថ្នាក់លើ ឬក៏ថ្នាក់ណាៗនោះជាភារកិច្ចរបស់គាត់ដោយឡែកៗគឺថា គាត់មិនអាចយកផែនការនោះ គឺថាមិនដែលយកផែនការដែលគាត់ដើរនោះមកផ្សព្វផ្សាយដល់ថ្នាក់ក្រោមទេ។ គឺថាយើងមានសិទ្ធិតែការពារសម្រាប់តែពេលគាត់ធ្វើដំណើរនៅនឹងគោលដៅយើង។

**ស៖** សូមអរគុណ។ ក្នុងពេលដែលលោកចូលរួមរំដោះទីក្រុងភ្នំពេញ ឬក៏ប៉ុន្មានខែក្រោយមកនោះ តើលោកបានជួបមេបញ្ជាការកងពល ក្រៅពី អឿន ដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបហើយថា តួនាទីភារកិច្ចផងខ្ញុំនេះ ចំពោះថ្នាក់ដឹកនាំចាប់ពីវរសេនាធំកងពលទៅនេះ មិនបានជិតស្និទ្ធទេ។ ខ្ញុំបាទបានជួបតែត្រឹមឋានៈវរសេនាតូច ហើយនិងអនុសេនាធំ អនុសេនាតូច និងតាមក្រុមហ្នឹងជាប្រចាំ។ តែចាប់ពីវរសេនាធំឡើងទៅលើនេះ គឺមិនដែលបានជួប មិនដែលមកសំណេះសំណាល មិនដែលបានប្រជុំជាមួយទេ។ ហើយកងពលដទៃទៀតៗ ថ្នាក់ដឹកនាំធំៗទៅទៀត ក៏ខ្ញុំមិនដែលបានចូលរួមក្នុងការប្រជុំ ចូលរួមក្នុងការការពារពេលដែលវេលា គាត់មកប្រជុំគ្នា គឺខ្ញុំអត់ដឹងតែម្តង។

**ស៖** ខ្ញុំគិតថាចម្លើយរបស់លោកបានឆ្លើយច្បាស់ហើយ។ ភស្តុតាង និងសក្ខីកម្មដែលលោកបានឆ្លើយ គឺថាលោកដឹងដោយកម្រិតតែប៉ុណ្ណោះ គឺមិនដឹងទូលំទូលាយនោះទេ។ ចំណុចនេះ គឺឲ្យយើងឃើញយ៉ាងច្បាស់។ ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ។ តើលោកចាំដែរឬទេក្នុងឆ្នាំណាដែរ ដែលលោកចាកចេញពីចលនារបស់ខ្មែរក្រហមនេះ? ឈប់ធ្វើការងារក្នុងចលនាខ្មែរក្រហម តើឆ្នាំណាដែរ?

[១៤:១៩:០៥]

**ឆ៖** បាទ ខ្ញុំចេញពីរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩។

**ស៖** ដូច្នេះក្នុងអំឡុងពេល៤ឆ្នាំ ក្រោយពេលរំដោះទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ តើក្នុងអំឡុងពេល៤ឆ្នាំនេះ លោកមានធ្លាប់ជួបមេបញ្ជាការកងពលណាម្នាក់ ដែលចូលរួមរំដោះនៅក្នុងទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ក្រោយពេលរំដោះក្រុងភ្នំពេញ គឺខ្ញុំបាទ គឺពេលដែលខ្ញុំទៅរស់នៅព្រលាននៅឆ្នាំ

១៩៧៦ ពេលនោះខ្ញុំបានជួបនៅប្រធានកងពលធំៗ ដែលមាន តាល្វៃ, តាធួក, តាគីន ហ្នឹងគឺហៅថា កងពល៥០២។

**ស៖** ដើម្បីឲ្យខ្ញុំយល់ឲ្យបានច្បាស់លាស់ មេបញ្ជាការកងពលទាំង៣នោះ គឺក៏បានចូលរួមវាយរំដោះទីក្រុងភ្នំពេញផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ដោយពេលនោះ ខ្ញុំបាទបានទៅបំពេញការងារធ្វើព្រលាននៅកំពង់ឆ្នាំង ហើយថ្នាក់ដឹកនាំកងពលនេះ បានគ្រប់គ្រងខ្ញុំ។ ពេលដែលខ្ញុំបំពេញការងារហ្នឹង។ អ៊ីចឹង គាត់បាននិយាយពីអតីតការវាយចូលភ្នំពេញ គឺគាត់បានចូលរួមចំណែកចូលទីក្រុងភ្នំពេញតាមភូមិភាគនិរតី។

[១៤:២១:០៥]

**ស៖** តើលោកដឹងថា អ្នកទាំង៣ហ្នឹង តើមានជោគវាសនាយ៉ាងម៉េចដែរ តើពួកគាត់នៅរស់ដែរឬទេ? ឬក៏ពួកគាត់មិនរស់នោះទេ ស្លាប់ហើយ?

**ឆ៖** បាទ នៅក្នុងឆ្នាំ១៩៧៦ អ៊ីចឹង គាត់នៅរស់។ ដល់ឆ្នាំ១៩៧៧ ខ្ញុំបានបែកពីព្រលានមក ហើយមិនដឹងជាគាត់ទៅណា បច្ចុប្បន្ន រស់ស្លាប់ អត់ដឹង។

**ស៖** នៅសព្វថ្ងៃនេះ តើលោកដឹងទេ អ្នកទាំង៣នេះ គាត់នៅរស់ឬក៏យ៉ាងម៉េច? ហើយដឹងកន្លែងដែលគាត់រស់នៅដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបហើយ ថាកាលពីឆ្នាំ១៩៧៦ ខ្ញុំបាននៅជិតគាត់ ដល់ឆ្នាំ១៩៧៧ ខ្ញុំចេញពីគាត់ តែបច្ចុប្បន្ននេះ មិនដឹងជាគាត់រស់ ឬក៏ស្លាប់ នៅកន្លែងណា ខ្ញុំអត់ដឹង។

**ស៖** សូមអរគុណ។ យោងតាម -- ផ្អែកតាមបទពិសោធន៍របស់លោកក្នុងជួរកងទ័ពខ្មែរក្រហម ដែលលោកដឹងអំពីការចាត់តាំង និងរចនាសម្ព័ន្ធកងទ័ពខ្មែរក្រហម។ តើមេបញ្ជាការកងពលដូចជា ហេង សំរិន ដែលគាត់វាយចូលទីក្រុងភ្នំពេញនោះ គាត់អាចមកផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងការចូលវាយចូលទីក្រុងភ្នំពេញដែរឬទេ? ជាពិសេស ពាក់ព័ន្ធទៅនឹងការងារទាំងឡាយដែលកើតឡើងនៅក្នុងកងពល ឬក៏មុខព្រួញរបស់គាត់ ដែលគាត់ក្តោបក្តាប់ កាន់កាប់នោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកចៅក្រម ខ្ញុំជំទាស់ការសួរសំណួរនេះ។ សួរសំណួរនេះ គឺថាឲ្យសាក្សីធ្វើការទាយស្មាន។

ប្រសិនបើមេធាវីគាត់ចង់លើកជាសេចក្ដីសន្និដ្ឋានណាមួយនោះ វាជាបញ្ហាផ្សេងមួយទៀត។ តែនេះវាជាការសួរសំណួរមួយ ឲ្យសាក្សីស្មាន។

**លោក ហ្វាស្ដើ ប៉ោ៖**

លោកប្រធាន ខ្ញុំអាចធ្វើការរៀបចំការធ្វើសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក ហ្វាស្ដើ ប៉ោ៖**

**ស៖** លោកសាក្សី ផ្អែកតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក ដែលលោកធ្លាប់ធ្វើការជាកងទ័ពខ្មែរក្រហម ក្នុងពេលរំដោះទីក្រុងភ្នំពេញ និងក្រោយពេលរំដោះទីក្រុងភ្នំពេញនោះ។ ចំពោះលោក តើបុគ្គលណាមួយដែលអាចដឹងហេតុការណ៍ ដែលកើតឡើងនៅក្នុងទីក្រុងភ្នំពេញ ក្នុងពេល -- រំដោះទីក្រុងភ្នំពេញ ឬក៏ក្រោយពេលរំដោះទីក្រុងភ្នំពេញនោះ តើមានបុគ្គលដូចលោកដែលមក -- អាចមកផ្ដល់ព័ត៌មានលម្អិតជាងនេះ ឬក៏មេបញ្ជាទេ ដែលផ្ដល់ព័ត៌មានច្រើនជាងនេះ?

[១៤:២៤:២៣]

**លោក គង់ គីម៖**

**ឆ៖** ខ្ញុំស្ដាប់សំណួរអត់បាន។ ឆ្លើយអត់កើត។

**ស៖** ខ្ញុំនឹងសួរឲ្យជាក់លាក់វិញ។ លោកគឺជាទាហាន មានអាយុ១៦ឆ្នាំ នាពេលនោះ។ ហើយលោកមិនមានសេរីភាពដើរហើរនៅក្នុងទីក្រុងភ្នំពេញនោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទពេលនោះគឺពិតជាត្រឹមត្រូវ ព្រោះការកំណត់គឺថា យើងមានសិទ្ធិតែកំណត់ដីប៉ុនណាយើងគ្រប់គ្រងតែប៉ុណ្ណឹង។ ដូចខ្ញុំជម្រាបហើយថា កងទ័ពខ្ញុំគ្មានម៉ោងសម្រាកទេ។ បាទ គ្មានម៉ោងធ្វើការ គ្មានម៉ោងសម្រាក គឺធ្វើការរហូត ហើយប្រចាំតែគោលដៅដែលគេប្រគល់ឲ្យ។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចនិយាយថា លោកដឹងតែអំពីរឿងរ៉ាវដែលកើតឡើងនៅក្នុងដីឡូត៍របស់លោក ដែលលោកឈរជើង ដូចដែលលោកបានលើកឡើងថា លោកយាមនៅឡូត៍ខាងជើងវត្តភ្នំតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់សំណួរនេះគឺថា ច្រំដែលៗយើងឮបីបួនដងប្រាំដងហើយ គឺមេធាវីព្យាយាមសួរ

សំណួរសង្ខេបឡើងវិញតែប៉ុណ្ណោះ។

**លោក ហ្សាស្តេ ប៉ៅ៖**

លោកប្រធានជាទីគោរព! ខ្ញុំព្យាយាមឲ្យលើកឡើងឲ្យមានប្រយោជន៍ទៅដល់សាក្សី។ ខ្ញុំមិនដឹងថា សាក្សីយល់សំណួរខាងដើមមុនៗ ឬក៏យ៉ាងណានោះទេ។ ខ្ញុំគ្រាន់តែសួរចូលមួយជំហានទៀត តែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងសំអាងហេតុត្រឹមត្រូវ។ សំណួរនេះសំណួរច្រំដែលច្រើនលើកច្រើនសាហើយ។ សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរច្រំដែលបែបនេះទេ!

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណ។

[១៤:២៦:៥៧]

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** ដោយសារតែលោកមានតួនាទីកម្រិត និងការដឹងក្នុងលក្ខណៈកម្រិតតែប៉ុណ្ណោះ ក្នុងអំឡុងពេលជម្លៀសទីក្រុងភ្នំពេញ និងប៉ុន្មានខែក្រោយពេលជម្លៀសទីក្រុងភ្នំពេញនោះ។ តើលោកអាចនិយាយបានទេថា មេបញ្ជាការកងពលដូច អឿន និង ដួច ហេង សំរិន តែប៉ុណ្ណោះ ដែលអាចដឹងអំពីទិដ្ឋភាពទូទៅរួមថាមានអ្វីកើតឡើងនៅក្នុងទីក្រុងភ្នំពេញ ក្នុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ និងរយៈពេលប៉ុន្មានខែក្រោយមក។ តើអ៊ីចឹងដែរឬទេ?

**លោក គង់ គីម៖**

**ឆ៖** បាទ កិច្ចការទាំងអស់នេះ ថ្នាក់ធំៗ គឺថាក៏ខ្ញុំអត់បានដឹងទេ ដោយសម័យនោះ គេមិនបានយកផែនការអីយកផ្សព្វផ្សាយជាទូលំទូលាយឲ្យយើងដឹងទេ។ បាទ គេដាក់តែផែនការឲ្យយើងអនុវត្តតែកន្លែងយើងអនុវត្តខ្លួនយើង។ រីឯថ្នាក់លើ និងថ្នាក់លើ គឺជាការងារផងគេ គឺគេមិនដែលយកមកផ្សព្វផ្សាយឲ្យយើងដឹងទេ។

[១៤:២៨:១១]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណ។ វាជាចម្លើយមួយត្រង់ ហើយវាជាក់ស្តែង ហើយសំណួរនេះវា -- ចម្លើយនេះគឺ

បានឲ្យខ្ញុំយល់។ ខ្ញុំមិនមានសំណួរបន្ថែមទៀតទេ ហើយលោកសេវិករបស់ខ្ញុំលោក សុន អរុណ នោះក៏មិនមានសំណួរបន្ថែមទៀតដែរ។ យើងខ្ញុំសូមជូនពរលោក និងអរគុណលោក សូមឲ្យលោកធ្វើដំណើរទៅផ្ទះវិញដោយសុវត្ថិភាព ហើយខ្ញុំមិនដឹងថា តើមេធាវីខាងក្រុមផ្សេងនោះមានសំណួរ ឬក៏អត់នោះទេ យើងខ្ញុំពីក្រុមមេធាវី នួន ជា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ ប្រសិនបើមាន។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! សួស្តីសហព្រះរាជអាជ្ញា សហភាគីទាំងអស់ ហើយក៏សួស្តីអស់លោកទាំងឡាយចូលរួមសវនាការនេះ នៅក្នុងបន្ទប់ ឬនៅក្រៅបន្ទប់ក្តី។

សួស្តីផងដែរលោក គង់ គីម ខ្ញុំ អាង ឧត្តម ហើយនៅខាងស្តាំដៃខ្ញុំនេះ គឺលោក ម៉ៃខល កាណាវាស។ យើងជាសហមេធាវីការពារក្តីលោក អៀង សារី។ នៅពេលនេះ យើងមិនមានសំណួរនឹងសួរលោកទេ។ តែយ៉ាងណាក្តី តាងនាមលោក អៀង សារី យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណចំពោះលោកដែលបានចូលមកផ្តល់សក្ខីកម្ម ជួយតុលាការក្នុងការស្វែងរកការពិត។ សូមលោកធ្វើដំណើរបានសុខសប្បាយតាមផ្លូវត្រឡប់ទៅវិញ។ សូមអរគុណលោកប្រធាន។

[១៤:២៩:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ ប្រសិនបើមាន។

សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្នុងនាមមេធាវីលោក ខៀវ សំផន ខ្ញុំអត់មានសំណួរអ្វីសម្រាប់សាក្សីរូបនេះទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក គង់ គីម ការស្តាប់សក្ខីកម្មរបស់លោក រហូតដល់ពេលនេះបានចប់

ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅដែលលោកមានបំណងចង់ទៅបានហើយ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីសមត្ថភាព លទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ សូមលោក គង់ គីម ជួបតែសំណាងល្អ ហើយនិងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៤:៣០:៥៣]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅដែលគាត់មានបំណងចង់ទៅបានហើយ។

សវនាការនៅថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-690 ដែលនឹងចាប់ផ្តើមសួរដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀត នៃរឿងក្តី។

ហើយអង្គជំនុំជម្រះ ក៏នឹងកោះហៅ ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-89 ជាការត្រៀមបម្រុងទុកដែរ។ សូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃចន្ទ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៣២ នាទី)*